ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ចក្ខុវិស័យ
# ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឆ្នាំ ២០៣០

*"ស្ថាប័ននៃឧត្តមភាព, មានគុណវុឌ្ឍិ, វិជ្ជាជីវៈ និង ស្មារតីទទួលខុសត្រូវខ្ពស់"*




២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ចក្ខុវិស័យ
# ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ឆ្នាំ ២០៣០

"ស្ថាប័ននៃឧត្តមភាព,
មានគុណវុឌ្ឍិ វិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវខ្ពស់"

ទទួលបានការអនុម័តដាក់ឱ្យអនុវត្ត
១៩ តុលា ២០២២

# អារម្ភកថា

# អារម្ភកថា



**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

សុខសន្តិភាព និង ស្ថិរភាពនយោបាយ ដែលទទួលបាន ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និង ចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានធ្វើឱ្យកម្ពុជាមានការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិយ៉ាងឆាប់រហ័ស ជាមួយនឹងសមិទ្ធផលច្រើនឥតគណនា គួរជាទីមោទនៈ។ កិច្ចអភិវឌ្ឍលើគ្រប់វិស័យ ដើម្បីសម្រេចឋានៈ ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ តាមរយៈ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤** នីតិកាលទី ៦ នៃរដ្ឋសភា គឺ “**កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព : កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០**” ធ្វើឱ្យជីវភាពប្រជាជនមានភាពល្អប្រសើរឡើង ។

ក្នុងនាមជាសេនាធិការរាជរដ្ឋាភិបាល, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដឹកនាំធ្វើនិម្មាបនកម្ម និង និយ័តកម្ម វិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ជានិម្មាបនករនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលជាប្រព័ន្ធគ្រប់គ្រង ចាត់ចែង និង ប្រើប្រាស់ថវិកាជាតិ ដែលជាប្រព័ន្ធសរសៃឈាមនៃរដ្ឋបាលសាធារណៈមិនអាចខ្វះបាន ។ ទិសដៅយុទ្ធសាស្ត្ររយៈពេលវែងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិតជាចាំបាច់ និង សមស្រប សម្រាប់គាំទ្ររាជរដ្ឋាភិបាល ដើម្បីសម្រេច **បង្គោលចរ ឆ្នាំ ២០៣០** ដែលធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ។ **ចក្ខុវិស័យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឆ្នាំ ២០៣០** គឺជាឯកសារយុទ្ធសាស្ត្រគោល រយៈពេលវែង និង ជាប្រទីបគោចរសម្រាប់តម្រង់ទិសការកសាងស្ថាប័ននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុផ្ទាល់ និងការអនុវត្តមុខងារស្នូល និង ពាក់ព័ន្ធរបស់ក្រសួង ប្រកបដោយប្រសិទ្ធភាព។

ចក្ខុវិស័យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឆ្នាំ២០៣០ គឺជាចក្ខុវិស័យនៃការកសាងស្ថាប័នឱ្យមានសមត្ថភាពពេញលេញក្នុងការបំពេញបេសកកម្ម សំដៅចូលរួមចំណែកឱ្យរាជរដ្ឋាភិបាលសម្រេចគោលដៅយុទ្ធសាស្ត្រ សម្រាប់ឆ្នាំ ២០៣០ ។ រីឯក្របខណ្ឌយុទ្ធសាស្ត្រ គឺការដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រ ព្រមទាំងយន្តការសម្រាប់អនុវត្តឆ្ពោះទៅសម្រេចបំណងប្រាថ្នានៃក្របខណ្ឌចក្ខុវិស័យ ។ ចក្ខុវិស័យដែលបានកំណត់ គឺការប្រែក្លាយ **«ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាស្ថាប័ននៃឧត្តមភាពប្រកបដោយសមត្ថភាព និងគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីបំពេញបេសកកម្មស្នូលនិងពាក់ព័ន្ធ ក្នុងការចូលរួមវិភាគទានឱ្យសម្រេចចក្ខុវិស័យរាជរដ្ឋាភិបាល»** ។ គោលបំណង ២, គោលដៅ ៧ និងយុទ្ធសាស្ត្រគន្លឹះ ៣១ ត្រូវបានដាក់ចេញ ដោយមានកំណត់អង្គភាពជំនាញ ដើម្បីទទួលបន្ទុករៀបចំ និង អនុវត្ត ជាមួយនឹងពេលវេលាកំណត់ច្បាស់លាស់ ។

ដើម្បីសម្រេចបាននូវចក្ខុវិស័យ ត្រូវតម្កល់ និងប្រតិបត្តិតាមឱ្យបានខ្ជាប់ខ្ជួននូវ “**គុណតម្លៃស្ថាប័ន**” នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចំនួន ៦ ដូចមានក្នុងខ្លឹមសារនៃចក្ខុវិស័យ ហើយថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទ, អង្គភាពពាក់ព័ន្ធ, បុគ្គលិក មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ត្រូវបំពេញកិច្ចការ ៣ យ៉ាង ក្នុង**ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ** គឺ **១.** ថែរក្សា និង ពង្រឹងបន្ថែមនូវការងារ និង សមិទ្ធផល ដែលសម្រេចបាននាពេលកន្លងមក **២.** ពង្រឹងសមត្ថភាព និង បន្តអនុវត្តការងារតាមបទដ្ឋានគតិយុត្តជាធរមាន និង យុទ្ធសាស្ត្រ ដែលបានដាក់ចេញប្រកបដោយនវានុវត្តន៍ និង **៣.** ប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម និង កិច្ចសហការ តាមរយៈការផ្តល់នូវគុណតម្លៃដល់ស្ថាប័ន និង ផលប្រយោជន៍ប្រជាជន និង សង្គមជាតិ ជាមួយនឹងការបន្តកសាងសមិទ្ធផលថ្មី ទាំងបច្ចុប្បន្ន និង អនាគត ហើយត្រូវសហការអនុវត្តជាមួយក្រសួង-ស្ថាប័ន, អង្គភាពពាក់ព័ន្ធផ្សេងៗទៀតក្រៅរចនាសម្ព័ន្ធរដ្ឋបាលក្រសួង ។ ក្នុងករណីមានបញ្ហាប្រឈមនៅសេសសល់ដែលស្ថិតក្រោមសមត្ថកិច្ចក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរួមគ្នាដោះស្រាយឱ្យបានទាន់ពេល ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ហើយត្រូវពង្រឹងគណនេយ្យភាពបន្ថែម ក្នុងការបំពេញមុខងារស្នូលក្នុងស្ថាប័ន ។ ដើម្បីពង្រឹង និង ពង្រីកលទ្ធភាពកម្ពុជា ចំពោះកាលា-

នុវត្តភាពនៃរបត់ថ្មី សម្រាប់សង្គម-សេដ្ឋកិច្ច, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវជំរុញការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបន្ថែមទៀត ដើម្បីឆ្ពោះទៅអនុវត្តដំណាក់កាលទី ៤ "**គណនេយ្យភាពសមិទ្ធកម្ម**" ជាដំណាក់កាលចុងក្រោយនាអនាគតដ៏ខ្លី ដើម្បីសម្រេចបានគោលដៅជាសារវន្តនៃកម្មវិធីកែទម្រង់គ្រប់ជ្រុងជ្រោយ មុនឆ្នាំ ២០៣០ ។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមគោរពថ្លែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលតែងតែមានសុទិដ្ឋិនិយម និង មោទនភាព ចំពោះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការបំពេញបេសកកម្មដឹកនាំ និង គ្រប់គ្រងវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុកម្ពុជាកន្លងមក ជាមួយស្មារតីទទួលខុសត្រូវខ្ពស់ ។ ទន្ទឹមនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំក្រសួង, ថ្នាក់ដឹកនាំអង្គភាព និង បុគ្គលិក មន្ត្រីរាជការក្រោមឱវាទគ្រប់លំដាប់ថ្នាក់, ជាពិសេសខ្ញុំសូមកោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ និង ជាប្រធានក្រុម-ការងាររៀបចំចក្ខុវិស័យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កម្រិតថ្នាក់ដឹកនាំ, ឯកឧត្តម **មាស សុខសេនសាន** អគ្គលេខាធិការ និង ជាប្រធានក្រុមការងារកម្រិតបច្ចេកទេស ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃក្រុមការងារទាំងពីរកម្រិត និង អ្នកពាក់ព័ន្ធ ដែលបានដឹកនាំផ្ទាល់ ប្រមូលផ្តុំកម្លាំងចូលរួមរៀបចំយ៉ាងសកម្ម ឱ្យសម្រេចបាននូវ **ចក្ខុវិស័យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឆ្នាំ ២០៣០** នេះ គ្រប់ជ្រុងជ្រោយ ក្លាយជាឯកសារយុទ្ធសាស្ត្ររយៈពេលវែង និង ជាសមិទ្ធផលផែនការនីយកម្មយុទ្ធសាស្ត្រថ្មី ប្រកបដោយទស្សនវិស័យវែងឆ្ងាយ សម្រាប់ជាឯកសារគោល របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ខ្ញុំពិតជាមានមោទនភាពចំពោះថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទក្រសួង, អង្គភាពពាក់ព័ន្ធ, បុគ្គលិក មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលនឹងសកម្មចូលរួមអនុវត្តចក្ខុវិស័យនេះ ដើម្បីសម្រេចគោលដៅយុទ្ធសាស្ត្រ ធ្វើឱ្យប្រសើរឡើងនូវសង្គម-សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាលកម្ពុជា ។

ថ្ងៃពុធ ៩រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

# មាតិកានុក្រម


អារម្ភកថា
ខ្លឹមសារសង្ខេបប្រតិបត្តិ

លេខទំព័រ

១ សេចក្តីផ្តើម ០១-០២
១.១ សារតារ
១.២ គោលបំណង និងសារៈសំខាន់
១.៣ វិសាលភាព

២ ការវិភាគស្ថានភាពបច្ចុប្បន្ន និងនិន្នាការអនាគត ០៣-១១
២.១ ការវិភាគស្ថានភាពបច្ចុប្បន្ន
២.១.១ ទិដ្ឋភាពសេដ្ឋកិច្ច
២.១.២ ទិដ្ឋភាពហិរញ្ញវត្ថុ
២.១.៣ ទិដ្ឋភាពស្ថាប័ន
២.១.៤ ទិដ្ឋភាពបរិវត្តកម្មឌីជីថល
២.២ និន្នាការអនាគត
២.២.១ និន្នាការតំបន់ និងសកល
២.២.២ កាលានុវត្តភាពសម្រាប់សេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា

៣ ចក្ខុវិស័យ និងបេសកកម្ម ១២-១៣
៣.១ ចក្ខុវិស័យ
៣.២ បេសកកម្ម

៤ ក្របខណ្ឌយុទ្ធសាស្ត្រ ១៤-២៩
៤.១ គោលបំណងទី១ : សមត្ថភាពនិងគុណវុឌ្ឍិជាស្ថាប័ននៃឧត្តមភាព
៤.១.១ គោលដៅទី១ : ពង្រឹងសមត្ថភាព និងវិជ្ជាជីវៈ
៤.១.២ គោលដៅទី២ : ជំរុញស្មារតីសកម្ម និងបុរេសកម្ម
៤.១.៣ គោលដៅទី៣ : ធានាភាពស្អាតស្អំ និងសុចរិតភាព
៤.២ គោលបំណងទី២ : ប្រសិទ្ធភាពនៃការអនុវត្តមុខងារនិងភារកិច្ច
៤.២.១ គោលដៅទី១ : បង្កើនភាពធន់នៃមូលដ្ឋានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ
៤.២.២ គោលដៅទី២ : ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងទ្រព្យសម្បត្តិរដ្ឋឆ្ពោះទៅឧត្តមានុវត្តន៍
៤.២.៣ គោលដៅទី៣ : ចូលរួមកសាងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈជាប្រព័ន្ធនិងគ្រប់ជ្រុងជ្រោយ
៤.២.៤ គោលដៅទី៤ : ចូលរួមជំរុញបរិវត្តកម្មឌីជីថល កសាងសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា

៥ គុណតម្លៃស្ថាប័ន ៣០

៦ យន្តការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ៣១

៧ ការវិភាគនិងការគ្រប់គ្រងហានិភ័យ ៣២-៣៣

៨ សន្និដ្ឋាន ៣៤

ឧបសម្ព័ន្ធ ៣៥-៦៤
ឧបសម្ព័ន្ធទី១ : ក្របខណ្ឌរួមនៃចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០
ឧបសម្ព័ន្ធទី២ : តារាងម៉ាទ្រីសតម្រង់ទិសការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ
ឧបសម្ព័ន្ធទី៣ : តារាងសម្រង់ឯកសារយុទ្ធសាស្ត្ររបស់អង្គភាពពាក់ព័ន្ធ
ឧបសម្ព័ន្ធទី៤ : បញ្ជីរាយនាមក្រុមការងាររៀបចំចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# ខ្លឹមសារសង្ខេបប្រតិបត្តិ

# ខ្លឹមសារសង្ខេបប្រតិបត្តិ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និងសមធម៌សង្គម។ ក្នុងរយៈពេលជិត ៣ ទសវត្សរ៍, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រេចសមិទ្ធផលជាច្រើន ដែលបានរួមចំណែកនាំឱ្យកម្ពុជាអភិវឌ្ឍប្រកបដោយឯករាជ្យ និងអធិបតេយ្យ។ បរិការណ៍កម្ពុជា និងពិភពលោកកំពុងផ្លាស់ប្តូរ ដែលទាមទារឱ្យរដ្ឋមានភាពធន់ សមត្ថភាពឆ្លើយតប និងអាចគ្រប់គ្រងវិបត្តិបានទាន់ពេល។ ក្នុងន័យនេះ ការបន្តកសាង និងពង្រឹងសមត្ថភាព និងអភិបាលកិច្ចស្ថាប័នរដ្ឋ រួមទាំងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផង ពិតជាមានសារៈសំខាន់ និងចាំបាច់ជាងពេលណាៗទាំងអស់ ដើម្បីធានាការអនុវត្តមុខងារនិងភារកិច្ចរបស់ក្រសួងប្រកបដោយប្រសិទ្ធភាពខ្ពស់ផងនិងចូលរួមចំណែកជំរុញឱ្យកម្ពុជាកាន់តែរឹងមាំ និងមានជវភាព។ ដូច្នេះ ឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសម្រេចរៀបចំ **“ចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ ២០៣០”**។

កម្មវត្ថុសំខាន់នៃចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០ គឺកសាងស្ថាប័ន ឱ្យមានសមត្ថភាព និងគុណវុឌ្ឍិគ្រប់គ្រាន់ សម្រាប់អនុវត្តបេសកកម្មរបស់ក្រសួង ផ្សារភ្ជាប់ជាមួយគោលដៅធំៗដែលមានកំណត់ក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង, ក្នុងគោលបំណងចូលរួមគាំទ្រឱ្យរាជរដ្ឋាភិបាលសម្រេចគោលដៅយុទ្ធសាស្ត្រជំរុញកម្ពុជាឱ្យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ក្នុងន័យនេះចក្ខុវិស័យក្រសួង ត្រូវបានកំណត់ថា **«នៅឆ្នាំ២០៣០ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាស្ថាប័ននៃឧត្តមភាព ប្រកបដោយសមត្ថភាព និងគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីបំពេញបេសកកម្មស្នូលនិងពាក់ព័ន្ធ ក្នុងការចូលរួមវិភាគទានឱ្យសម្រេចចក្ខុវិស័យរាជរដ្ឋាភិបាល»**។ នៅក្នុងដំណើរឆ្ពោះទៅសម្រេចចក្ខុវិស័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបំពេញបេសកកម្ម ៤ រួមមាន៖ ទី១-កសាងមូលដ្ឋានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ទី២-កសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ទី៣-ដឹកនាំ និងសម្របសម្រួលការកសាងប្រព័ន្ធគាំពារសង្គម, និង ទី៤-ចូលរួមដឹកនាំ សម្របសម្រួលបរិវត្តកម្មឌីជីថល និងកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា។

នៅក្នុងដែនបេសកកម្មខាងលើ ក្របខណ្ឌយុទ្ធសាស្ត្រត្រូវបានដាក់ចេញដើម្បីឈានទៅសម្រេចចក្ខុវិស័យ។ក្របខណ្ឌយុទ្ធសាស្ត្រ ចែកចេញជាគោលបំណង គោលដៅ យុទ្ធសាស្ត្រគន្លឹះ និងការងារអាទិភាព។ ការសម្រេចចក្ខុវិស័យ ត្រូវឈរលើគោលបំណងចំនួន ២ គឺ (១) “សមត្ថភាពនិងគុណវុឌ្ឍិជាស្ថាប័ននៃឧត្តមភាព” ដែលផ្តោតលើការកសាងស្ថាប័ននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្ទាល់ និង (២) “ប្រសិទ្ធភាពនៃការអនុវត្តមុខងារនិងភារកិច្ច” ដែលផ្តោតលើសមិទ្ធកម្មនៃការអនុវត្តមុខងារនិងភារកិច្ចកំណត់ក្នុងបេសកកម្មខាងលើ។ ដើម្បីសម្រេចគោលបំណងទាំង២, គោលដៅចំនួន ៧ ត្រូវបានដាក់ចេញ ដើម្បីតម្រង់ទិសការកំណត់យុទ្ធសាស្ត្រគន្លឹះ។ សម្រាប់គោលបំណងទី១-កសាងស្ថាប័ន, គោលដៅចំនួន ៣ ត្រូវសម្រេចឱ្យបាន រួមមាន៖ (១) ពង្រឹងសមត្ថភាព និងវិជ្ជាជីវៈ, (២) ជំរុញស្មារតីសកម្ម និងបុរេសកម្ម, និង (៣) ធានាភាពស្អាតស្អំ និងសុចរិតភាព។ គោលដៅទាំង៣ ត្រូវគាំទ្រដោយយុទ្ធសាស្ត្រគន្លឹះចំនួន ១៣។ សម្រាប់គោលបំណងទី២-បង្កើនប្រសិទ្ធភាពនៃការអនុវត្តមុខងារនិងភារកិច្ច, គោលដៅចំនួន ៤ ត្រូវសម្រេចឱ្យបាន រួមមាន៖ (១) បង្កើនភាពធន់នៃមូលដ្ឋានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ, (២) ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងទ្រព្យសម្បត្តិរដ្ឋឆ្ពោះទៅឧត្តមានុវត្តន៍, (៣) ចូលរួមកសាងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈជាប្រព័ន្ធនិងគ្រប់ជ្រុងជ្រោយ និង (៤) ចូលរួមជំរុញបរិវត្តកម្មឌីជីថល កសាងសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា។ គោលដៅទាំង៤ ត្រូវគាំទ្រដោយយុទ្ធសាស្ត្រគន្លឹះចំនួន ១៨។ ដើម្បីអនុវត្ត យុទ្ធសាស្ត្រគន្លឹះសរុបទាំង៣១នេះ, ការងារអាទិភាពចំនួន ១៤៦ ត្រូវបានកំណត់ផងដែរ សម្រាប់យកទៅអនុវត្តតាមលំដាប់ពេលវេលាច្បាស់លាស់។

ទស្សនាទានសំខាន់ៗដែលបានធានាដំណើរការប្រកបដោយប្រសិទ្ធភាព នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនាពេលកន្លងមក ព្រមជាមួយនឹងទស្សនាទានគន្លឹះថ្មីៗបន្ថែមទៀត ត្រូវបានធ្វើស្ថាប័នូបនីយកម្ម ទៅជា**គុណតម្លៃស្ថាប័ន** របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ គុណតម្លៃស្ថាប័ន មានចំនួន ៦ រួមមាន៖ ១-ក្រមសីលធម៌វិជ្ជាជីវៈ, ២-ស្មារតីបុរេសកម្ម, ៣-ប្រតិ-តុល្យការ, ៤-ប្រសិទ្ធភាព-ស័ក្តិសិទ្ធភាព, ៥-នវានុវត្តន៍ និង ៦-គុណាធិបតេយ្យ ត្រូវដក់ជាប់ក្នុងស្មារតីរបស់ថ្នាក់ដឹកនាំ និងបុគ្គលិក មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៅពេលបំពេញការងារ ដើម្បីធានាថាគ្រប់អង្គភាពអាចបំពេញការងារនៅក្នុង**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**។

ការសម្រេចចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ ២០៣០ ទាមទារឱ្យមានការចូលរួមអនុវត្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃ ពីថ្នាក់ដឹកនាំក្រសួង ថ្នាក់ដឹកនាំអង្គភាព មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងភាគីពាក់ព័ន្ធផ្សេងៗ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមេបញ្ជាការកម្រិតនយោបាយ ដោយមានអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការសម្របសម្រួលបច្ចេកទេស។ ថ្នាក់ដឹកនាំក្រសួងពាក់ព័ន្ធ គ្រប់អង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួង ទាំងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន អង្គភាព និងក្រុមការងារពាក់ព័ន្ធ មានភារកិច្ចចូលរួម សហការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ ទៅតាមសមត្ថកិច្ចរបស់អង្គភាព និងតាមការចាត់តាំងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

នៅក្នុងដំណាក់កាលអនុវត្ត អាទិភាពការងារកំណត់នៅតាមយុទ្ធសាស្ត្រគន្លឹះនីមួយៗ នៃក្របខណ្ឌយុទ្ធសាស្ត្រ ដែលមានកំណត់ផងដែរក្នុង**តារាងម៉ាទ្រីសតម្រង់ទិសការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ**(ឧបសម្ព័ន្ធទី២)ត្រូវយកទៅគិតគូររៀបចំបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់សាមីអង្គភាព រួចត្រូវរៀបចំគ្រោងថវិកាគាំទ្រក្នុងក្របខណ្ឌថវិកាពាក់ព័ន្ធ ទៅតាមសារជាតិនៃកិច្ចការងារ និងតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅក្នុងដំណាក់កាលតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ, ការតាមដាននិងត្រួតពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ ត្រូវរៀបចំចាប់ពីឆ្នាំ២០២៣តទៅ។ បន្ថែមពីនេះ ការវាយតម្លៃសមិទ្ធកម្មពាក់កណ្តាលកាលកំណត់ ត្រូវរៀបចំនៅឆ្នាំ២០២៦ និងជាចុងក្រោយ គឺការវាយតម្លៃសមិទ្ធកម្មចុងកាលកំណត់ ត្រូវរៀបចំនៅឆ្នាំ២០៣១។ ការពិនិត្យរបាយការណ៍តាមដាននិងត្រួតពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ និងរបាយការណ៍វាយតម្លៃសមិទ្ធកម្មពាក់កណ្តាលកាលកំណត់ និងចុងកាលកំណត់ ជារបៀបវារៈមួយនៃកិច្ចពិភាក្សាក្នុងវិបស្សនាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមពេលកំណត់ជាក់ស្តែង។

ឯកសារចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០ ត្រូវបានចាត់ទុកជាឯកសាររស់ ដែលជាកម្មវត្ថុនៃការកែប្រែទៅតាមការប្រែប្រួលកាលៈទេសៈសង្គម-សេដ្ឋកិច្ចកម្ពុជា និងគោលដៅយុទ្ធសាស្ត្រឆ្នាំ២០៣០ របស់រាជរដ្ឋាភិបាល។ ការសម្រេចឱ្យកែប្រែខ្លឹមសារនៃចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០ ត្រូវធ្វើឡើងបន្ទាប់ពីការវាយតម្លៃពាក់កណ្តាលកាលកំណត់ ពោលគឺនៅឆ្នាំ២០២៦ ទៅតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ១ សេចក្ដីផ្ដើម

# ១
# សេចក្តីផ្តើម

## ១.១ សាវតារ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦។ អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ “ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា” ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និងលើកតម្កើងជីវភាពប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និងសមធម៌សង្គម។

ក្នុងរយៈពេលជិត៣ទសវត្សរ៍, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសម្រេចសមិទ្ធផលជាច្រើនក្នុងការរួមចំណែកប្រែក្លាយកម្ពុជាពីប្រទេសដែលពឹងផ្អែកលើជំនួយបរទេសទាំងស្រុងក្នុងកិច្ចអភិវឌ្ឍ មកជាប្រទេសដែលអាចកៀរគរ គ្រប់គ្រង និងវិភាជបានកាន់តែមានប្រសិទ្ធភាពនូវធនធានរបស់ប្រទេស សម្រាប់បម្រើឱ្យការអភិវឌ្ឍទៅតាមទិសដៅយុទ្ធសាស្ត្ររបស់ខ្លួនប្រកបដោយឯករាជ្យ និងអធិបតេយ្យ។ ក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបំពេញតួនាទីសំខាន់និងចាំបាច់ ក្នុងការជំរុញស្ថាបនាគ្រឹះសេដ្ឋកិច្ចទៅតាមបរិការណ៍ប្រទេស និងសកលូបនីយកម្ម ព្រមទាំងចូលរួមដឹកនាំការរៀបចំ អនុវត្ត និងចូលរួមអនុវត្តគោលនយោបាយពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សម្រាប់វិស័យហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានកសាងនិងពង្រឹងជាបន្តបន្ទាប់នូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលឆ្លើយតប នឹងបរិការណ៍ប្រទេស និងកំពុងធ្វើទំនើបកម្មជាបណ្តើរៗឆ្ពោះទៅឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

បរិការណ៍កម្ពុជាកំពុងផ្លាស់ប្តូរ។ កម្ពុជាបានប្រែក្លាយពីប្រទេសចំណូលទាប ទៅជាប្រទេសចំណូលមធ្យមកម្រិតទាបនៅក្នុងឆ្នាំ២០១៥។ កម្រិតជីវភាពរបស់ប្រជាជនបានកើនឡើងគួរឱ្យកត់សម្គាល់ ដោយអត្រាភាពក្រីក្របានធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយ។ ចំនួនប្រជាជនដែលមានចំណូលមធ្យមបាននិងកំពុងកើនឡើង ជាមួយនឹងកំណើននៃការប្រើប្រាស់ និងតម្រូវការសេវាសាធារណៈកាន់តែមានប្រសិទ្ធភាព និងសម្បូរបែប។ ទន្ទឹមនេះ បរិការណ៍ពិភពលោកក៏កំពុងតែផ្លាស់ប្តូរ។ សង្គ្រាមពាណិជ្ជកម្ម, ការបែរត្រឡប់មកផ្តោតលើផលប្រយោជន៍ជាតិជាធំនៃបណ្តាប្រទេសនានា, ការបន្តកើនឡើងនូវកម្តៅ ភូមិសាស្ត្រនយោបាយ, ចរន្តតំបន់បូនីយកម្ម (Regionalisation), ចលនាឌីជីថលូបនីយកម្ម (Digitalisation) និងបរិវត្តកម្មឌីជីថល (Digital transformation) លើសកលលោក និងវិបត្តិសកលផ្សេងៗទៀត ទាមទារឱ្យកម្ពុជាបន្តកែលម្អគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបន្ថែមទៀត ជាពិសេស ពាក់ព័ន្ធនឹងតួនាទីរបស់រដ្ឋក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។នេះសំដៅលើតួនាទីរបស់រដ្ឋជាយុទ្ធសាស្ត្រវិទូ ដឹកនាំគាំទ្រដំណើរការទីផ្សារដែលរុញច្រានដោយវិស័យឯកជននិងធ្វើអន្តរាគមន៍តាមការចាំបាច់ ដើម្បីធានាផលប្រយោជន៍រួមរបស់ប្រជាជន កិច្ចដំណើរការប្រកបដោយប្រសិទ្ធភាពរបស់យន្តការទីផ្សារ និងជំរុញភាពជាម្ចាស់របស់ប្រជាជន លើមធ្យោបាយ កម្លាំងផលិតកម្ម និងផលិតផល។ ជាក់ស្តែង វិបត្តិជំងឺឆ្លងសកល កូវីដ-១៩ បានស្តែងឱ្យឃើញជាក់ច្បាស់នូវតម្រូវការឱ្យរដ្ឋមានភាពធន់ ខ្ពស់ ព្រមទាំងមានសមត្ថភាពឆ្លើយតប និងគ្រប់គ្រងវិបត្តិបានទាន់ពេល ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានមកលើសេដ្ឋកិច្ចជាតិ រដ្ឋបាលសាធារណៈ និងប្រជាជន។ ក្នុងន័យនេះ ការបន្តកសាងនិងពង្រឹងសមត្ថភាព និងអភិបាលកិច្ចស្ថាប័នរដ្ឋ រួមទាំងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផង ពិតជាមានសារៈសំខាន់ និងចាំបាច់ជាងពេលណាៗទាំងអស់ ដើម្បីធានាការអនុវត្តមុខងារនិងភារកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់ និងចូលរួមចំណែកជំរុញឱ្យកម្ពុជាកាន់តែរឹងមាំ និងមានជវភាព ស្របតាមទិសដៅយុទ្ធសាស្ត្រនានាដែលកំណត់ដោយរាជរដ្ឋាភិបាល។

ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យនិងភាពប្រាកដនិយមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, រាជរដ្ឋាភិបាលកម្ពុជាកំពុងរៀបចំដាក់ចេញនូវចក្ខុវិស័យរយៈពេលវែង ដោយចង់ប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដូច្នេះ ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមការដឹកនាំរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសម្រេចឱ្យមានការគិតគូរពិនិត្យការអនុវត្តការងាររបស់ក្រសួង រួចកំណត់ចក្ខុវិស័យ បេសកកម្ម និងដាក់ចេញនូវក្របខណ្ឌយុទ្ធសាស្ត្រដើម្បីគាំទ្រដល់ដំណើរឈានឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ក្នុងន័យនេះ ឯកសារយុទ្ធសាស្ត្ររយៈពេល ៩ ឆ្នាំ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំគឺ **“ចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ ២០៣០”** ដែលតទៅនេះ ហៅកាត់ថា **“ចក្ខុវិស័យក្រសួង”**។

## ១.២ គោលបំណង និងសារៈសំខាន់

ចក្ខុវិស័យក្រសួង គឺជាចក្ខុវិស័យនៃការកសាងស្ថាប័នឱ្យមានសមត្ថភាព និងគុណវុឌ្ឍិគ្រប់គ្រាន់ សម្រាប់បំពេញបេសកកម្មស្នូល និងបេសកកម្មចូលរួមអនុវត្តលើការងារដទៃទៀត ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងចូលរួមវិភាគទានឈានទៅសម្រេចបានចក្ខុវិស័យរួមរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ កម្មវត្ថុសំខាន់នៃការរៀបចំចក្ខុវិស័យក្រសួង គឺ ការកសាងស្ថាប័ន ដើម្បីអនុវត្តបេសកកម្មរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្សារភ្ជាប់ជាមួយគោលដៅធំៗដែលកំណត់ក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងគោលបំណងចូលរួមគាំទ្រឱ្យរាជរដ្ឋាភិបាលសម្រេចគោលដៅយុទ្ធសាស្ត្រជំរុញកម្ពុជាឱ្យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

ចក្ខុវិស័យក្រសួង នឹងផ្តល់សារៈប្រយោជន៍ដល់ថ្នាក់ដឹកនាំក្រសួង អង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលរបស់ក្រសួង ព្រមទាំងបុគ្គលិក មន្ត្រីរាជការនៃក្រសួង ជាសារវ័ន្តដូចតទៅ៖

| | |
|---|---|
| ១ | ជាឧបករណ៍ជំនួយដល់ថ្នាក់ដឹកនាំក្រសួង និងអង្គភាព ក្នុងការពង្រឹងស្ថាប័ន, ដឹកនាំ អនុវត្ត និងជំរុញអនុវត្តមុខងារស្នូលរបស់ខ្លួន |
| ២ | ជាប្រទីបគោចរសម្រាប់តម្រង់ទិសការរៀបចំយុទ្ធសាស្ត្ររយៈពេលវែង និងមធ្យម របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៣ | បង្កើនសមត្ថភាព ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ លើកទឹកចិត្ត និងបណ្តុះស្មារតីចូលរួមរបស់បុគ្គលិក មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ឱ្យយល់ច្បាស់ពីសារៈសំខាន់ និងបង្កើនការយកចិត្តទុកដាក់និងការទទួលខុសត្រូវខ្ពស់ក្នុងការបំពេញការងាររបស់ខ្លួនដែលជាការចូលរួមមិនអាចកាត់ផ្តាច់បានពីកម្លាំងរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៤ | ជំរុញនិងបង្កើនប្រសិទ្ធភាពនៃការផ្សារភ្ជាប់គោលបំណងគោលនយោបាយរបស់ក្រសួង ទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសផ្តល់មូលដ្ឋានប្រកបដោយភាពគ្រប់ជ្រុងជ្រោយ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ ព្រមទាំងគាំទ្រដល់ការរៀបចំផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យកាន់តែច្បាស់លាស់បន្ថែមទៀត។ |

## ១.៣ វិសាលភាព

ចក្ខុវិស័យក្រសួង មានវិសាលភាពគ្របដណ្តប់ដល់គ្រប់អង្គភាពស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ព្រមទាំងអង្គភាពស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្សេងៗទៀត។ អង្គភាពស្ថិតក្រោមអាណាព្យាបាលក្រសួង សំដៅដល់អង្គភាពអន្តរក្រសួង ស្ថាប័នដែលមានលក្ខណៈអចិន្ត្រៃយ៍ ឬអង្គភាពផ្សេងៗទៀតដែលស្ថិតនៅក្រៅរចនាសម្ព័ន្ធរដ្ឋបាលរបស់ក្រសួង ប៉ុន្តែមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាប្រធាន មានអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានស្ថិតនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬមានកញ្ចប់ថវិកាស្ថិតនៅក្នុងក្របខណ្ឌថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ២ ការវិភាគស្ថានភាពបច្ចុប្បន្ន និងនិន្នាការអនាគត

# ២

# ការវិភាគស្ថានភាពបច្ចុប្បន្ន និងទិន្នការអនាគត

## ២.១ ការវិភាគស្ថានភាពបច្ចុប្បន្ន

នៅក្នុងក្របខណ្ឌមុខងារនិងភារកិច្ចដែលកំណត់ដោយច្បាប់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាក្រសួង ស្ថាប័នដទៃទៀត បានចូលរួមចំណែកអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល តាមនីតិកាលនីមួយៗនៃរដ្ឋសភា ដោយសម្រេចបានសមិទ្ធផលសំខាន់ៗក្នុងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងអភិបាលកិច្ច ដូចមានបរិយាយលម្អិតក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០២៣។

ការវិភាគស្ថានភាពបច្ចុប្បន្ននៃវិស័យពាក់ព័ន្ធ ព្រមទាំងស្ថានភាពស្ថាប័ននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាការចាំបាច់ក្នុងការបូកសរុបសមិទ្ធផល យល់ច្បាស់ពីស្ថានភាពបច្ចុប្បន្ន និងកំណត់បញ្ហាប្រឈមសំខាន់ៗ ដើម្បីដាក់ចេញនូវចក្ខុវិស័យ និងក្របខណ្ឌយុទ្ធសាស្ត្ររបស់ក្រសួង។ សមិទ្ធផល ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ត្រូវបានសង្ខេបជាសារវ័ន្តដូចតទៅ៖

### ២.១.១ ទិដ្ឋភាពសេដ្ឋកិច្ច



រយៈពេល ២ ទសវត្សរ៍នេះ សេដ្ឋកិច្ចកម្ពុជាមានកំណើនខ្ពស់ក្នុងរង្វង់ ៧% ជាមធ្យមក្នុងមួយឆ្នាំ ធ្វើឱ្យផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) សម្រាប់មនុស្សម្នាក់ កើនដល់ ១.៧០០ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ ហើយត្រូវបានទទួលស្គាល់ថា ជាខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី។ ប្រជាជនកម្ពុជារាប់លាននាក់បានរួចផុតពីភាពក្រីក្រ ពីកម្រិតស្មើរ ១០០% នៅថ្ងៃ ៧ មករា ១៩៧៩ មកស្ថិតក្នុងរង្វង់ប្រមាណ ១៧% នាពេលបច្ចុប្បន្ន។ អត្រាអតិផរណានៅកម្ពុជាស្ថិតក្នុងកម្រិតមួយដែលគ្រប់គ្រងបាន រីឯអត្រាប្តូរប្រាក់មានស្ថិរភាព ក្នុងកម្រិតជាមធ្យមប្រមាណ៤.០៥៥រៀលក្នុងមួយដុល្លារអាមេរិក។សមិទ្ធផលនេះបាននាំមកនូវឱកាសសម្រាប់ប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់ ក្នុងការស្វែងរកការងារ បង្កើនប្រាក់ចំណូល និងធ្វើឱ្យគម្លាតប្រាក់ចំណូលស្ថិតក្នុងកម្រិតទាប។

របត់សំខាន់នៃការអភិវឌ្ឍនេះ កើតឡើងក្នុងឆ្នាំ២០២០-២០២១ គឺវិបត្តិជំងឺរាតត្បាតជាសកលកូវីដ-១៩ ដែលកម្ពុជាក៏ដូចជាបណ្តាប្រទេសនានា កំពុងរងផលប៉ះពាល់ ជាពិសេសមកលើការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ការប្រកបអាជីវកម្ម ធ្វើការ និងការរស់នៅរបស់ប្រជាជន។ ក្នុងឆ្នាំ២០២០, សេដ្ឋកិច្ចកម្ពុជាមានកំណើនអវិជ្ជមានក្នុងអត្រា -៣,១%។ រាជរដ្ឋាភិបាលបានឆ្លើយតបយ៉ាងឆាប់រហ័ស ដោយដាក់ចេញនូវយុទ្ធសាស្ត្រជំរុញភាពស៊ាំសហគមន៍ តាមរយៈការបង្កើនល្បឿនចាក់វ៉ាក់សាំងជូនប្រជាជន និងដាក់ចេញនូវ “ក្របខណ្ឌនិងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ឆ្នាំ២០២១-២០២៣” ដែលកំពុងផ្តល់ផ្លែផ្កាជាបណ្តើរៗ ក្រោយការបើកសេដ្ឋកិច្ចឡើងវិញទាំងស្រុង។

ក្នុងរយៈពេលមធ្យមខាងមុខ បើទោះបីជាការព្យាករថាកំណើនសេដ្ឋកិច្ចសកលនឹងងើបឡើងវិញក្តី ការចាកចេញរបស់កម្ពុជាពីឋានៈប្រទេសដែលមានការអភិវឌ្ឍតិចតួច ទៅជាប្រទេសកំពុងអភិវឌ្ឍ នឹងនាំមកនូវបញ្ហាប្រឈមមួយចំនួនសម្រាប់សេដ្ឋកិច្ចកម្ពុជា រួមមាន៖ ការថយចុះនៃថវិកាជំនួយ និងភាពអនុគ្រោះខាងពាណិជ្ជកម្ម, ការថមថយរំហូរទុនវិនិយោគពីបរទេស, មូលដ្ឋានសេដ្ឋកិច្ចចង្អៀត និងល្បឿនពិពិធកម្មសេដ្ឋកិច្ចយឺត, ថ្លៃដើមធុរកិច្ចនៅខ្ពស់, ប្រព័ន្ធដឹកជញ្ជូន និងឡជីស្ទីកមានកម្រិត, ការសម្របសម្រួលស្ថាប័ន ពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច, បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញ, ផលិតភាពសេដ្ឋកិច្ចទាប, និងភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម[1] ។

[1] ដកស្រង់ចេញពីក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២២

## ២.១.២ ទិដ្ឋភាពហិរញ្ញវត្ថុ

### វិស័យហិរញ្ញវត្ថុសាធារណៈ




កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាកម្មវិធីកែទម្រង់រយៈពេលវែងរបស់រាជរដ្ឋាភិបាល ដែលបាន និងកំពុងកសាងនិងធ្វើទំនើបកម្មប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាឆ្ពោះទៅស្តង់ដារអន្តរជាតិ។ ផែនការយុទ្ធសាស្ត្រសំខាន់ៗ ត្រូវបានដាក់ចេញ និងបច្ចុប្បន្នកម្មជាបន្តបន្ទាប់គ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃប្រព័ន្ធទាំងមូល ទាំងផ្នែកចំណូល-ចំណាយសាធារណៈ ទ្រព្យសម្បត្តិរដ្ឋ អធិការកិច្ចហិរញ្ញវត្ថុនិងសវនកម្ម វិមជ្ឈការហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលនាំឱ្យមានការដាក់ឱ្យអនុវត្តនូវក្របខណ្ឌគតិយុត្តគោលចាំបាច់ជាច្រើន សម្រាប់ដំណើរការគ្រប់គ្រងជ្រោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សម្រាប់ឆ្នាំ២០២០-២០២១ វិចារណកម្មថវិកាត្រូវបានធ្វើឡើង ដោយបង្វែរថវិកាមកផ្តោតអាទិភាពលើការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងទប់ទល់ផលប៉ះពាល់មកលើសេដ្ឋកិច្ចជាតិ។ ឆ្លងកាត់ដំណាក់កាលលំបាកនេះ ស្ថានភាពហិរញ្ញវត្ថុសាធារណៈកម្ពុជានៅល្អប្រសើរ ឆ្លុះបញ្ចាំងតាមរយៈការធានាបានការប្រមូលចំណូលជារួមមិនឱ្យធ្លាក់ចុះខ្លាំង, លទ្ធភាពវិភាជចំណាយឡើងវិញក្នុងឆ្នាំ ឆ្លើយតបបាននឹងការប្រែប្រួលយ៉ាងឆាប់រហ័សនៃអាទិភាពគោលនយោបាយ និងតម្រូវការដោះស្រាយបញ្ហាប្រឈមក្នុងសង្គម-សេដ្ឋកិច្ច។ ប្រការនេះបង្ហាញបានយ៉ាងច្បាស់ថា កិច្ចខិតខំប្រឹងប្រែងកែទម្រង់បានផ្តល់ផលវិជ្ជមានក្នុងការកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរឹងមាំ ជា “ឧបករណ៍គោលនយោបាយ” បម្រើឱ្យការអភិវឌ្ឍនៅកម្ពុជា។

ការវាយតម្លៃក្របខណ្ឌចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ(PEFA)ឆ្នាំ២០២០បានបង្ហាញអំពីស្ថានភាពជាទូទៅនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា លើទិដ្ឋភាពនៃសូចនាករគន្លឹះ ៣ ដូចតទៅ៖

(១) វិន័យថវិកា៖ ការព្យាករចំណូល និងរដ្ឋបាលចំណូលត្រូវបន្តពង្រឹង រីឯផ្នែកចំណាយត្រូវដោះស្រាយលើចំណាយកកស្ទះ និងពង្រឹងការតាមដាននៅ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ (២) ប្រសិទ្ធភាពវិភាជថវិកា៖ ត្រូវបង្កើនគុណភាពឯកសារថវិកា, ពង្រឹងការរៀបចំថវិកាពហុឆ្នាំ; (៣) ស័ក្តិសិទ្ធភាពការផ្តល់សេវាសាធារណៈ៖ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (រួមទាំងសវនកម្ម) ត្រូវពង្រឹងបន្ថែម, ការតាមដាននិងវាយតម្លៃសមិទ្ធកម្មនៅខ្ចះខ្ចាត, កិច្ចលទ្ធកម្មសាធារណៈមិនទាន់មានការប្រកួតប្រជែង, ការផ្សព្វផ្សាយ និងតម្លាភាពថវិកាសម្រាប់ក្រសួង-ស្ថាប័នផ្តល់សេវាសាធារណៈ នៅពុំទាន់បានល្អតាមឧត្តមានុវត្តន៍នៅឡើយ។

របាយការណ៍ស្តីពីវឌ្ឍនភាពប្រចាំឆ្នាំ២០២០ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានពិនិត្យស៊ីជម្រៅលើស្ថានភាពនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឃើញថានៅមានបញ្ហាប្រឈមបច្ចេកទេសមួយចំនួនដែលចាំបាច់ត្រូវដោះស្រាយ រួមមាន៖ ចីរភាពកំណើនចំណូលសារពើពន្ធសម្រាប់រយៈពេលវែង, ស្ថាបនូបនីយកម្មយន្តការប្រមូលនិងគ្រប់គ្រងចំណូល ទាំងសារពើពន្ធ និងមិនមែនសារពើពន្ធ, សម្រាប់ថវិកាកម្មវិធី គុណភាពកម្មវិធីនៅមិនទាន់ល្អតាមការចង់បាននៅឡើយ ទាំងខ្លឹមសារ និងរចនាសម្ព័ន្ធ នៅតែចំណុះរចនាសម្ព័ន្ធរដ្ឋបាល ដែលពិបាកផ្សារភ្ជាប់នឹងគោលនយោបាយ និងសកម្មភាពអនុវត្តការបន្តរក្សាការគ្រប់គ្រងថវិកាប្រមូលផ្តុំនៅក្រសួង ស្ថាប័នមួយចំនួន ដោយអនុញ្ញាតឱ្យមានអង្គភាពថវិកា និងផ្តល់សិទ្ធិអំណាចតិចតួច នាំឱ្យគណនេយ្យភាពសមិទ្ធកម្មការងារជំនាញក៏នៅពុំទាន់អាចកំណត់បានច្បាស់លាស់, នីតិវិធីអនុវត្តថវិកាត្រូវបានកែលម្អច្រើន ប៉ុន្តែនៅមិនទាន់អាចធានាភាពឆាប់រហ័ស ត្រឹមត្រូវ និងអាចប៉ាន់ប្រមាណបាននៅឡើយ, ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅជាបញ្ហាប្រឈមសំខាន់ដែលត្រូវយកចិត្តទុកដាក់ថែមទៀត, ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន កំពុងឈានឆ្ពោះទៅមុខយ៉ាងឆាប់រហ័ស ជាមួយនឹងការបន្ទាន់សម័យប្រព័ន្ធជាមួយនឹងតម្រូវការអ្នកប្រើប្រាស់, ការពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពិតជាចាំបាច់ដើម្បីប្រែក្លាយការងារកែទម្រង់ទៅជាការងារប្រចាំថ្ងៃផង និងឆ្លើយតបទៅនឹងគោលដៅបន្តនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្ពោះទៅប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មផង។

## វិស័យហិរញ្ញវត្ថុមិនមែនធនាគារ

វិស័យហិរញ្ញវត្ថុមិនមែនធនាគារ មានការរីកចម្រើនជាបន្តបន្ទាប់ និងកាន់តែឆាប់រហ័ស ដែលកំពុងចូលរួមចំណែកបង្កើនភាពសម្បូរបែបនៃផលិតផល និងសេវាកម្មហិរញ្ញវត្ថុនៅកម្ពុជាជាពិសេសក្រោយការដាក់ចេញយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ២០១១-២០២០, បច្ចុប្បន្នភាព ២០១៦- ២០២៥ និងការធ្វើសមាហរណកម្មស្ថាប័ននិយ័តកម្មវិស័យពាក់ព័ន្ធជាអាទិ៍ វិស័យធានារ៉ាប់រងនិងសោធនឯកជន វិស័យមូលបត្រ វិស័យសន្តិសុខសង្គម វិស័យបរធនបាលកិច្ច វិស័យគណនេយ្យនិងសវនកម្ម និងវិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ឱ្យស្ថិតក្រោមបញ្ញត្តិករតែមួយ គឺអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

ទន្ទឹមនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនេះ នៅមានបញ្ហាប្រឈមមួយចំនួនសម្រាប់វិស័យទាំងមូល រួមមាន៖ តម្រូវការក្របខណ្ឌគតិយុត្តឱ្យបានគ្រប់គ្រាន់ និងស្របតាមសម្ទុះនៃការអភិវឌ្ឍ, ដំណើរការនិងប្រសិទ្ធភាពនៃការចុះត្រួតពិនិត្យផ្ទាល់ យន្តការត្រួតពិនិត្យផ្សេងៗ និងភាពម៉ឺងម៉ាត់នៃការចាត់វិធានការច្បាប់, ភាពមានកម្រិតនៃការផ្សព្វផ្សាយ ការពង្រឹងសមត្ថភាព និងការលើកទឹកចិត្តដល់វិស័យឯកជន, ព្រមទាំងបញ្ហាប្រឈមដោយឡែកៗផ្សេងទៀតតាមវិស័យនីមួយៗ។

## កិច្ចគាំពារសង្គម

កិច្ចគាំពារសង្គម ជាអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលចាប់ពីដំណាក់កាលដំបូងនៃការអភិវឌ្ឍប្រទេស។ កន្លងមក គោលនយោបាយសង្គមកិច្ចជាច្រើនត្រូវបានដាក់ឱ្យដំណើរការក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ ភាពងាយរងគ្រោះ វិសមភាព រួមចំណែកដល់ការគាំពារ និងអភិវឌ្ឍធនធានមនុស្ស និងជំរុញកំណើនសេដ្ឋកិច្ច។ ប៉ុន្តែការកសាងប្រព័ន្ធគាំពារសង្គម ជាកិច្ចការលក្ខណៈពហុវិស័យដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធីពាក់ព័ន្ធផ្សេងៗ។ ហេតុដូច្នេះ នៅឆ្នាំ២០១៧, “ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥” ត្រូវបានដាក់ចេញ ដើម្បីបង្កើនប្រសិទ្ធភាព និងសង្គតិភាពនៃរបប ឬកម្មវិធីទាំងអស់ ផ្តោតលើគោលការណ៍សំខាន់ៗ គឺ៖ (១) ការកែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រងប្រព័ន្ធគាំពារសង្គមទាំងមូល, (២) ការបង្កើនប្រសិទ្ធភាពចំណាយថវិការដ្ឋ, (៣) ការពង្រីកវិសាលភាពគ្របដណ្តប់ជាអតិបរមា និង (៤) ការពិនិត្យបញ្ហាឆ្លងវិស័យ។

ផ្អែកលើក្របខណ្ឌគោលនយោបាយនេះ អភិបាលកិច្ចប្រព័ន្ធគាំពារសង្គមត្រូវបានរៀបចំឡើង ដោយបង្កើតឱ្យមានក្រុមប្រឹក្សាជាតិ គណៈកម្មាធិការប្រតិបត្តិ អគ្គលេខាធិការដ្ឋាន និងប្រតិបត្តិករនៃប្រព័ន្ធទាំង២ គឺប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម ដោយធ្វើសមាហរណកម្មប្រតិបត្តិករ និងកម្មវិធី ឬរបបផ្សេងៗតាមការចាំបាច់សម្រាប់បង្កើនប្រសិទ្ធភាព។ ទន្ទឹមនេះ ក្របខណ្ឌគតិយុត្តជាច្រើនត្រូវបានដាក់ឱ្យអនុវត្ត រីឯការផ្សព្វផ្សាយក៏កាន់តែទូលំទូលាយ និងសម្បូរបែប។ ជោគជ័យជាក់ស្តែងនៃកិច្ចខិតខំប្រឹងប្រែងកសាងប្រព័ន្ធគាំពារសង្គមនៅកម្ពុជា ស្តែងឱ្យឃើញតាមរយៈប្រសិទ្ធភាព ភាពបត់បែន និងភាពរស់រវើក នៃយន្តការគាំទ្រដល់វិធានការអន្តរាគមន៍របស់រដ្ឋ ក្នុងកាលៈទេសៈនៃការរីករាលដាលកូវីដ-១៩ ក្នុងសហគមន៍ នៅឆ្នាំ២០២០-២០២២នេះ ក្រោមរូបភាពជាការឧបត្ថម្ភសាច់ប្រាក់ជូនប្រជាជនក្រីក្រ និងងាយរងគ្រោះ ព្រមទាំងកម្មវិធីជំនួយសង្គមផ្សេងៗទៀត។

### ២.១.៣ ទិដ្ឋភាពស្ថាប័ន



ធនធានមនុស្ស គឺជាធនធានសំខាន់មិនអាចខ្វះបានរបស់ស្ថាប័ន។ ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព គុណវុឌ្ឍិ សមត្ថភាព និងផលិតភាព ដើម្បីឆ្លើយតបនឹងតម្រូវការបង្កើនសមត្ថភាព និងប្រសិទ្ធភាពស្ថាប័ន ជាកត្តាគន្លឹះដែលត្រូវបានយកចិត្តទុកដាក់ជាអាទិភាព ទាំងក្នុងកម្រិតរាជរដ្ឋាភិបាល និងកម្រិតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនេះ ការរៀបចំស្ថាប័នឱ្យមានរចនាសម្ព័ន្ធសមស្រប, ការបែងចែកតួនាទី និងភារកិច្ច និងកំណត់បន្ទាត់គណនេយ្យភាព, ការសម្របសម្រួលអន្តរស្ថាប័ន-អង្គភាព, គុណាធិបតេយ្យ, ហេដ្ឋារចនាសម្ព័ន្ធការងារ, និងការតាមដាននិងត្រួតពិនិត្យ ជាការងារចាំបាច់សម្រាប់បង្កើនសមត្ថភាពស្ថាប័ន។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងអនុវត្តការងារគ្រប់គ្រងបុគ្គលិកទៅតាមក្របខណ្ឌផ្ទៃក្នុងច្បាស់លាស់។ ប្រព័ន្ធលើកទឹកចិត្តដែលគ្របដណ្តប់ទូទាំងក្រសួង ត្រូវបានដាក់ឱ្យអនុវត្ត ចាប់ពីឆ្នាំ២០១៤ មក។ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រការបំពេញការងារ ក៏ត្រូវបានកែលម្អជាបន្តបន្ទាប់ ទៅតាមដំណាក់កាល និងលទ្ធភាពថវិកា។ ការអនុវត្តប្រព័ន្ធខាងលើ គួបផ្សំជាមួយការរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធការងារល្អ បានផ្តល់ផលត្រឡប់មកវិញ ជាសមិទ្ធកម្មការងារជំនាញជាក់ស្តែង ប្រកបដោយគុណភាព ប្រសិទ្ធភាព និងនវានុវត្តន៍ នៅគ្រប់ផ្នែក គ្រប់ផែន នៃសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវបានទទួលស្គាល់ ជាទូទៅក្នុងមជ្ឈដ្ឋានស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។ បន្ថែមពីនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំពុងអនុវត្ត “ក្របខណ្ឌគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស ឆ្នាំ២០១៨-២០២៣” សំដៅប្រើប្រាស់ឱ្យអស់សក្តានុពលនូវធនធានមនុស្សដែលមានស្រាប់, អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ បុគ្គលិក ប្រកបដោយនវានុវត្តន៍, និងលើកកម្ពស់គុណផល និងគុណភាព នៃការផ្តល់សេវាសាធារណៈ ទៅតាមប្រព័ន្ធការងារផ្អែកលើសមិទ្ធកម្ម។

ទោះយ៉ាងណា នៅមានបញ្ហាប្រឈមជាច្រើនដែលក្រសួងជួបប្រទះក្នុងទិដ្ឋភាពស្ថាប័នផ្ទាល់ រួមមាន៖ រចនាសម្ព័ន្ធអង្គភាព និងមុខតំណែងកែសម្រួល, ខ្វះមន្ត្រីបំពេញប្រអប់, ការគ្រប់គ្រងចលនាមន្ត្រីរាជការ, ផែនការក្របខណ្ឌមន្ត្រីរាជការ និងផែនការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាមានមូលដ្ឋានរៀបចំតូចចង្អៀត, ការគ្រប់គ្រងបៀវត្សនៅមិនទាន់ឆ្លើយតបបានរហ័សទៅនឹងបម្រែបម្រួលស្ថានភាពមន្ត្រី, ការត្រួតពិនិត្យបុគ្គលិក និងការគ្រប់គ្រងវិន័យនៅមិនទាន់បានអនុវត្តតាមលិខិតបទដ្ឋានទាំងស្រុង, ការគ្រប់គ្រងទិន្នន័យមន្ត្រីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានស្ថិតនៅដំណាក់កាលចាប់ផ្តើម, ការគ្រប់គ្រងសមិទ្ធកម្ម និងការលើកទឹកចិត្តដំណើរការ ប៉ុន្តែពុំទាន់អាចវាស់វែងសមិទ្ធកម្មមន្ត្រីផ្ទាល់ និងកំណត់បន្ទាត់គណនេយ្យភាពបានពេញលេញ, កម្រិតយេនឌ័រ និងជនពិការ, ការអភិវឌ្ឍសមត្ថភាពពុំទាន់មានលក្ខណៈជាប្រព័ន្ធ ពុំទាន់មានការតាមដាននិងវាយតម្លៃ តម្រូវការបណ្តុះបណ្តាល និងពុំទាន់មានផែនការកសាងសមត្ថភាព និងផែនការបន្តវេន[2]។

[2] ក្របខណ្ឌគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស ឆ្នាំ២០១៨-២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### ២.១.៤ ទិដ្ឋភាពបរិវត្តកម្មឌីជីថល

វិស័យឌីជីថលត្រូវបានមើលឃើញថាជាប្រភពកំណើនថ្មី មានសក្តានុពលខ្ពស់ ក្នុងការលើកកម្ពស់កម្រិតអភិវឌ្ឍនៃសេដ្ឋកិច្ចកម្ពុជាដោយដើរតួនាទីជាជន្ទល់កំណើនថ្មីនិងជាចលករគាំទ្រវិស័យទ្រទ្រង់និងលើកស្ទួយសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម និងវែង។ ក្នុងបរិការណ៍កម្ពុជា ការធ្វើបរិវត្តកម្មឌីជីថល គឺជាការចាប់យកឌីជីថល និងការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មាន និងឌីជីថល ដើម្បី៖ ទី១-ផលិតភាព ប្រសិទ្ធភាព និងកំណើនសេដ្ឋកិច្ច, ទី២-កសាងសង្គមស៊ីវិល័យ ដែលពលរដ្ឋប្រើប្រាស់សេវាឌីជីថល ដោយបរិយាបន្ន ជំនឿទុកចិត្ត និងសុវត្ថិភាពខ្ពស់ និង ទី៣-បង្កើនការឆ្លើយតបរបស់រដ្ឋទៅនឹងតម្រូវការសង្គម ភាពសម្បូរបែប និងប្រសិទ្ធភាពនៃសេវាសាធារណៈ ។



ដោយឌីជីថលូបនីយកម្មនៅកម្ពុជា ស្ថិតក្នុងដំណាក់កាលចាប់ផ្តើមនៅឡើយ, ការត្រៀមខ្លួនចាប់យកវិស័យឌីជីថលកំពុងស្ថិតនៅកម្រិតទាប។ ហេតុដូច្នេះ “ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥” ត្រូវបានរៀបចំឡើងជាទស្សនវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ក្នុងការតម្រង់ទិសបរិវត្តកម្មឌីជីថល ដោយដាក់ចេញនូវក្របខណ្ឌគោលនយោបាយ ក្របខណ្ឌអនុវត្ត និងយន្តការសម្របសម្រួល តាមដាន និងវាយតម្លៃ រួមទាំងការបង្កើនយន្តការស្ថាប័នច្បាស់លាស់ផងដែរ។

ទោះជាយ៉ាងណា ការត្រៀមខ្លួនចាប់យកវិស័យឌីជីថល នៅជួបបញ្ហាប្រឈមច្រើន រួមមាន៖ ភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ទាំងឌីជីថល ដឹកជញ្ជូន និងឡូជីស្ទីក, ក្របខណ្ឌគតិយុត្ត, ភាពជឿទុកចិត្តលើបច្ចេកវិទ្យា ចំណេះដឹងជំនាញ និងភាពជាអ្នកដឹកនាំឌីជីថល, ការអភិវឌ្ឍធនធានមនុស្ស និងទាក់ទាញទេពកោសល្យឌីជីថលនៅមិនទាន់ឆ្លើយតបនឹងតម្រូវការទីផ្សារ, ពុំមានថ្នាលជាតិរួម ឬស្តង់ដារបច្ចេកទេសតម្រូវរួមសម្រាប់ស្ថាប័នរដ្ឋ, ប្រព័ន្ធអេកូឡូស៊ីធុរកិច្ចឌីជីថលសហគ្រិនភាព និងធុរកិច្ចថ្មី ស្ថិតក្នុងដំណាក់កាលចាប់ផ្តើម និងចូលរួមបានតិចតួចក្នុងខ្សែច្រវាក់តម្លៃតំបន់ និងសកល[3]។

[3] ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥

## ២.២ និន្នាការអនាគត

### ២.២.១ និន្នាការតំបន់ និងសកល

បច្ចុប្បន្ន កម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលស្តារនិងពង្រឹងសេដ្ឋកិច្ចជាតិ ក្នុងបរិការណ៍នៃការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី។ ទន្ទឹមនេះ កត្តាវិវត្តប្រែប្រួលជាសកលនៅថ្ងៃអនាគត ដែលអាចធ្វើឱ្យរចនាសម្ព័ន្ធសេដ្ឋកិច្ច និងពាណិជ្ជ-កម្មសកលប្រែប្រួល នឹងត្រូវកំណត់ដោយនិន្នាការធំៗមួយចំនួន រួមមាន៖

**១ និម្មាបនកម្មសេដ្ឋកិច្ចសកលបង្ហាញនិន្នាការថ្មីមួយកាន់តែច្បាស់**

និន្នាការពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចដែលនឹងលេចឡើងថ្មី គឺនិន្នាការ “តំបន់ូបនីយកម្ម” ដែលនឹងធ្វើឱ្យសណ្ឋាននៃវិនិយោគ និងពាណិជ្ជកម្មសកលផ្លាស់ប្តូរ ទាំងទិសដៅ មធ្យោបាយ និងប្រភេទទំនិញនិងសេវា។ ការកើនឡើងនៃគោលនយោបាយគាំពារនិយម និងផ្តោតតែលើការជំរុញសេដ្ឋកិច្ចក្នុងស្រុក នឹងធ្វើឱ្យកំណើនសេដ្ឋកិច្ចនិងពាណិជ្ជកម្មសកលមិនពេញសក្តានុពលនិងធ្វើឱ្យលំហូរមូលធនសកលនិងវិនិយោគរវាងប្រទេសនិងប្រទេស តំបន់និងតំបន់ ប្រព្រឹត្តទៅក្នុងភាពរឹតត្បិត និងប្រុងប្រយ័ត្នខ្ពស់ជាងមុន។ ទោះយ៉ាងណា និន្នាការនេះនឹងនាំឱ្យមានការប្រមូលផ្តុំវិនិយោគនៅក្នុងតំបន់ដែលមានសក្តានុពល គឺតំបន់អាស៊ី និយាយជារួម, តំបន់អាស៊ីប៉ូស៊ីហ្វិក និងអាស៊ីអាគ្នេយ៍ និយាយដោយឡែក[4]។

**២ ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា“បដិវត្តន៍ឧស្សាហកម្មទី៤.0”**

ល្បឿនឌីជីថលូបនីយកម្ម និងបរិវត្តកម្មឌីជីថលនៅលើពិភពលោកកំពុងកើនឡើង។ បច្ចេកវិទ្យាឌីជីថល មានលទ្ធភាពបង្កើនផលិតភាពនិងប្រសិទ្ធភាពសេដ្ឋកិច្ច ជំរុញពិពិធកម្ម បង្កើតការងារ ដែលអាចចូលរួមកាត់បន្ថយភាពក្រីក្រ និងវិសមភាពសង្គម។ វិស័យឌីជីថលអាចជាប្រភពកំណើនថ្មី មានសក្តានុពលខ្ពស់ ក្នុងការលើកកម្ពស់សេដ្ឋកិច្ចកម្ពុជាឱ្យមានកំណើនប្រកបដោយជវភាព[5]។

**៣ ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ**

ការប្រែប្រួលអាកាសធាតុ បង្កើតជាហានិភ័យធ្ងន់ធ្ងរសម្រាប់មនុស្សជាតិ និងជាប្រធានបទចម្បងក្នុងសតវត្សទី២១។ ផលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ មិនត្រឹមតែមានលើសុខភាពសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែក៏មានលើការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ស្វែងរកដំណោះស្រាយ។ ដូចគ្នានេះដែរ តំបន់អាស៊ីអាគ្នេយ៍នឹងជួបប្រទះការគំរាមកំហែងពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុកាន់តែច្រើន។ ការសិក្សាស្រាវជ្រាវបានបង្ហាញថា និន្នាការនេះនឹងកាន់តែកើនថែមទៀតរហូតដល់ចុងសតវត្សរ៍។ កម្ពុជាត្រូវយកចិត្តទុកដាក់អនុវត្តផែនការសកម្មភាពបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុដើម្បីសម្រេចគោលដៅសេដ្ឋកិច្ចបៃតងនិងលើកកម្ពស់ជីវភាពប្រជាជន ជាពិសេស ក្រុមងាយរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ[6]។

4 ដកស្រង់ចេញពីចំណុចទី៦ ក្នុងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២២

5 ការសំយោគចេញពីក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥

6 ដកស្រង់ចេញពីឯកសារ “Cambodia’s Updated Nationally Determined Contribution (NDC)” ឆ្នាំ២០២០

## ២.២.២ កាលានុវត្តភាពសម្រាប់សេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា

កម្ពុជាសម្លឹងឃើញការប្រែក្លាយវិបត្តិឱ្យទៅជាកាលានុវត្តភាពសម្រាប់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចតទៅ៖

### ១ គន្លងប្រក្រតីភាពថ្មី

ជំងឺកូវីដ-១៩ ត្រូវបានរំពឹងថានឹងក្លាយជាផ្នែកមួយនៃ "គន្លងប្រក្រតីភាពថ្មី"។ ក្នុងស្មារតីនេះ ការអនុវត្ត "ក្របខណ្ឌនិងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ឆ្នាំ២០២១-២០២៣" នឹងជំរុញរក្សាលំនឹងសេដ្ឋកិច្ច កែលម្អជន្ទល់កំណើនសក្តានុពលឱ្យងើបឡើងវិញ និងទាញយកឱ្យបានជាអតិបរមានូវកាលានុវត្តភាពថ្មីដែលកំពុងលេចឡើង ចាត់ទុកបានជាចលករកំណើនដែលអាចប៉ះប៉ូវឱ្យការងើបឡើងវិញយឺតនៃសេដ្ឋកិច្ចសកល។ គន្លងប្រក្រតីភាពថ្មី ជាកាលានុវត្តភាពដ៏ល្អសម្រាប់បង្កើនសម្ទុះកែទម្រង់គ្រប់ផ្នែក និងគ្រប់វិស័យ ដើម្បីបង្កើនប្រសិទ្ធភាព ភាពឆ្លើយតប និងគណនេយ្យភាពរបស់រដ្ឋ ព្រមទាំងពង្រឹងមូលដ្ឋានសេដ្ឋកិច្ចឱ្យរឹងមាំជាងមុន។ ការទាញយកកាលានុវត្តភាពនេះ នឹងជំរុញឱ្យកម្ពុជាអាចបន្តរក្សាកំណើនរឹងមាំក្នុងរយៈពេលមធ្យម ដូចដែលធ្លាប់មានមុនវិបត្តិ ឬកាន់តែល្អជាងមុន។

### ២ សេដ្ឋកិច្ចពិភពលោកនឹងនាំមុខដោយទ្វីបអាស៊ី

សេដ្ឋកិច្ចពិភពលោកនឹងនាំមុខដោយទ្វីបអាស៊ី ពិសេស អាស៊ីបូព៌ា ដែលកត្តានេះបន្តផ្តល់ "ឱកាសមាស"[7] សម្រាប់កម្ពុជាទាញយកផលប្រយោជន៍ជាអតិបរមាពីកត្តាភូមិសាស្ត្ររបស់ខ្លួន ដែលស្ថិតនៅចំកណ្តាលនៃតំបន់ដែលកំពុងមានកំណើនប្រកបដោយឥរភាពនិងសក្តានុពល សម្រាប់អភិវឌ្ឍ និងធ្វើទំនើបកម្មផលិតកម្ម ឧស្សាហកម្ម និងសេវាកម្មរបស់កម្ពុជា ជាមួយបណ្តាប្រទេសក្នុងតំបន់។ ទន្ទឹមនេះ ការបង្វែរការបញ្ជាទិញផលិតផល និងចលនាផ្លាស់ប្តូររោងចក្រ និងទីតាំងវិនិយោគ រវាងបណ្តាប្រទេសក្នុងតំបន់ ជាឱកាសដែលកម្ពុជាត្រូវទាញយកឱ្យបានក្នុងរយៈពេលមធ្យម និងវែងខាងមុខ។

### ៣ ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក ព្រមទាំងគំនិតផ្តួចផ្តើមសហប្រតិបត្តិការផ្សេងៗទៀតនឹងបង្កើតចលនាសេរីភាវូបនីយកម្មពាណិជ្ជកម្មទំនិញ-សេវានិងវិនិយោគក្នុងតំបន់ដែលនឹងជួយជំរុញស្តារឡើងវិញ និងពង្រីកកាន់តែខ្លាំងក្លាជាងមុននូវពាណិជ្ជកម្មក្នុងតំបន់ ទោះបីវិបត្តិនៃជំងឺកូវីដ-១៩ នៅពុំទាន់ផុតរលត់ទាំងស្រុងនៅឡើយ។ បន្ថែមពីនេះ ការចូលជាធរមានជាបន្តបន្ទាប់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិន (CCFTA) និង កម្ពុជា-កូរ៉េ (CKFTA) ព្រមទាំងកិច្ចខិតខំប្រឹងប្រែងចរចាកិច្ចព្រមព្រៀងទ្វេភាគីផ្សេងៗទៀត នឹងផ្តល់អត្ថប្រយោជន៍ច្រើនសន្ធឹកសន្ធាប់ដល់កម្ពុជា។

[7] យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

## ៤ ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក្នុងដំណាក់កាលនៃបដិវត្តន៍ឧស្សាហកម្មទី៤.០ (IR4.0) បានកើតឡើង និងរីកចម្រើនទាន់ពេល ឬនិយាយម្យ៉ាងទៀតថា ដោយសារតែការរីករាលដាលនៃវិបត្តិជំងឺកូវីដ-១៩, បានបង្កើតនូវមុខរបរ និងធុរកិច្ចថ្មីៗជាច្រើនដែលមិនធ្លាប់មានពីមុនមក និងចូលរួមចំណែកកសាងសេដ្ឋកិច្ចនិងសង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយកបរិវត្តកម្មឌីជីថលនៅគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងធុរជន និងប្រជាជនទូទៅ ជាចលករជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់ជីវភាពប្រជាជនតាមគន្លងប្រក្រតីភាពថ្មីដែលកម្ពុជាត្រូវតែចាប់យកឱកាសនេះឱ្យបាន។

## ៥ លទ្ធភាពពិពិធកម្មប្រភពហិរញ្ញប្បទានសម្រាប់វិនិយោគសាធារណៈ

ដើម្បីជំរុញក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ កម្ពុជាត្រូវបង្កើនវិនិយោគសាធារណៈក្នុងកម្រិតសមស្របមួយ ដែលអាចឆ្លុះបញ្ចាំងពីល្បឿននៃកំណើនសេដ្ឋកិច្ចផង និងតម្រូវការនៃកិច្ចអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមផង។ កត្តានេះ តម្រូវឱ្យរាជរដ្ឋាភិបាលគិតគូរស្វែងរកប្រភពហិរញ្ញប្បទានសក្តានុពលផ្សេងទៀត ជាពិសេសការបោះផ្សាយលក់មូលបត្ររដ្ឋ និងយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។ ដោយស្ថានភាពបំណុលសាធារណៈកម្ពុជាស្ថិតក្នុងស្ថានភាពគ្រប់គ្រងបាន ពោលគឺមាន "ចីរភាព" និង "ហានិភ័យកម្រិតទាប" មានន័យថា កម្ពុជាមានសមត្ថភាពខ្ចីច្រើនជាងមុន។ យន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ជាឧបករណ៍ដ៏សំខាន់សម្រាប់ទាក់ទាញហិរញ្ញប្បទានបន្ថែមពីវិស័យឯកជន ទាំងទុនក្នុងប្រទេស និងពីក្រៅប្រទេស ដើម្បីបង្កើនទំហំនៃវិនិយោគស្របតាមគោលដៅរបស់រាជរដ្ឋាភិបាល។ ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន (ភ.រ.ឯ.) នឹងរួមចំណែកកៀរគរហិរញ្ញប្បទានវិនិយោគសាធារណៈតាមយន្តការថ្មីនេះ ប្រកបដោយប្រសិទ្ធភាព។

## ៦ ភាពសម្បូរបែបនៃការផ្តល់កិច្ចសហការបច្ចេកទេស និងហិរញ្ញប្បទាន ឆ្លើយតបការប្រែប្រួលអាកាសធាតុ

ការកសាងភាពធន់នឹងគ្រោះធម្មជាតិនិងវិបត្តិផ្សេងៗប្រកបដោយចីរភាពនិងបរិយាបន្នជាប្រធានបទសកលដែលកំពុងមានរដ្ឋ និងស្ថាប័នអន្តរជាតិជាច្រើនចាប់អារម្មណ៍ផ្តល់ហិរញ្ញប្បទានគាំទ្រ។ កម្ពុជាអាចទាញយកកាលានុវត្តភាពពីភាពសម្បូរបែបនៃការផ្តល់កិច្ចសហការបច្ចេកទេស និងហិរញ្ញប្បទាន ដែលជាប្រភពហិរញ្ញប្បទានថ្មី សម្រាប់អភិវឌ្ឍ កសាងភាពធន់ និងចីរភាពនៃសេដ្ឋកិច្ច តាមអភិក្រមនៃការអភិវឌ្ឍបៃតង (Green Growth) ដែលធានាតុល្យភាពរវាងតម្រូវការអភិវឌ្ឍ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

## ៧ លទ្ធភាពដកពិសោធន៍សម្រាប់រៀបចំប្រព័ន្ធគាំពារសង្គមគ្រប់ជ្រុងជ្រោយនិងមានចីរភាព

វិធានការឆ្លើយតបនឹងវិបត្តិជំងឺកូវីដ-១៩ ទាំង១០ជុំកន្លងមក និងវិធានការជំនួយសង្គមសម្រាប់ប្រជាជនក្រីក្រក្នុងកាលៈទេសៈនៃការរីករាលដាលក្នុងសហគមន៍នៃជំងឺនេះ ជាកាលានុវត្តភាពសម្រាប់ទាញយកបទពិសោធន៍ជាក់ស្តែងពីការអនុវត្តគោលនយោបាយទាំងនេះ សម្រាប់ឈានទៅរៀបចំប្រព័ន្ធគាំពារសង្គមកម្ពុជា ដែលមានភាពគ្រប់ជ្រុងជ្រោយ និងចីរភាព។

## ៨ ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ និងក្របខណ្ឌថវិការយៈពេលមធ្យម

ការចាប់ផ្តើមរៀបចំ និងអនុវត្តក្របខណ្ឌហិរញ្ញវត្ថុសាធារណៈក្របខណ្ឌថវិការយៈពេលមធ្យម និងការត្រៀមខ្លួនអនុវត្តថវិកាសមិទ្ធកម្ម នឹងអនុញ្ញាតឱ្យរាជរដ្ឋាភិបាលគិតគូរជាយុទ្ធសាស្ត្ររយៈពេលមធ្យម លើគោលនយោបាយសារពើពន្ធ និងថវិកា ដែលអាចមើលឃើញច្បាស់នូវទិដ្ឋភាពជារួម និងធ្វើអាទិភាវូបនីយកម្មវិស័យសំខាន់ៗ ដែលជំរុញកំណើនសេដ្ឋកិច្ចជាតិរយៈពេលវែង។ ក្នុងនោះ វិស័យអាទិភាពដែលត្រូវបន្តផ្តោតរួមមាន វិស័យសង្គមកិច្ច វិស័យសេដ្ឋកិច្ច និងវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់។

## ៩ ដំណើរការកែទម្រង់អភិបាលកិច្ចផ្នែកហិរញ្ញវត្ថុសាធារណៈឆ្ពោះទៅ “គណនេយ្យភាពសមិទ្ធកម្ម”

ដំណើរឆ្ពោះទៅគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ “គណនេយ្យភាពសមិទ្ធកម្ម” នឹងនាំមកនូវឱកាសកសាងប្រព័ន្ធ យន្តការ ក្របខណ្ឌគតិយុត្ត និងការពង្រឹងធនធានមនុស្សជាដំណាក់កាល ដើម្បីប្រែក្លាយថវិកាជាឧបករណ៍គោលនយោបាយពិតប្រាកដ ដែលធានាប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព និងភាពរស់រវើកនៃប្រព័ន្ធរដ្ឋបាលសម្រាប់រដ្ឋទំនើបនាពេលអនាគត។

# ៣ ចក្ខុវិស័យ និងបេសកកម្ម

# ៣
# ចក្ខុវិស័យ និងបេសកកម្ម

## ៣.១ ចក្ខុវិស័យ

ឈរលើគោលបំណងគាំទ្រ និងចូលរួមចំណែកអនុវត្តវិធានការគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកំណត់និងដាក់ចេញនូវចក្ខុវិស័យ ប្រកបដោយមហិច្ឆតា និងប្រាកដនិយមថា៖

> **“នៅឆ្នាំ២០៣០ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាស្ថាប័ននៃឧត្តមភាព ប្រកបដោយសមត្ថភាព និងគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីបំពេញបេសកកម្មស្នូលនិងពាក់ព័ន្ធ ក្នុងការចូលរួមវិភាគទានឱ្យសម្រេចចក្ខុវិស័យរាជរដ្ឋាភិបាល។”**

**ស្ថាប័ននៃឧត្តមភាព** (Institution of excellence) សំដៅលើស្ថាប័នពេញដោយសមត្ថភាព និងគុណវុឌ្ឍិគ្រប់គ្រាន់ ដែលមានលក្ខណសម្បត្តិ ៣ យ៉ាង រួមមាន៖

| ១ | ២ | ៣ |
|---|---|---|
| *សមត្ថភាព និងជំនាញវិជ្ជាជីវៈខ្ពស់* | *ភាពសកម្ម និងបុរេសកម្ម* | *ភាពស្អាតស្អំ និងសុចរិតភាព* |

ស្ថាប័ននៃឧត្តមភាព បំពេញ**មុខងារដែលច្បាប់ និងរាជរដ្ឋាភិបាលប្រគល់ឱ្យ** ប្រកបដោយប្រសិទ្ធភាព ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីរួមចំណែកឱ្យរាជរដ្ឋាភិបាលសម្រេច **“បង្គោលចរឆ្នាំ២០៣០”** គឺកម្ពុជាក្លាយជា**ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់** និងបន្តគាំទ្រឱ្យរាជរដ្ឋាភិបាលសម្រេច “ចក្ខុវិស័យកម្ពុជា ២០៥០” គឺប្រែក្លាយកម្ពុជាជា**ប្រទេសមានចំណូលខ្ពស់**។

## ៣.២ បេសកកម្ម

បេសកកម្មស្នូលនិងពាក់ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកំណត់ដូចខាងក្រោម៖

១ កសាងមូលដ្ឋានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ

២ កសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ

៣ ដឹកនាំ និងសម្របសម្រួលការកសាងប្រព័ន្ធគាំពារសង្គម

៤ ចូលរួមដឹកនាំ និងសម្របសម្រួលបរិវត្តកម្មឌីជីថល ការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល។

ការអនុវត្តបេសកកម្មទាំង៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានវិសេសភាពដូចតទៅ៖

### ១ កសាងមូលដ្ឋានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ជាតិ

ក្នុងកម្រិតគោលនយោបាយនិងយុទ្ធសាស្ត្រ,ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានមុខងារសំខាន់ដោយមានការចូលរួមសហការពីធនាគារជាតិនៃកម្ពុជា និងក្រសួង ស្ថាប័នពាក់ព័ន្ធ សម្រាប់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុ។

### ២ កសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុវត្តមុខងារជានិម្មាបនករ (Architect) នៃប្រព័ន្ធ, ជាស្ថាប័នដឹកនាំរៀបចំប្រព័ន្ធ ក្របខណ្ឌគតិយុត្ត យន្តការ គោលនយោបាយ និងកសាងធនធានមនុស្សសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដោយមានក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពសាធារណៈផ្សេងៗ ជាប្រតិបត្តិករ។

## ៣ ដឹកនាំ និងសម្របសម្រួលការកសាងប្រព័ន្ធគាំពារសង្គម

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានមុខងារដឹកនាំ និងសម្របសម្រួល កសាង គ្រប់គ្រងប្រព័ន្ធគាំពារសង្គម និងរៀបចំក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រ ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ ទៅតាមយន្តការស្ថាប័នដែលកំណត់ដោយក្របខណ្ឌគតិយុត្តជាធរមាន។

## ៤ ចូលរួមដឹកនាំ និងសម្របសម្រួលបរិវត្តកម្មឌីជីថល ការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានមុខងារចូលរួមដឹកនាំ សម្របសម្រួល និងជំរុញការងារបរិវត្តកម្មឌីជីថលនៅកម្ពុជា ការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល និងការគិតគូរវិភាជថវិកាគាំទ្រ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈយន្តការស្ថាប័នពាក់ព័ន្ធ។

### ដ្យាក្រាមទី១៖
### ក្របខណ្ឌរួម នៃចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០



# ៤ ក្របខណ្ឌយុទ្ធសាស្ត្រ

# ៤
# ក្របខណ្ឌយុទ្ធសាស្ត្រ

ក្របខណ្ឌយុទ្ធសាស្ត្រ ត្រូវបានដាក់ចេញដើម្បីកំណត់វិធានការយុទ្ធសាស្ត្រជាក់លាក់ សំដៅជំរុញសម្រេចគោលបំណងនៃចក្ខុវិស័យក្រសួង។ ក្របខណ្ឌយុទ្ធសាស្ត្រ ចែកចេញជា គោលបំណង គោលដៅ យុទ្ធសាស្ត្រគន្លឹះ និងការងារអាទិភាព។ **គោលបំណង** ជាបំណែកនៃកម្មវត្ថុរបស់ចក្ខុវិស័យ។ **គោលដៅ** ជាទិសដៅយុទ្ធសាស្ត្រឆ្លើយតបនឹងគោលបំណង។ **យុទ្ធសាស្ត្រគន្លឹះ** ជាវិធានការអន្តរាគមន៍គន្លឹះ ដើម្បីសម្រេចគោលដៅ។ **ការងារអាទិភាព** ជាការងារចាំបាច់ត្រូវបំពេញជាដំណាក់កាលៗទៅតាមយុទ្ធសាស្ត្រគន្លឹះនីមួយៗ។ ការងារអាទិភាព ជាភារកិច្ចអនុវត្តដោយអង្គភាពពាក់ព័ន្ធ ទៅតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ **តារាងម៉ាទ្រីសតម្រង់ទិសការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ** ត្រូវបានកំណត់ជាឧបសម្ព័ន្ធទី២ នៃឯកសារនេះ។ នៅតាមគោលដៅនីមួយៗ មានកំណត់ជា **លទ្ធផលរំពឹងទុក** ដែលអាចចាត់ទុកជាសូចនាករសមិទ្ធកម្មគន្លឹះ ក្នុងកម្រិតលទ្ធផលចុងក្រោយ (Impact / Outcome indicators) សម្រាប់វាស់វែងការសម្រេចគោលដៅដែលបានដាក់ចេញ។

ដើម្បីសម្រេចចក្ខុវិស័យ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំណត់**គោលបំណង ២** រួមមាន៖ ទី១-បង្កើនសមត្ថភាពនិងគុណវុឌ្ឍិជាស្ថាប័ននៃឧត្តមភាព និង ទី២-បង្កើនប្រសិទ្ធភាពនៃការអនុវត្តមុខងារនិងភារកិច្ច។ ការកំណត់គោលបំណងចំនួនពីរដូចនេះ ឆ្លើយតបទៅនឹងកម្មវត្ថុនៃចក្ខុវិស័យក្រសួង ដែលកំណត់ឱ្យ "កសាងស្ថាប័ន" ដើម្បី "បំពេញបេសកកម្មស្នូលនិងពាក់ព័ន្ធ"។ ការសម្រេចគោលបំណងទាំង២ ត្រូវគាំទ្រដោយ**គោលដៅ ៧** និង**យុទ្ធសាស្ត្រគន្លឹះ ៣១** ព្រមទាំងការងារអាទិភាពតាមយុទ្ធសាស្ត្រគន្លឹះនីមួយៗ ដូចតទៅ៖

## ៤.១ គោលបំណងទី១ : សមត្ថភាពនិងគុណវុឌ្ឍិជាស្ថាប័ននៃឧត្តមភាព

គោលបំណងទី១ នៃក្របខណ្ឌយុទ្ធសាស្ត្រ កំណត់ឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្លាយជាសេនាធិការរបស់រាជរដ្ឋាភិ-បាល ដែលមានសមត្ថភាព និងគុណវុឌ្ឍិពេញលេញ ប្រកបដោយលក្ខណសម្បត្តិ ៣ យ៉ាង គឺ (១) សមត្ថភាព និងវិជ្ជាជីវៈ, (២) ស្មារតីសកម្ម និងបុរេសកម្ម និង (៣) ភាពស្អាតស្អំ និងសុចរិតភាព។ គោលបំណងទី១ ជាគោលបំណងផ្តោតលើការកសាងស្ថាប័នផ្ទៃក្នុង ដែលត្រូវអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្ទាល់។ ដើម្បីសម្រេចគោលបំណងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំណត់គោលដៅចំនួន ៣ ដូចតទៅ៖

### ៤.១.១ គោលដៅទី១ : ពង្រឹងសមត្ថភាព និងវិជ្ជាជីវៈ

ធនធានមនុស្សនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវប្រែក្លាយជាមូលធនមនុស្ស ដែលមានសមត្ថភាពពេញលេញចំណេះដឹង ជំនាញជាក់លាក់ និងបំពេញការងារល្អ ដោយប្រកាន់ខ្ជាប់ក្រមសីលធម៌វិជ្ជាជីវៈដោយពុំមានករណីលើកលែង។ ការអភិវឌ្ឍធនធានមនុស្ស ប្រព័ន្ធ និងយន្តការការងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តអភិវឌ្ឍ និងពង្រឹងបន្ថែមឱ្យឆ្លើយតបនឹងតម្រូវការកសាង និងរក្សាមូលធនមនុស្ស ដែលធានាផលិតភាព គុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការងារជំនាញ និងសមភាពយេនឌ័រ ស្ថិតនៅក្រោមក្របខណ្ឌគតិយុត្ត និងគោលនយោបាយផ្ទៃក្នុងច្បាស់លាស់ ពេញលេញ និងស្របតាមក្របខណ្ឌថ្នាក់ជាតិ។

ដើម្បីពង្រឹងសមត្ថភាព និងវិជ្ជាជីវៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តោតលើ៖

## យុទ្ធសាស្ត្រគន្លឹះទី១ : ប្រព័ន្ធអភិវឌ្ឍមូលធនមនុស្ស

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំប្រព័ន្ធធានាផលិតកម្មមូលធនមនុស្សដែលមានគុណវុឌ្ឍិ ចំណេះដឹង ជំនាញ បំណិនការងារ គំនិតនវានុវត្តន៍ ព្រមទាំងប្រកាន់ខ្ជាប់គុណធម៌ សីលធម៌ និងមនសិការវិជ្ជាជីវៈ។ ប្រព័ន្ធអភិវឌ្ឍមូលធនមនុស្ស ត្រូវដំណើរការតាម **អភិក្រម ៤ ត្រូវ នៃការគ្រប់គ្រងធនធានមនុស្ស** គឺ **"រើសត្រូវ បណ្តុះបណ្តាលត្រូវ ប្រើប្រាស់ត្រូវ និង ទុកដាក់ត្រូវ"** និងត្រូវស្ថិតក្រោមគោលការណ៍គុណាធិបតេយ្យ និងប្រតិតុល្យការ។ ការងារអាទិភាពដែលត្រូវយកចិត្តទុកដាក់ រួមមាន៖

### រើសត្រូវ

- ពង្រឹងការជ្រើសរើសបុគ្គលិក មន្ត្រីរាជការ ដែលរួមមានទាំងការប្រឡងប្រជែងជ្រើសរើសមន្ត្រីថ្មី និងបុគ្គលិកជាប់កិច្ចសន្យានៅគ្រប់អង្គភាព ដោយឈរលើគោលការណ៍អនុលោមភាព តម្លាភាព សមត្ថភាព និងផ្អែកលើតម្រូវការជំនាញជាក់ស្តែងរបស់អង្គភាព
- ពង្រឹងយន្តការស្នើផ្តល់ជូនក្របខណ្ឌពិសេស សម្រាប់បុគ្គលិកមានគុណវុឌ្ឍិ សមត្ថភាព ឆន្ទៈ បំណិនការងារនវានុវត្តន៍ ដែលបានបំពេញការងារបម្រើបេសកកម្មក្រសួងច្រើនឆ្នាំប្រកបដោយគុណភាព
- សាកល្បងអនុវត្តការជ្រើសរើស និងប្រើប្រាស់មន្ត្រី តាមប្រព័ន្ធនិយោជន៍ ទៅតាមការអនុញ្ញាតរបស់រាជរដ្ឋាភិបាលសម្រាប់ការងារជំនាញវិជ្ជាជីវៈជាក់លាក់ ជាជំហានៗ

### បណ្តុះបណ្តាលត្រូវ

- ជំរុញរៀបចំ និងបង្កើនគុណភាពនៃផែនការអភិវឌ្ឍធនធានមនុស្សនៅតាមអង្គភាពក្រោមឱវាទក្រសួង ឆ្លើយតបនឹងតម្រូវការរបស់អង្គភាពផ្ទាល់ និងផែនការយុទ្ធសាស្ត្រតាមវិស័យជំនាញនីមួយៗ
- រៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាព វគ្គបណ្តុះបណ្តាល និងវិក្រឹតការ ជាការតម្រង់ទិស ឬវគ្គទូទៅ នៅថ្នាក់ក្រសួង និងបណ្តុះបណ្តាលរយៈពេលខ្លី-មធ្យម សម្រាប់បច្ចុប្បន្នភាព ឬបំពាក់ជំនាញថ្មីជាក់លាក់ នៅអង្គភាពជំនាញផ្ទាល់ និងលើកទឹកចិត្តឱ្យបណ្តុះបណ្តាលគ្រូបង្គោល ដើម្បីបណ្តុះបណ្តាលបន្តគ្នា តាមលំដាប់លំដោយ
- ពង្រឹងការចាត់បញ្ជូនមន្ត្រីចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលឱ្យចំមុខងារទទួលបន្ទុក និងជំរុញការចែករំលែកចំណេះដឹងផ្ទៃក្នុង
- ជំរុញលើកទឹកចិត្តអគ្គាភិវឌ្ឍន៍ ស្របតាមតម្រូវការជំនាញរបស់អង្គភាព

### ប្រើប្រាស់ត្រូវ

- ពង្រឹងការគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ ការវិភាគមុខងារ តម្រូវការគុណវុឌ្ឍិសម្រាប់មុខតំណែង និងការគ្រប់គ្រងគុណវុឌ្ឍិមន្ត្រីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- បែងចែកមន្ត្រី ផ្អែកលើគុណវុឌ្ឍិ ជំនាញ ការចង់បានរបស់មន្ត្រី និងតម្រូវការអង្គភាព-ក្រសួង, ដើម្បីទទួលបានមន្ត្រីមានសមត្ថភាព ចំជំនាញត្រូវការ រីឯមន្ត្រីអាចបញ្ចេញសមត្ថភាព ព្រមទាំងបន្តរៀនសូត្រ បំប៉នជំនាញពីការងារផ្ទាល់
- ជំរុញឱ្យមានសៀវភៅណែនាំការងារជំនាញនៅតាមនាយកដ្ឋាន ដើម្បីជាឯកសារជំនួយដល់ការអនុវត្តការងារ

### ទុកដាក់ត្រូវ

- បង្កើតកាលានុវត្តភាពសម្រាប់ការវិវឌ្ឍអាជីពរបស់មន្ត្រី ទាំងក្នុងមុខតំណែងរដ្ឋបាល និងមុខតំណែងវិជ្ជាជីវៈ
- តែងតាំងមន្ត្រីឱ្យកាន់មុខតំណែង ដោយផ្អែកលើសមត្ថភាព បុគ្គលិកលក្ខណៈ និងអតីតភាពការងារ។

## យុទ្ធសាស្ត្រគន្លឹះទី២ : ប្រព័ន្ធការងារលើកតម្កើងសមត្ថភាព

អង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវមានប្រព័ន្ធការងារផ្ទៃក្នុង ដែលប្រើប្រាស់សមត្ថភាពមន្ត្រីឱ្យអស់សក្តានុពល និងជំរុញលើកទឹកចិត្តឱ្យមន្ត្រីបន្តលើកកម្ពស់សមត្ថភាព។ ដើម្បីបង្កើនផលិតភាពការងារកាន់តែល្អប្រសើរ និងធានាថាមន្ត្រីដែលមានសមត្ថភាព អាចបំពេញការងារប្រកបដោយប្រសិទ្ធភាព, ប្រព័ន្ធការងារ ត្រូវមានការបែងចែកភារកិច្ចច្បាស់លាស់ មានកំណត់ការទទួលខុសត្រូវ និងជំរុញការចូលរួមផ្តល់គំនិត។ ការងារអាទិភាពដែលត្រូវយកចិត្តទុកដាក់ រួមមាន៖

### នៅថ្នាក់ក្រសួង

- ធ្វើវិចារណកម្មមុខងារអង្គភាពក្រោមឱវាទ ដោយពិនិត្យ និងកែសម្រួលឡើងវិញនូវមុខងារភារកិច្ចដែលត្រួតគ្នា
- ទំនើបកម្មប្រព័ន្ធការងារតាមបច្ចេកវិទ្យាព័ត៌មាន ដោយធ្វើសន្ទានកម្មប្រព័ន្ធដែលពាក់ព័ន្ធគ្នា និងអនុវត្តប្រព័ន្ធអ៊ីនត្រាណិតក្រសួង ឬអ៊ិនធើណិតដែលមានប្រព័ន្ធសុវត្ថិភាពសមស្រប
- ផ្តល់សិទ្ធិអំណាចជាបន្តបន្ទាប់ដល់អង្គភាពជំនាញ លើការជ្រើសរើស ចាត់ចែង និងស្នើតែងតាំងមន្ត្រីដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អង្គភាព ដើម្បីធានាគណនេយ្យភាពរបស់អង្គភាពនីមួយៗ

### នៅតាមអង្គភាព

- ពិនិត្យ កែលម្អ ឬធ្វើបច្ចុប្បន្នភាពរំហូរនីតិវីធីការងារផ្ទៃក្នុង ដែលប្រទាំងប្រទើស និងស្មុគស្មាញ ព្រមទាំងសហការគ្នាកែលម្អ សម្រួលនីតិវិធីការងារឆ្លងអង្គភាព
- ជំរុញអនុវត្តការបង្វឹក និងការណែនាំការងារដោយថ្នាក់ដឹកនាំអង្គភាព (Coaching and Mentoring) និងការបណ្តុះបណ្តាលផ្ទាល់ដោយមន្ត្រីជារៀមច្បង (On-the-job Training) ដើម្បីជំរុញឱ្យមន្ត្រីបំពេញការងារអស់សក្តានុពល
- ពិនិត្យលទ្ធភាពផ្តល់សិទ្ធិសម្រេចឱ្យបានច្រើនដល់ថ្នាក់ដឹកនាំនៅក្រោមបន្ទាប់នៅគ្រប់កម្រិត ទៅតាមសមត្ថភាព និងកម្រិតអាចទទួលខុសត្រូវបានជាក់ស្តែង ព្រោះការផ្តល់សិទ្ធិសម្រេចជាគន្លឹះជំរុញឱ្យឃើញសក្តានុពលពិតប្រាកដ។

## យុទ្ធសាស្ត្រគន្លឹះទី៣ : យន្តការស្ថាប័ននវានុវត្តន៍

បន្ថែមពីការអនុវត្តការងារទៅតាមឋានានុក្រមកំណត់ក្នុងរចនាសម្ព័ន្ធរដ្ឋបាល ការប្រើប្រាស់យន្តការស្ថាប័នដែលមានលក្ខណៈអន្តរអង្គភាព-អគ្គនាយកដ្ឋាន-នាយកដ្ឋាន ក្នុងទម្រង់ជាគណៈកម្មាធិការ គណៈកម្មការ ក្រុមការងារអចិន្ត្រៃយ៍ ឬក្រុមការងារចំពោះកិច្ចផ្សេងៗ សម្រាប់ទទួលបន្ទុកបំពេញការងារ ឬដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធអង្គភាព ឬវិស័យច្រើន, គឺជាជម្រើសយន្តការប្រកបដោយសក្តានុពល។ យន្តការស្ថាប័នដូច្នេះ មានលទ្ធភាពប្រមូលផ្តុំធនធានមានសមត្ថភាពមកពីច្រើនអង្គភាព ដែលអាចចូលរួមផ្តល់គំនិតចម្រុះ ក្នុងការបំពេញការងារ ឬដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព នវានុវត្តន៍ ដែលនឹងក្លាយជាវេទិកាដ៏កម្រសម្រាប់ឱ្យមន្ត្រីសិក្សា ចែករំលែក និងដកពិសោធន៍ពីគ្នាទៅវិញទៅមក។ ដើម្បីឱ្យយន្តការអន្តរអង្គភាពដំណើរការបានល្អ ការងារអាទិភាពដែលត្រូវយកចិត្តទុកដាក់ រួមមាន៖

- ពង្រឹងយន្តការគណៈកម្មាធិការ គណៈកម្មការ ក្រុមការងារអចិន្ត្រៃយ៍ដែលមានស្រាប់ ដោយផ្លាស់ប្តូរ ឬបន្ថែមសមាសភាពអ្នកពាក់ព័ន្ធតាមការចាំបាច់ និងជំរុញឱ្យចូលរួមមតិ និងអនុវត្តការងារពីគ្រប់សមាសភាពទាំងអស់
- លើកទឹកចិត្តឱ្យប្រើប្រាស់យន្តការអន្តរអង្គភាព ដើម្បីទទួលបន្ទុកការងារលក្ខណៈពហុវិស័យ ដោយដាក់បញ្ចូលសមាសភាពពាក់ព័ន្ធដែលមានសមត្ថភាព ប៉ុន្តែត្រូវបែងចែកភារកិច្ចឱ្យបានច្បាស់លាស់ និងមានយន្តការតាមដាន និងវាយតម្លៃ ដែលដំណើរការជាប្រចាំ និងមានប្រសិទ្ធភាព។

## យុទ្ធសាស្ត្រគន្លឹះទី៤ : ក្របខណ្ឌគតិយុត្ត និងគោលនយោបាយពេញលេញ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើបច្ចុប្បន្នភាព ឬ រៀបចំបន្ថែមឱ្យបានពេញលេញនូវក្របខណ្ឌគតិយុត្ត និងគោលនយោបាយសម្រាប់អនុវត្តផ្ទៃក្នុង ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន ដោយអនុលោមតាមបទដ្ឋានគតិយុត្ត និងគោលនយោបាយថ្នាក់ជាតិ។ ភាពពេញលេញនៃក្របខណ្ឌគតិយុត្ត និងគោលនយោបាយនឹងធានាថាការគ្រប់គ្រងមន្ត្រីមានតម្លាភាពគ្មានទំនាស់ផលប្រយោជន៍អនុលោមភាពខ្ពស់និងផ្តល់អត្ថប្រយោជន៍ផ្សេងៗជូនមន្ត្រីបានត្រឹមត្រូវដូចកំណត់ក្នុងបទដ្ឋានពាក់ព័ន្ធ។ ទាំងនេះជាកត្តាចាំបាច់ ក្នុងការកៀរគរ រក្សា និងអភិវឌ្ឍបានធនធានមនុស្សរបស់ក្រសួងប្រកបដោយប្រសិទ្ធភាព។ ការងារអាទិភាពដែលត្រូវយកចិត្តទុកដាក់ រួមមាន៖

•បច្ចុប្បន្នភាព ឬបំពេញបន្ថែមក្របខណ្ឌគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធ ឱ្យស្របតាមទិសដៅនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០

•បច្ចុប្បន្នភាពនិងអភិវឌ្ឍបន្ថែមប្រព័ន្ធគ្រប់គ្រងការងារបុគ្គលិកទាំងនៅកម្រិតក្រសួងនិងនៅតាមអង្គភាពដោយគោរពតាមអភិក្រម ៤ ត្រូវ នៃការគ្រប់គ្រងធនធានមនុស្ស គឺ "រើសត្រូវ បណ្តុះបណ្តាលត្រូវ ប្រើប្រាស់ត្រូវ និងទុកដាក់ត្រូវ" ដូចមានបរិយាយខាងលើ ដើម្បីប្រសិទ្ធភាពការងារ។

ដើម្បីវាស់វែងការសម្រេចគោលដៅនេះ **លទ្ធផលរំពឹងទុក** ត្រូវបានកំណត់ដូចតទៅ៖

១ ក្របខណ្ឌគតិយុត្ត និងគោលនយោបាយសម្រាប់អភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន គ្រប់ជ្រុងជ្រោយ និងអនុវត្តដោយប្រសិទ្ធភាព

២ ទណ្ឌកម្មវិន័យចំពោះមន្ត្រីមានតិចបំផុត ឬ គ្មាន ដោយការប្រតិបត្តិខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការ

៣ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ បំពេញការងារប្រកបដោយចំណេះដឹង និងសមត្ថភាពពេញលេញ

៤ ចំនួនស្ត្រីបម្រើការងារ និងទទួលបានការតែងតាំងក្នុងមុខតំណែងរដ្ឋបាល និងថ្នាក់ដឹកនាំក្រសួង

៥ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដំណើរការពេញលេញ

៦ ផែនការសកម្មភាព និងយន្តការស្ថាប័នទទួលបន្ទុកការងារកែទម្រង់រដ្ឋបាលសាធារណៈ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដំណើរការពេញលេញ និងអនុលោមតាមក្របខណ្ឌថ្នាក់ជាតិ

៧ ប្រព័ន្ធការងារលើកតម្កើងសមត្ថភាព និងយន្តការស្ថាប័ននវានុវត្តន៍ ក្លាយជាវប្បធម៌ការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៤.១.២ គោលដៅទី២ : ជំរុញស្មារតីសកម្ម និងបុរេសកម្ម

សមត្ថភាព និងវិជ្ជាជីវៈ ជាបុរេលក្ខខណ្ឌសម្រាប់ការបំពេញការងារ ប៉ុន្តែពុំធានាថាការងារសម្រេចលទ្ធផលទាន់ពេល និងតាមការចង់បាននោះឡើយ។ ដូចនេះ មូលធនមនុស្សប្រកបដោយសមត្ថភាព និងសក្តានុពលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវ**សកម្ម** ដោយបំពេញការងារទៅតាមមុខងារនិងភារកិច្ច ក្នុងក្របខណ្ឌនៃពេលវេលាកំណត់ជាក់លាក់ ព្រមទាំងត្រូវ**បុរេសកម្ម** ដោយមិនបង្កើតបញ្ហា មើលរំលង ឬទុកបញ្ហាឱ្យកាន់តែធំ ប៉ុន្តែថែមទាំងចេះប្រមើលមើលទុកជាមុននូវបញ្ហាប្រឈមដែលអាចកើតមានជាយថាហេតុ និងត្រៀមលក្ខណៈជានិច្ចសម្រាប់ដោះស្រាយ។ ស្មារតីសកម្ម និងបុរេសកម្ម ជាកត្តាគន្លឹះសម្រាប់ថែរក្សាសមិទ្ធផល កសាងស្នាដៃថ្មី និងធានានិរន្តរភាពរដ្ឋបាល។

ដើម្បីជំរុញស្មារតីសកម្ម និងបុរេសកម្ម, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តោតលើ៖

### យុទ្ធសាស្ត្រគន្លឹះទី១ : របៀបរបបការងារ

គ្រប់អង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំ និងពង្រឹងការបំពេញការងារ ដោយមានរបៀបរបបច្បាស់លាស់គឺ “ធ្វើផែនការ អនុវត្តផែនការ តាមដាននិងវាយតម្លៃ”។ របៀបរបបការងារច្បាស់លាស់ និងត្រឹមត្រូវ ជាឃ្នាស់គាស់មន្ត្រី និងស្ថាប័ន ឱ្យសកម្ម និងបុរេសកម្ម។ ការងារអាទិភាពដែលត្រូវយកចិត្តទុកដាក់រួមមាន៖

#### ធ្វើផែនការ

- គ្រប់អង្គភាពត្រូវស្គាល់ ឱ្យតម្លៃ និងគោរពជំនាញ មុខងារ និងភារកិច្ចរបស់ខ្លួន
- ពង្រឹងការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន វិទ្យាស្ថាន អង្គភាពចំណុះបន្តបន្ទាប់ និងក្រុមការងារផ្សេងៗ ឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនិងទិសដៅការងារបន្ថែម ដែលដាក់ចេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងថ្នាក់ដឹកនាំក្រសួង ឱ្យមានគុណភាព និងមានគម្រោងថវិកាច្បាស់លាស់
- បែងចែកភារកិច្ច និងការទទួលខុសត្រូវ ទៅតាមចង្កោម ឬផែនការងារ កំណត់ក្នុងផែនការសកម្មភាពប្រចាំឆ្នាំ

#### អនុវត្តផែនការ

- រៀបចំគម្រោងអនុវត្តផែនការសកម្មភាព តាមខែ ត្រីមាស ឆមាស ដោយគិតគូរ ចាត់ចែងស្នើសុំ ឬទូទាត់ថវិកា សម្រាប់គាំទ្រសកម្មភាពទាន់ពេល
- ថ្នាក់ដឹកនាំអង្គភាព ដែលទទួលបន្ទុកតាមចង្កោម ឬផែនការងារ ត្រូវចាត់ចែងជំរុញអនុវត្តទៅតាមផែនការដាក់ចេញ

#### តាមដាន និងវាយតម្លៃ

- ពង្រឹងការអនុវត្តរបបរាយការណ៍ និងរបបប្រជុំ ទៅតាមឋានានុក្រម និងតាមយន្តការការងារពាក់ព័ន្ធ
- ជំរុញការរាយការណ៍បញ្ហាប្រឈម និងស្នើសុំការណែនាំ កិច្ចសហការ និងអន្តរាគមន៍ដោះស្រាយពីថ្នាក់ដឹកនាំ ទៅតាមឋានានុក្រម និងនីតិវិធីរដ្ឋបាល ឱ្យបានទាន់ពេល។

## យុទ្ធសាស្ត្រគន្លឹះទី២ : វប្បធម៌ផលិតភាព គុណភាព និងប្រសិទ្ធភាព

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបណ្តុះវប្បធម៌ផលិតភាព គុណភាព និងប្រសិទ្ធភាព ក្នុងការបំពេញការងារ នៅគ្រប់កម្រិត។ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ត្រូវប្រកាន់គោលជំហរផ្តល់សេរីភាព និងភាពបត់បែនក្នុងការបំពេញការងារ ដល់ថ្នាក់ដឹកនាំបន្ទាប់ និងមន្ត្រីក្រោមឱវាទ ដោយផ្តោតសំខាន់លើលទ្ធផលការងារ ជាជាងការគ្រប់គ្រងលក្ខណៈមីក្រូ (Micro-management)។ ជាការឆ្លើយតប ថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទ ត្រូវអនុវត្តការងារទៅតាមផែនការ និងការតម្រង់ទិសពីថ្នាក់លើប្រកបដោយផលិតភាព គុណភាព និងប្រសិទ្ធភាព ដោយខិតខំប្រឹងប្រែងឱ្យអស់លទ្ធភាព ឈានទៅសម្រេចគោលដៅដាក់ចេញដោយថ្នាក់ដឹកនាំ។ ការងារអាទិភាពដែលត្រូវយកចិត្តទុកដាក់ រួមមាន៖

- ជំរុញសាកល្បងជាបណ្តើរៗនូវការរៀបចំ និងការអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម រវាងប្រធានស្ថាប័ន ប្រធានកម្មវិធី និងអង្គភាពថវិកា ក្នុងក្របខណ្ឌថវិកាកម្មវិធី
- ដាក់ឱ្យអនុវត្តក្របខណ្ឌលទ្ធផលផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងក្របខណ្ឌការងារប្រចាំថ្ងៃ
- ពង្រឹងការបែងចែកភារកិច្ច និងការអនុវត្តកិច្ចព្រមព្រៀងការងារសម្រាប់មន្ត្រីរាជការ
- បង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម
- អនុវត្តគោលការណ៍ប្រតិភូកម្មសិទ្ធិសម្រេច និងកំណត់បន្ទាត់គណនេយ្យភាពនៅតាមអង្គភាព។

## យុទ្ធសាស្ត្រគន្លឹះទី៣ : សាមគ្គីភាពផ្ទៃក្នុង

គ្រប់អង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពង្រឹងសាមគ្គីភាពផ្ទៃក្នុងរឹងមាំដោយរក្សាជំហរ **“សាមគ្គីរស់ បែកបាក់សាមគ្គីស្លាប់”**។ ថ្នាក់ដឹកនាំ ត្រូវតម្រង់ទិសអង្គភាពក្រោមការគ្រប់គ្រងរបស់ខ្លួន និងជំរុញឱ្យភាគីពាក់ព័ន្ធទាំងអស់សហការបំពេញការងារជាមួយគ្នា នៅក្នុងប្រព័ន្ធ និងពេលវេលាតែមួយ ដើម្បីយល់គ្នាច្បាស់ មានសង្គតិភាព មានកិច្ចសហការជិតស្និទ្ធ ផ្តល់ព័ត៌មាន បំពេញឱ្យគ្នាទៅវិញទៅមក ទទួលខុសត្រូវខ្ពស់ក្នុងការបំពេញមុខងាររបស់ខ្លួន ទើបអាចសម្រេចបានសហថាមភាពនៅទូទាំងក្រសួង។ ការងារអាទិភាពដែលត្រូវយកចិត្តទុកដាក់ រួមមាន៖

- ពង្រឹងយន្តការទទួលព័ត៌មានត្រឡប់ (Feedback) ការស្តាប់កង្វល់របស់ថ្នាក់ដឹកនាំ បុគ្គលិក និងមន្ត្រីក្រោមឱវាទ និងការអនុវត្តរបបប្រជុំរាយការណ៍ និងដោះស្រាយបញ្ហា
- ជំរុញតម្លាភាពក្នុងការបំពេញការងារ និងបង្កើនការចូលរួមរបស់មន្ត្រីគ្រប់រូប ទាំងក្នុងសកម្មភាពការងារ និងសកម្មភាពកំសាន្តផ្សេងៗរបស់អង្គភាពក្រៅម៉ោងការងារ ទៅតាមលទ្ធភាព
- ពង្រឹងយន្តការដោះស្រាយបញ្ហាប្រឈមឆ្លងអង្គភាព ដោយសហការគ្នាតាមខ្សែទទឹង រួចស្នើសុំកិច្ចសហការដឹកនាំដោះស្រាយពីថ្នាក់ដឹកនាំតាមខ្សែបណ្តោយនីមួយៗ
- ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ត្រូវដើរតួនាទីជាអ្នកសម្របសម្រួល ថ្លឹងថ្លែង ដោះស្រាយវិវាទដែលកើតមាន ដោយស្តាប់សម្លេងរបស់គ្រប់ភាគី ប្រកាន់ជំហរអព្យាក្រឹត និងព្យាយាមដោះស្រាយដោយសន្តិវិធី ក្នុងស្មារតីយោគយល់ ប៉ុន្តែយុត្តិធម៌។

## យុទ្ធសាស្ត្រគន្លឹះទី៤ : ហេដ្ឋារចនាសម្ព័ន្ធគាំទ្រការបំពេញការងារ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធគាំទ្រការបំពេញការងារគ្រប់គ្រាន់ និងខិតខំដំឡើងគុណភាពបន្ថែម ទៅតាមលទ្ធភាព ទាំងហេដ្ឋារចនាសម្ព័ន្ធ**រូបវ័ន្ត** ជាអាទិ៍ ទីតាំងធ្វើការ តុ កៅអី កុំព្យូទ័រ បរិយាកាសការងារ, និងហេដ្ឋារចនាសម្ព័ន្ធ**មិនមែនរូបវ័ន្ត** ជាអាទិ៍ ការគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក សម្ភារ និងបច្ចេកវិទ្យាព័ត៌មានជាដើម ដើម្បីបង្កបរិយាកាសឱ្យមន្ត្រី បំពេញការងារបានដោយរលូន។ ការងារអាទិភាពដែលត្រូវយកចិត្តទុកដាក់ រួមមាន៖

- គ្រប់អង្គភាពត្រូវពិនិត្យស្ថានភាពហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តគាំទ្រដល់ការបំពេញការងារ និងចាត់ចែងគ្រោង ស្នើសុំ និងយកមកបំពាក់ឱ្យបានសមស្រប ទៅតាមតម្រូវការជាក់ស្តែង និងលទ្ធភាពថវិកា
- គ្រប់អង្គភាពត្រូវរៀបចំយន្តការគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក សម្ភារ និងបច្ចេកវិទ្យាព័ត៌មាន ដល់បណ្តាអង្គភាព និងមន្ត្រីនៅក្រោមឱវាទ ឱ្យបានសមស្រប ប្រកបដោយភាពសាមញ្ញ ងាយស្រួល ត្រឹមត្រូវ និងទាន់ពេលវេលា និងទាន់ហេតុការណ៍ និងនវានុវត្តន៍។

## យុទ្ធសាស្ត្រគន្លឹះទី៥ : ប្រព័ន្ធលើកទឹកចិត្ត ឬចាត់វិធានការ

អង្គភាព និងមន្ត្រីសកម្ម និងបុរេសកម្មការងារ ដែលសម្រេចបានលទ្ធផលការងារសមប្រកប ស្របតាមគោលដៅកំណត់ដោយក្រសួង ត្រូវស្ថិតក្នុងអាទិភាពសម្រាប់ទទួលបានការលើកទឹកចិត្ត ដែលរួមមានទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ។ ដោយឡែក អង្គភាព និងមន្ត្រីអសកម្មក្នុងមុខងារនិងភារកិច្ចផ្ទាល់ ហើយមិនប្រកាន់យកស្មារតីបុរេសកម្ម ត្រូវស្ថិតក្រោមការពិចារណាចាត់វិធានការសមស្របទៅតាមភាពអសកម្មជាក់ស្តែងនិងការអនុញ្ញាតនៃលិខិតបទដ្ឋានគតិយុត្តជាធរមាន។ការងារអាទិភាពដែលត្រូវយកចិត្តទុកដាក់ រួមមាន៖

- កសាង និងពង្រឹងប្រព័ន្ធលើកទឹកចិត្ត ទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុសម្បូរបែប ដែលជំរុញលើកទឹកចិត្តមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ឱ្យសកម្ម និងបុរេសកម្មការងារ ដោយអនុវត្តប្រព័ន្ធនេះប្រកបដោយតម្លាភាព
- ពង្រឹងប្រព័ន្ធ និងយន្តការតាមដាននិងវាយតម្លៃសមិទ្ធកម្ម និងការផ្តល់ព័ត៌មានត្រឡប់ ដើម្បីជាមូលដ្ឋានសម្រាប់ពិចារណា និងសម្រេចចិត្តផ្តល់ការលើកទឹកចិត្ត ឬចាត់វិធានការផ្សេងៗ
- ពង្រឹងយន្តការក្រុមប្រឹក្សា គណៈកម្មការវិន័យ នៅតាមអង្គភាព និងនៅថ្នាក់ក្រសួង។

ដើម្បីវាស់វែងការសម្រេចគោលដៅនេះ **លទ្ធផលរំពឹងទុក** ត្រូវបានកំណត់ដូចតទៅ៖

១ “ការធ្វើផែនការ ការអនុវត្តផែនការ ការតាមដាននិងវាយតម្លៃ” ក្លាយជារបៀបរបបការងារនៅតាមអង្គភាពគ្រប់កម្រិត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២ វប្បធម៌ផលិតភាព គុណភាព និងប្រសិទ្ធភាពការងាររបស់ក្រសួង ត្រូវបានទទួលស្គាល់ដោយសាធារណមតិ

៣ សាមគ្គីភាពផ្ទៃក្នុង និងជវភាពនៃប្រព័ន្ធតួអង្គតែមួយ មានអត្ថិភាពជាប្រចាំ

៤ ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ត្រូវបានដំណើរការពេញលេញ

៥ អនុលោមភាព និងភាពគ្រប់ជ្រុងជ្រោយនៃប្រព័ន្ធលើកទឹកចិត្ត និងប្រព័ន្ធចាត់វិធានការផ្ទៃក្នុងក្រសួង។

### ៤.១.៣ គោលដៅទី៣ : ធានាភាពស្អាតស្អំ និងសុចរិតភាព

ភាពស្អាតស្អំ និងសុចរិតភាព ជាធាតុផ្សំចាំបាច់សម្រាប់ការកសាងស្ថាប័ននៃឧត្តមភាព។ ភាពស្អាតស្អំ ជាការបំពេញការងារ ដោយអនុលោមតាមក្របខណ្ឌគតិយុត្តជាធរមាន និងចៀសឆ្ងាយពីអំពើពុករលួយ ដូចមានកំណត់ក្នុងលិខិតបទដ្ឋានពាក់ព័ន្ធ ទាំងក្នុងការផ្តល់សេវាជូនសាធារណជន និងស្ថាប័នរដ្ឋដទៃ និងក្នុងការបំពេញការងារគាំទ្រផ្ទៃក្នុង។ សុចរិតភាព ជាការបំពេញការងារដោយសុទ្ធចិត្ត ពេញសក្តានុពល ដោយតម្កល់ឧត្តមប្រយោជន៍ជាតិ ប្រជាជន និងស្ថាប័ន និងឈរលើមូលដ្ឋាននៃគុណធម៌ សច្ចធម៌ និងភក្តីភាព។ ភាពស្អាតស្អំ និងសុចរិតភាពស្ថាប័ន ជាកត្តាជំរុញបង្កើនជំនឿទុកចិត្តរបស់សាធារណជន និងរាជរដ្ឋាភិបាលមកលើក្រសួង និងធ្វើឱ្យគុណភាពការងាររបស់ក្រសួងកាន់តែល្អប្រសើរ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកសាងវប្បធម៌ស្អាតស្អំ និងសុចរិត, ពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងលើការផ្តល់សេវា និងការបំពេញការងារ និងរៀបចំយន្តការសម្រាប់អនុវត្តការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ផ្អែកលើ **អភិក្រម ៤ ប្រការ** គឺ **"អប់រំ បង្ការ ទប់ស្កាត់ និងបង្ក្រាប"** ដើម្បីពង្រឹងស្មារតី **"មិនហ៊ាន មិនអាច និងមិនចង់ប្រព្រឹត្តអំពើពុករលួយ"**។

ដើម្បីធានាភាពស្អាតស្អំ និងសុចរិតភាព, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តោតលើ៖

#### យុទ្ធសាស្ត្រគន្លឹះទី១ : វប្បធម៌ស្អាតស្អំ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកសាង បញ្ជ្រាប និងពង្រឹងវប្បធម៌ស្អាតស្អំ ក្នុងការបំពេញការងារ ដោយបង្កើនការផ្សព្វផ្សាយទូលំទូលាយនូវក្របខណ្ឌគតិយុត្តជាធរមាន និងការយល់ដឹងផ្ទៃក្នុង, បង្កើនស្មារតីស្រឡាញ់ភាពត្រឹមត្រូវ ស្មោះត្រង់ និងភក្តីភាពចំពោះជាតិ ប្រជាជន និងស្ថាប័ន, បណ្តុះស្មារតីស្អប់ខ្ពើមអំពើពុករលួយគ្រប់ប្រភេទ, និងកសាងទម្លាប់រាយការណ៍អំពើអសកម្ម ប្រកបដោយក្រមសីលធម៌ និងស្ថិតក្រោមការការពារដោយស្ថាប័ន។ ការងារអាទិភាពដែលត្រូវយកចិត្តទុកដាក់ រួមមាន៖

- ពង្រឹងយន្តការផ្សព្វផ្សាយផ្ទៃក្នុងក្រសួង និងអង្គភាពក្រោមឱវាទ នូវលិខិតបទដ្ឋាន គោលនយោបាយដែលរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ
- រៀបចំកម្មវិធីលើកកម្ពស់ភាពស្អាតស្អំជាប្រចាំនៅកម្រិតក្រសួង និងផ្សព្វផ្សាយបន្តទៅតាមអង្គភាព
- ផ្សព្វផ្សាយជាប្រចាំនូវប្រព័ន្ធលើកទឹកចិត្តរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមួយនឹង**អភិក្រមការងារ ៤ ប្រការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ជាពិសេស **អភិក្រមទី៤ "មិនមើលរំលងកំហុសខ្លួនឯង"** និង**វិធានការ ៥ របស់រាជរដ្ឋាភិបាល** គឺ **"ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល វះកាត់"**។

#### យុទ្ធសាស្ត្រគន្លឹះទី២ : ប្រព័ន្ធការងារសុចរិត

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំប្រព័ន្ធការងារសុចរិត ដោយធានាគោលការណ៍ប្រតិគុល្យការ, ការបែងចែកភារកិច្ច និងការទទួលខុសត្រូវច្បាស់លាស់, ប្រព័ន្ធលើកទឹកចិត្ត និងការចាត់វិធានការលើភាពអសកម្ម។ ការងារអាទិភាពដែលត្រូវយកចិត្តទុកដាក់ រួមមាន៖

- ពង្រឹងការអនុវត្តគោលការណ៍ប្រតិគុល្យការ ដោយបែងចែកភារកិច្ច និងការទទួលខុសត្រូវច្បាស់លាស់ នៅគ្រប់លំដាប់ថ្នាក់, ផ្តល់ធនធានគ្រប់គ្រាន់, និងរក្សាតុល្យភាពរវាងឋានានុក្រមរដ្ឋបាល និងសមិទ្ធកម្មការងារ
- ពង្រឹងការអនុវត្តគោលការណ៍វិសមិតភាពមុខងារ ចៀសវាងទំនាស់ផលប្រយោជន៍ក្នុងការបំពេញការងារ
- រៀបចំ និងអនុវត្តក្របខណ្ឌគតិយុត្ត និងគោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF Internal Control Guideline) និងការពង្រីកបន្តទៅគ្រប់អង្គភាព
- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការអធិការកិច្ច និងសវនកម្មផ្ទៃក្នុង
- ពង្រឹងយន្តការវាយតម្លៃសមិទ្ធកម្មការងារសម្រាប់មន្ត្រី និងអង្គភាព
- ពង្រឹងយន្តការទទួលព័ត៌មានត្រឡប់ និងយន្តការទទួលពាក្យបណ្តឹង
- រៀបចំយន្តការការពារអ្នករាយការណ៍អំពីការប្រព្រឹត្តអំពើពុករលួយពិតប្រាកដ ដែលធានាសុវត្ថិភាពបុគ្គល។

## យុទ្ធសាស្ត្រគន្លឹះទី៣ ៖ សេវាស្អាតស្អំ

អង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តល់សេវាដល់សាធារណជន និងស្ថាប័នរដ្ឋដទៃ ដោយភាពត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិជាធរមាន និងគោរពក្រមសីលធម៌វិជ្ជាជីវៈខ្ពស់។ ការផ្តល់សេវាបានល្អ និងគោរពតាមនិយាមស្អាតស្អំ ត្រឹមត្រូវ នឹងត្រូវបានលើកទឹកចិត្ត រីឯការអនុវត្តមិនត្រឹមត្រូវ នឹងត្រូវរងវិធានការសមស្រប។ ការងារអាទិភាពដែលត្រូវយកចិត្តទុកដាក់ រួមមាន៖

- រៀបចំ ដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយឱ្យទូលាយ នូវក្របខណ្ឌគតិយុត្ត និងគោលការណ៍ណែនាំផ្សេងៗពាក់ព័ន្ធនឹង ការផ្តល់សេវារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមគ្រប់អង្គភាពផ្តល់សេវា ទាំងសម្រាប់សេវាសាធារណៈ និងសេវាសម្រាប់ស្ថាប័នរដ្ឋដទៃ
- ពង្រឹងយន្តការផ្តល់សេវាដែលប្រមូលផ្តុំ នៅច្រកចេញចូលតែមួយ, កាត់បន្ថយការកាន់ឯកសារចរាចរផ្ទាល់ដោយអ្នកស្នើសុំសេវា, និងពង្រីកការផ្តល់សេវា និងការទូទាត់កម្រៃសេវាតាមប្រព័ន្ធឌីជីថល
- ពង្រឹងយន្តការទទួលព័ត៌មានត្រឡប់ និងយន្តការទទួលពាក្យបណ្តឹង
- ពង្រឹងរបបចុះត្រួតពិនិត្យជាប្រចាំ និងដោយមិនជូនដំណឹងជាមុន នៅតាមទីតាំងផ្តល់សេវា និងចាត់វិធានការទៅតាមកម្រិតនៃភាពអសកម្ម
- រៀបចំ និងពង្រឹងការវាយតម្លៃ និងទទួលស្គាល់អ្នកដឹកនាំគំរូ និងអង្គភាពផ្តល់សេវាសាធារណៈគំរូ ប្រចាំក្រសួង និងការអនុវត្តការលើកទឹកចិត្តបន្ថែមផ្អែកលើគុណភាពនៃការផ្តល់សេវា។

## យុទ្ធសាស្ត្រគន្លឹះទី៤ ៖ ការងារសុចរិត

អង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបំពេញការងារដោយសុទ្ធចិត្ត ខិតខំប្រឹងប្រែងធ្វើឱ្យអស់ពីលទ្ធភាព ដោយអនុលោមតាមក្របខណ្ឌគតិយុត្តជាធរមាន ក្នុងបុព្វហេតុជាតិ ប្រជាជន និងស្ថាប័ន។ ការប្រើប្រាស់ពេលវេលារដ្ឋបាលទៅប្រកបរបរផ្សេង ការកេងប្រវ័ញ្ចទ្រព្យសម្បត្តិរបស់រដ្ឋ ការបំពេញការងារឱ្យរួចពីដៃ មិនពេញលេញ មិនគ្រប់ជ្រុងជ្រោយ និងធ្វើឡើងដោយមានទំនាស់ផលប្រយោជន៍ជាដើម ត្រូវចាត់ទុកថាជាការបំពេញការងារមិនសុចរិត។ ការងារអាទិភាពដែលត្រូវយកចិត្តទុកដាក់រួមមាន៖

- ពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការ
- បង្កើតកិច្ចព្រមព្រៀងសុចរិតភាព សម្រាប់បុគ្គលិក និងមន្ត្រីថ្មី ដែលចូលបម្រើការងារក្នុងក្រសួង
- ពង្រឹងការអនុវត្តប្រព័ន្ធថវិកាសមិទ្ធិកម្ម និងការអនុវត្តការងារ និងការលើកទឹកចិត្តផ្អែកលើលទ្ធផល
- ពង្រឹងយន្តការត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មមន្ត្រី
- ពង្រឹងការអនុវត្តវិធានការវិន័យ តាមការចាំបាច់។

ដើម្បីវាស់វែងការសម្រេចគោលដៅនេះ **លទ្ធផលរំពឹងទុក** ត្រូវបានកំណត់ដូចតទៅ៖

១ បទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំផ្ទៃក្នុងពាក់ព័ន្ធ ត្រូវបានរៀបចំរួចរាល់ និងដំណើរការពេញលេញ

២ បុគ្គលិក មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនមានកំហុសពាក់ព័ន្ធនឹងអំពើពុករលួយ

៣ យន្តការទទួលព័ត៌មានត្រឡប់ និងដោះស្រាយបណ្តឹង ត្រូវបានដាក់ឱ្យប្រើប្រាស់តាមរយៈប្រព័ន្ធព័ត៌មានវិទ្យា ដោយចំនួនបណ្តឹងតវ៉ាមានការថយចុះ ឬ គ្មាន

៤ ធានាភាពពេញចិត្តរបស់សាធារណជន និងស្ថាប័នរដ្ឋផ្សេងៗ ចំពោះការផ្តល់សេវារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៥ ប្រព័ន្ធថវិកាសមិទ្ធកម្ម ពិសេសកិច្ចព្រមព្រៀងសមិទ្ធកម្ម ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។

## ៤.២ គោលបំណងទី២ : ប្រសិទ្ធភាពនៃការអនុវត្តមុខងារនិងភារកិច្ច

គោលបំណងទី២ នៃក្របខណ្ឌយុទ្ធសាស្ត្រ ផ្តោតលើការអនុវត្តមុខងារនិងភារកិច្ចដែលកំណត់ក្នុងបេសកកម្មស្នូល និងបេសកកម្មពាក់ព័ន្ធរបស់ក្រសួង ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ការសម្រេចគោលបំណងទី១ នៃក្របខណ្ឌយុទ្ធសាស្ត្រ ដែលផ្តោតលើសមត្ថភាពស្ថាប័នផ្ទៃក្នុងក្រសួង ជាបុរេលក្ខខណ្ឌសម្រាប់ធានាថាក្រសួងមានសមត្ថភាព និងគុណវុឌ្ឍិសមស្រប ដើម្បីបំពេញមុខងារ ភារកិច្ចស្នូល និងបេសកកម្មដោយឡែកផ្សេងៗ ដែលច្បាប់ និងរាជរដ្ឋាភិបាលប្រគល់ឱ្យ, និងឈានទៅសម្រេចគោលបំណងទី២។ ក្នុងន័យនេះ គោលបំណងទាំង២ នៃក្របខណ្ឌយុទ្ធសាស្ត្រ ត្រូវបានរៀបចំឡើងដោយឆ្លើយឆ្លងគ្នាទៅវិញទៅមក ប្រកបដោយវិចារណកម្មច្បាស់លាស់ សម្រាប់គាំទ្រការសម្រេចកម្មវត្ថុនៃចក្ខុវិស័យក្រសួង។

គោលបំណងទី២ នៃក្របខណ្ឌយុទ្ធសាស្ត្រ ប្រមូលផ្តុំបណ្តាក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹងបេសកកម្មស្នូលរបស់ក្រសួង និងបេសកកម្មពាក់ព័ន្ធផ្សេងៗក្នុងនាមរាជរដ្ឋាភិបាល, មកដាក់បញ្ចូលគ្នានៅក្នុងឯកសារយុទ្ធសាស្ត្រតែមួយ។ ការរៀបចំបែបនេះ មានភាពចាំបាច់ មិនអាចខ្វះបាន ក្នុងការធានាប្រសិទ្ធភាពការងាររបស់ក្រសួងទៅតាមការកំណត់នៃច្បាប់ និងរាជរដ្ឋាភិបាល។ លក្ខណវិនិច្ឆ័យនៃប្រសិទ្ធភាពការងារនេះ ត្រូវបានកំណត់ទៅតាមវិសេសភាពនៃបេសកកម្មនីមួយៗ ដោយចែកចេញជាគោលដៅចំនួន ៤ ដូចតទៅ៖

### ៤.២.១ គោលដៅទី១ : បង្កើនភាពធន់នៃមូលដ្ឋានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ

ស្របតាមទិសដៅយុទ្ធសាស្ត្រកំណត់ដោយរាជរដ្ឋាភិបាល និងស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវជំរុញការកសាងមូលដ្ឋានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិឱ្យមានភាពធន់ រឹងមាំ ចីរភាព (រួមទាំងចីរភាពបរិស្ថាន និងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ) ផលិតភាព និងភាពប្រកួតប្រជែងខ្ពស់ ឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងភ្ជាប់ជាប់នូវកាលានុវត្តភាពដែលកើតចេញមកពីការវិវត្តប្រែប្រួលនៃសភាពការណ៍តំបន់-សកល រួមទាំងបរិវត្តកម្មបច្ចេកវិទ្យាឌីជីថល។ គន្លឹះនៃការសម្រេចគោលដៅនេះ ស្ថិតនៅលើការបំពេញមុខងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជា**និម្មាបនករ (Architect)** ក្នុងកម្រិតគោលនយោបាយ និងយុទ្ធសាស្ត្រ ដែលសំដៅនាំមុខ តម្រង់ទិស **ជាស្ថាប័នជំរុញសហថាមភាព** (Synergy driver institution) រវាងក្រសួង ស្ថាប័ន អង្គភាពរបស់រដ្ឋ និងភាគីពាក់ព័ន្ធផ្សេងៗ ឱ្យស្ថិតក្នុង **"ធរភាពនៃប្រព័ន្ធតួអង្គតែមួយ"**[៨]។

ដើម្បីបង្កើនភាពធន់នៃមូលដ្ឋានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តោតលើ៖

**យុទ្ធសាស្ត្រគន្លឹះទី១ : ចីរភាពនៃកំណើន**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសម្របសម្រួល ដឹកនាំ ជំរុញ រៀបចំគោលនយោបាយ ដើម្បីចីរភាពនៃកំណើន និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, បុរេសកម្មលើការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច ដោយប្រយ័ត្នប្រយែង, បង្កើនភាពប្រទាក់ក្រឡា គ្រប់ជ្រុងជ្រោយ និងសង្គតិភាពនៃក្របខណ្ឌគោលនយោបាយលើវិស័យសំខាន់ៗ, កាត់បន្ថយគម្លាតរវាងផែនការដាក់ចេញ និងការអនុវត្តជាក់ស្តែង, រៀបចំយន្តការគ្រប់គ្រងវិបត្តិ និងហានិភ័យផ្នែកសេដ្ឋកិច្ចហិរញ្ញវត្ថុ អចលនទ្រព្យ និងវិស័យដទៃផ្សេងទៀត, ពង្រឹងសមត្ថភាពស្ថាប័ន និងប្រសិទ្ធភាពនៃកិច្ចសម្របសម្រួលអន្តរស្ថាប័ន, បង្កើត និងបង្កើនបរិយាកាសអំណោយផលសម្រាប់ធុរកិច្ច វិនិយោគ និងការអភិវឌ្ឍ, កែទម្រង់ប្រព័ន្ធពន្ធដារ, រៀបចំ និងអនុវត្តយន្តការសម្រួលដល់ការបង្កើតធុរកិច្ចថ្មី, ជំរុញ និងលើកកម្ពស់ការធ្វើពាណិជ្ជកម្មប្រកបដោយតម្លាភាព គណនេយ្យភាព និងអភិបាលកិច្ចល្អ, លើកកម្ពស់សមភាពយេនឌ័រក្នុងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងពង្រឹងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

**យុទ្ធសាស្ត្រគន្លឹះទី២ : ពិពិធកម្មសេដ្ឋកិច្ច**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសម្របសម្រួល ចូលរួមដឹកនាំ ជំរុញ រៀបចំគោលនយោបាយពិពិធកម្មសេដ្ឋកិច្ច ផ្តោតលើនាំចេញ តាមរយៈការស្វែងរកប្រភពនៃកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ ផ្អែកលើក្របខណ្ឌរួមនៃគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម, រៀបចំ និងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រកែលម្អប្រព័ន្ធឡូជីស្ទីក និងលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល ដើម្បីតភ្ជាប់នៅតាមប៉ូលសេដ្ឋកិច្ចសំខាន់ៗ, និងបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យមានស្ថិរភាព កាន់តែមានពិពិធភាព រឹងមាំ ធន់នឹងវិបត្តិ និងមានបរិយាបន្ន។

[៨] ការសម្របសម្រួលគ្នាបានជាប្រព័ន្ធតួអង្គតែមួយ គឺនៅពេលដែលក្រសួង-ស្ថាប័នទាំងអស់មិនត្រឹមតែបំពេញតួនាទីរៀងៗខ្លួន ដោយមិនប្រកាន់គ្នាទៅវិញទៅមកប៉ុណ្ណោះទេ, ប៉ុន្តែថែមទាំងសម្របសម្រួល និងសហការជិតស្និទ ដើម្បីសម្រេចនូវបេសកកម្ម គោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងឆ្លើយតបទៅនឹងកង្វល់ ឬសំណូមពររបស់ប្រជាជនបានដោយប្រសិទ្ធភាពទៀតផង (ប្រភព៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤)។

**យុទ្ធសាស្ត្រគន្លឹះទី៣ : វិស័យឯកជន និងការងារ**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសម្របសម្រួល ដឹកនាំ ជំរុញ រៀបចំគោលនយោបាយលើកស្ទួយវិស័យឯកជន និងការងារ ដែលមានតួនាទីគន្លឹះក្នុងការជំរុញកំណើន និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងនោះ ត្រូវផ្តោតលើការរៀបចំ និងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍទីផ្សារការងារ, លើកស្ទួយសហគ្រាសធុនតូច មធ្យម និងសហគ្រិនភាព, ធ្វើសាមញ្ញកម្មសេវារដ្ឋបាល ស្វ័យប្រវត្តិ និងយន្តការលើកទឹកចិត្ត, បង្កើតចង្កោមសហគ្រាសធុនតូច និងមធ្យម (SME Cluster), លើកកម្ពស់នវានុវត្តន៍ និងផ្តល់ប្រកាសនីយបត្រតក្កកម្ម (Patents), អភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន និងពង្រឹងការប្រកួតប្រជែងដោយយុត្តិធម៌។

**យុទ្ធសាស្ត្រគន្លឹះទី៤ : ភាពជាម្ចាស់ និងភាពជាដៃគូ ក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសម្របសម្រួល ដឹកនាំ ជំរុញ រៀបចំគោលនយោបាយបង្កើនភាពជាម្ចាស់ និងភាពជាដៃគូ ក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ ទាំងជាមួយដៃគូសន្ទនាគោលនយោបាយ ដៃគូអភិវឌ្ឍផ្លូវការ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ដោយពង្រឹងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំក្នុងការកៀរគរធនធានហិរញ្ញប្បទានពីគ្រប់ប្រភព ឈរលើគោលការណ៍ភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់ស្ថាប័នរដ្ឋ, ចូលរួមយ៉ាងសកម្មក្នុងកិច្ចការតំបន់ និងពិភពលោក ដើម្បីបង្កើតកាលានុវត្តភាព, អនុវត្តការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងវេទិកាអន្តរជាតិ ព្រមទាំងបង្កើតយន្តការសហប្រតិបត្តិការអន្តរជាតិថ្មីៗដើម្បីទាក់ទាញវិនិយោគបន្ថែមទៀត ជាពិសេសការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ពហុភាគី និងគំនិតផ្តួចផ្តើមផ្នែកសមាហរណកម្មសេដ្ឋកិច្ច នៅថ្នាក់តំបន់។

### ៤.២.២ គោលដៅទី២ : ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងទ្រព្យសម្បត្តិរដ្ឋឆ្ពោះទៅឧត្តមានុវត្តន៍

ស្របតាមទិសដៅយុទ្ធសាស្ត្រកំណត់ដោយរាជរដ្ឋាភិបាល, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកសាង ធ្វើទំនើបកម្ម និងគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ជាតិ ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព ឈានឆ្ពោះទៅលទ្ធផលចុងក្រោយជាឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Fiscal outcomes) រួមមាន៖ (១) បូរណភាពនៃការគោរពវិន័យថវិកា (២) ប្រសិទ្ធភាពថវិកា ទាំងការវិភាជ និងប្រតិបត្តិការ និង (៣) ស័ក្តិសិទ្ធភាពនៃដំណើរការរដ្ឋបាល និងការផ្តល់សេវាសាធារណៈរបស់រដ្ឋ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តកសាង និងពង្រឹងខឿនទាំង៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាកម្មវិធីកែទម្រង់អភិបាលកិច្ចហិរញ្ញវត្ថុសាធារណៈគ្រប់ជ្រុងជ្រោយ និងកំពុងដំណើរការស្រាប់ ព្រមទាំងត្រូវប្រែក្លាយសមិទ្ធផលនៃការងារកែទម្រង់ដែលសម្រេចបានក្នុងដំណាក់កាលកន្លងមកឱ្យទៅជាការងារប្រចាំថ្ងៃ ដែលត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននៅក្នុងប្រព័ន្ធថ្មី។

ដើម្បីសម្រេចទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងទ្រព្យសម្បត្តិរដ្ឋឆ្ពោះទៅឧត្តមានុវត្តន៍, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តោតលើ៖

**យុទ្ធសាស្ត្រគន្លឹះទី១ : ចីរភាពនៃភាពជឿទុកចិត្តនៃថវិកា**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធានាចីរភាពនៃភាពជឿទុកចិត្តបាននៃថវិកា តាមរយៈការពង្រឹងមូលដ្ឋានគ្រឹះដែលបានកសាងនាពេលកន្លងមក លើទិដ្ឋភាពនៃការប្រមូលនិងគ្រប់គ្រងចំណូល ការគ្រប់គ្រងបំណុលសាធារណៈ និងការកែលម្អការអនុវត្តថវិកា រួចឈានទៅកសាងមូលដ្ឋានកំណត់ក្នុងដំណាក់កាលបន្តបន្ទាប់ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផ្តោតលើភាពអាចប៉ាន់ប្រមាណបាននៃចំណូល និងចំណាយថវិកា, ក្នុងនោះត្រូវយកចិត្តទុកដាក់ពង្រឹង កែលម្អ និងទំនើបកម្មរដ្ឋបាលចំណូល, ធ្វើពិពិធកម្មប្រភពចំណូល ទាំងសារពើពន្ធ និងមិនមែនសារពើពន្ធ, ជំរុញអនុវត្តបណ្តាវិធានការកំណត់ក្នុងយុទ្ធសាស្ត្រកៀរគរចំណូល (RMS), ពង្រឹងការអនុវត្តថវិកាទៅតាមកម្មវិធីចំណូល-ចំណាយ និងផែនការសាច់ប្រាក់, កែលម្អនីតិវិធីអនុវត្តថវិកា រួមមាន កែលម្អដំណើរការអនុវត្ត និងទូទាត់ចំណាយ, អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់លទ្ធកម្មសាធារណៈ និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ។

## យុទ្ធសាស្ត្រគន្លឹះទី២ : គណនេយ្យភាពហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ដោយផ្តោតលើការពង្រីកស្វ័យប្រវត្តិកម្មដំណើរការថវិកា និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ការធានាភាពជឿទុកចិត្ត សុក្រឹតភាព និងភាពទាន់ពេលនៃទិន្នន័យ, និងការពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ឈរលើមូលដ្ឋានគ្រឹះដែលបានកសាងនៅដំណាក់កាលមុនៗនៃកម្មវិធីកែទម្រង់, ក្នុងនោះ ត្រូវយកចិត្តទុកដាក់ពង្រឹងនិងពង្រីកការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ពេញលេញ និងការធ្វើសន្ទានកម្មជាមួយប្រព័ន្ធពាក់ព័ន្ធដទៃទៀត, ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី, ពង្រឹងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (Financial Asset និង Non-Financial Asset), ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ រួមទាំងហានិភ័យនៃកាតព្វកិច្ចបំណុលយថាហេតុ និងហានិភ័យបំណុលពាក់ព័ន្ធ, និងពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុនៅគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ។

## យុទ្ធសាស្ត្រគន្លឹះទី៣ : ប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវជំរុញបង្កើនប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដោយផ្តោតលើក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ និងថវិការយៈពេលមធ្យម, គុណភាពនៃថវិកាកម្មវិធី ការគ្រប់គ្រងកម្មវិធី ការរៀបចំ និងផ្តល់សិទ្ធិអំណាចដល់អង្គភាពថវិកា និងគុណភាពសូចនាករ, ភាពគ្រប់ជ្រុងជ្រោយ និងសមាហរណកម្មថវិកា។ មូលដ្ឋានសំខាន់ និងចាំបាច់សម្រាប់យុទ្ធសាស្ត្រនេះ គឺការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ សម្រាប់បើកផ្លូវឱ្យមានការផ្លាស់ប្តូរពីប្រព័ន្ធគ្រប់គ្រងផ្អែកលើធាតុចូលនិងមធ្យោបាយ ឆ្ពោះទៅជាប្រព័ន្ធផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ ព្រមទាំងការរៀបចំក្របខណ្ឌគតិយុត្តពាក់ព័ន្ធជាច្រើនទៀតសម្រាប់អនុវត្តច្បាប់នេះ។ ក្នុងនោះ ត្រូវយកចិត្តទុកដាក់កែសម្រួល និង/ឬរៀបចំបន្ថែមក្របខណ្ឌគតិយុត្តសម្រាប់អនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី, កែលម្អគុណភាពព្យាករម៉ាក្រូសេដ្ឋកិច្ច ធ្វើស្ថាប័នូបនីយកម្មក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ និងថវិការយៈពេលមធ្យម និងពង្រឹងការរៀបចំស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS) ពេញលេញ, ពង្រឹងការគ្រប់គ្រងការវិនិយោគសាធារណៈ, បន្តពង្រឹងការរៀបចំ និងការអនុវត្តថវិកាកម្មវិធី ដោយផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រថវិកា, បែងចែកចំណាយទៅតាមកម្មវិធី, បន្តគិតគូរអំពីថវិកាឆ្លើយតបនឹងយេនឌ័រ, រៀបចំនិងផ្តល់សិទ្ធិអំណាចដល់អង្គភាពថវិកា និងកំណត់បន្ទាត់គណនេយ្យភាពតាមរចនាសម្ព័ន្ធកម្មវិធី, ជំរុញវិមជ្ឈការហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យស្ថិតក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈតែមួយ និងពង្រឹងការអនុវត្តថវិកាក្នុងក្របខណ្ឌផ្ទេរមុខងារ និងធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ជាមួយនឹងការពង្រឹងសវនកម្មផ្ទៃក្នុងនៅថ្នាក់ក្រោមជាតិ។

## យុទ្ធសាស្ត្រគន្លឹះទី៤ : គណនេយ្យភាពសមិទ្ធកម្ម

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកសាងនិងពង្រឹងគណនេយ្យភាពសមិទ្ធកម្មក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផ្តោតលើសមិទ្ធកម្ម គណនេយ្យភាព និងតម្លាភាព ទាំងផ្ទៃក្នុង និងផ្ទៃក្រៅ, ក្នុងនោះ ត្រូវយកចិត្តទុកដាក់លើការដាក់ឱ្យអនុវត្តពេញលេញនូវ “ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម” ជាដំណាក់កាលៗ គាំទ្រដោយក្របខណ្ឌគតិយុត្ត និងឧបករណ៍អនុវត្តផ្សេងៗ ជាពិសេស កិច្ចព្រមព្រៀងសមិទ្ធកម្ម, ការដាក់ឱ្យអនុវត្តប្រព័ន្ធតាមដាននិងត្រួតពិនិត្យសមិទ្ធកម្មតាមក្រសួង ស្ថាប័ន រួមមានផែនការប្រតិបត្តិថវិកា យន្តការ និងផែនការតាមដាននិងត្រួតពិនិត្យសមិទ្ធកម្ម, ការពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងផ្ទៃក្រៅ រួមមានសវនកម្មផ្ទៃក្នុង អធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្មឯករាជ្យ ដោយអនុវត្តសវនកម្មពេញលេញ លើទិដ្ឋភាពសមិទ្ធកម្ម បច្ចេកវិទ្យាព័ត៌មាន អនុលោមភាព និងហិរញ្ញវត្ថុ, និងការលើកកម្ពស់តម្លាភាពថវិកាផ្អែកតាមស្តង់ដារអន្តរជាតិ ភាពគ្រប់ជ្រុងជ្រោយនៃឯកសារថវិកា និងភាពទាន់ពេលនៃការផ្សព្វផ្សាយជាសាធារណៈ រួមទាំងការបន្តរៀបចំវេទិកាសាធារណៈពាក់ព័ន្ធ។

### យុទ្ធសាស្ត្រគន្លឹះទី៥ : ចលនការនៃការកែទម្រង់ និងប្រសិទ្ធភាពគ្រប់គ្រងប្រព័ន្ធ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរក្សា និងជំរុញបង្កើតបន្ថែមនូវឆន្ទៈ ស្មារតី និងសមិទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមដំណាក់កាលកន្លងមក, បង្កើនសង្គតិភាព និងភាពប្រទាក់ក្រឡាជាមួយការដ្ឋានកែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល, និងបន្តគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ ឆ្ពោះទៅសម្រេចលទ្ធផលចុងក្រោយទាំង៣ ដែលជាឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងនោះ ត្រូវយកចិត្តទុកដាក់ បង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង ឆន្ទៈ ភាពជាម្ចាស់ និងការទទួលខុសត្រូវ ទាំងសម្រាប់ការបំពេញមុខងារស្នូលប្រចាំថ្ងៃ និងការងារកែទម្រង់ នៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្ទាល់, រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌគ្រប់គ្រងផ្អែកលើលទ្ធផល និងវិធានការលើកទឹកចិត្ត ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្នុងក្របខណ្ឌផ្ទៃក្នុងក្រសួង, ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរការដ្ឋានកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស ជាមួយកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការដ្ឋានកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌, និងបន្តគ្រប់គ្រងឱ្យបានត្រឹមត្រូវ ពេញលេញ ស្របតាមក្របខណ្ឌគតិយុត្ត និងបន្តអភិវឌ្ឍ ឬកែលម្អទៅតាមឧត្តមានុវត្តន៍ថ្មីៗ នូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលកំពុងកសាងជាបណ្តើរៗ តាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ៤.២.៣ គោលដៅទី៣ : ចូលរួមកសាងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈជាប្រព័ន្ធនិងគ្រប់ជ្រុងជ្រោយ

ស្របតាមទិសដៅយុទ្ធសាស្ត្រកំណត់ដោយរាជរដ្ឋាភិបាល និងស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចូលរួមសម្របសម្រួល ដឹកនាំ និងជំរុញការកសាងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈជាប្រព័ន្ធនិងគ្រប់ជ្រុងជ្រោយ ប្រមូលផ្តុំ សង្គតិភាព និងមានវិសាលភាពគ្របដណ្តប់ទាំងវិស័យសាធារណៈ និងឯកជន ទៅតាម**គោលការណ៍ ៤ យ៉ាង** គឺ **អភិបាលកិច្ចល្អ ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពចំណាយ ការទទួលខុសត្រូវ និងចីរភាពហិរញ្ញវត្ថុ**។ ប្រព័ន្ធគាំពារសង្គម ត្រូវឈរលើសសរស្តម្ភចំនួន ២ គឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម, ដើម្បីធានាសន្តិសុខប្រាក់ចំណូលប្រជាពលរដ្ឋ ចូលរួមកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាពសង្គម ព្រមទាំងរួមចំណែកដល់ការគាំពារ និងអភិវឌ្ឍធនធានមនុស្សឱ្យកាន់តែទូលំទូលាយ និងជំរុញចីរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង។

ដើម្បីកសាងប្រព័ន្ធគាំពារសង្គមមានលក្ខណៈជាប្រព័ន្ធនិងគ្រប់ជ្រុងជ្រោយ,ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវផ្តោតលើ៖

### យុទ្ធសាស្ត្រគន្លឹះទី១ : អភិបាលកិច្ចល្អ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈយន្តការស្ថាប័នដែលមានស្រាប់ រួមមាន៖ ក្រុមប្រឹក្សាជាតិគាំពារសង្គម និងគណៈកម្មាធិការប្រតិបត្តិ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម អគ្គនាយកដ្ឋានថវិកា និយ័តករសន្តិសុខសង្គម និងអង្គភាពពាក់ព័ន្ធ, ត្រូវសម្របសម្រួល ជំរុញពង្រឹងអភិបាលកិច្ចល្អនៅក្នុងប្រព័ន្ធគាំពារសង្គមទាំងមូល ដោយចូលរួមធានាការប្រមូលផ្តុំ ការពិនិត្យជារួម និងការសម្របសម្រួលឆ្លងវិស័យ ឬរបប ទាំងក្នុងកម្រិតគោលនយោបាយនិយ័តករនិងប្រតិបត្តិករ,ធ្វើសមាហរណកម្មនិងកំណត់ឱ្យមានប្រព័ន្ធអភិបាលកិច្ចប្រកបដោយគណនេយ្យភាពនៅស្ថាប័នប្រតិបត្តិករសន្តិសុខសង្គម, លើកទឹកចិត្តការចូលរួមពីអ្នកពាក់ព័ន្ធ, និងអនុវត្តយន្តការតាមដាននិងវាយតម្លៃប្រព័ន្ធគាំពារសង្គមឱ្យបានហ្មត់ចត់ តឹងរឹង និងទៀងទាត់ ប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។

### យុទ្ធសាស្ត្រគន្លឹះទី២ : ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃចំណាយ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសម្របសម្រួល ដឹកនាំ និងជំរុញការប្រកាន់ខ្ជាប់គោលការណ៍ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃចំណាយ នៅក្នុងប្រព័ន្ធគាំពារសង្គម ដោយផ្តោតលើការកំណត់ក្រុមគោលដៅ និងវិធានការអន្តរាគមន៍ជំនួយសង្គមសាមញ្ញ ច្បាស់លាស់ និងត្រឹមត្រូវ ផ្អែកលើការសិក្សានិងវាយតម្លៃសមស្រប, កាត់បន្ថយលទ្ធភាពដែលបុគ្គលម្នាក់អាចស្ថិតក្នុងកម្មវិធីច្រើនត្រួតគ្នា, ការប្រមូលផ្តុំធនធានហិរញ្ញវត្ថុ និងការកាត់បន្ថយចំណាយប្រតិបត្តិការ, ការធ្វើសម្បទានឆ្លងរបបក្នុងប្រព័ន្ធសន្តិសុខសង្គម, ការវិនិយោគអតិរេកត្រឹមត្រូវ, និងការធ្វើសន្ទានកម្មឬសមាហរណកម្មប្រព័ន្ធចុះបញ្ជីរវាងប្រព័ន្ធអត្តសញ្ញាណកម្មប្រជាជនទូទៅ ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ប្រព័ន្ធបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) និងប្រព័ន្ធពាក់ព័ន្ធដទៃទៀត។

### យុទ្ធសាស្ត្រគន្លឹះទី៣ : ការទទួលខុសត្រូវ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសម្របសម្រួល និងជំរុញដំណើរការនៃប្រព័ន្ធគាំពារសង្គម ឱ្យមានការទទួលខុសត្រូវច្បាស់លាស់ ទៅតាមរចនាសម្ព័ន្ធ និងមុខងារនិងភារកិច្ចនៃស្ថាប័នពាក់ព័ន្ធ ស្របតាមក្របខណ្ឌគតិយុត្ត, ការអនុវត្តក្របខណ្ឌគោលនយោបាយពេញលេញ, ធានាតម្លាភាព និងគណនេយ្យភាពនៃការចុះបញ្ជី ការស្នើសុំអត្ថប្រយោជន៍ និងការបើកផ្ដល់/ទទួលតារកាលិក, ជំរុញការអប់រំ និងការផ្សព្វផ្សាយដោយប្រមូលផ្ដុំរួមគ្នា តាមមធ្យោបាយសម្បូរបែប និងទូលំទូលាយ, និងពង្រឹងយន្តការផ្ដល់ការគាំទ្រ យន្តការទទួលព័ត៌មានត្រឡប់ និងយន្តការដោះស្រាយបណ្ដឹងតវ៉ា ជាច្រកចេញចូលតែមួយ ឬ ជាប្រព័ន្ធឌីជីថល។

### យុទ្ធសាស្ត្រគន្លឹះទី៤ : ចីរភាពហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសម្របសម្រួល និងជំរុញការយកចិត្តទុកដាក់លើចីរភាពហិរញ្ញវត្ថុនៃប្រព័ន្ធគាំពារសង្គមទាំងមូល ដោយតម្រូវឱ្យគិតគូរហ្មត់ចត់អំពីបន្ទុកថវិកាសម្រាប់គោលនយោបាយគាំពារសង្គមទាំងអស់, ពិនិត្យជាប្រចាំនូវលទ្ធភាពថវិកា, និងជំរុញប្រមូលផ្ដុំគ្រប់ប្រភពធនធាន ទាំងការគាំទ្រដោយថវិការដ្ឋ និងភាគទានរបស់និយោជក-និយោជិត, ក្នុងនោះ ត្រូវយកចិត្តទុកដាក់លើថវិកាវិភាជសម្រាប់វិស័យសង្គមកិច្ចជារួម និងកិច្ចគាំពារសង្គមប្រចាំឆ្នាំ, វិនិយោគអតិរេកមូលនិធិ, បរិស្ថានវិនិយោគ ការសម្រួលនិងជំរុញសញ្ញ័យហិរញ្ញវត្ថុ ដែលដើរតួជាប្រភពហិរញ្ញប្បទានរយៈពេលវែង, និងការចូលរួមរបស់គ្រប់តួអង្គសេដ្ឋកិច្ចក្នុងរបបសន្តិសុខសង្គម និងការបង់ភាគទានតាមគោលការណ៍កំណត់។

### ៤.២.៤ គោលដៅទី៤ : ចូលរួមជំរុញបរិវត្តកម្មឌីជីថល កសាងសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា

ស្របតាមទិសដៅយុទ្ធសាស្ត្រកំណត់ដោយរាជរដ្ឋាភិបាល និងស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចូលរួមសម្របសម្រួល និងជំរុញការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា ស្របតាម**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** ដែលបានកំណត់គោលបំណងកសាង “សេដ្ឋកិច្ច និង ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម” តាមរយៈការធ្វើបរិវត្តកម្មឌីជីថលនៅគ្រប់វិស័យ ព្រមទាំងក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រផ្សេងៗពាក់ព័ន្ធនឹងសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវដើរតួនាទីជាចំណែកមួយដ៏សំខាន់ ក្នុងការចូលរួមសម្របសម្រួល ដឹកនាំ តម្រង់ទិសគោលនយោបាយ និងយុទ្ធសាស្ត្រ, វិភាជថវិកាគាំទ្រដំណើរការបរិវត្តកម្មឌីជីថល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ព្រមទាំងសម្របសម្រួលការអនុវត្ត និងតាមដាននិងវាយតម្លៃការអនុវត្តក្របខណ្ឌគោលនយោបាយនេះ ទៅតាមយន្តការស្ថាប័នដែលបានកំណត់។

ដើម្បីជំរុញបរិវត្តកម្មឌីជីថល កសាងសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្ដោតលើការជំរុញកសាងគ្រឹះចំនួន ២ គឺ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងទំនុកចិត្តនិងភាពជឿជាក់លើប្រព័ន្ធឌីជីថល, និងសសរស្ដម្ភចំនួន ៣ គឺ ពលរដ្ឋឌីជីថល រដ្ឋាភិបាលឌីជីថល និងធុរកិច្ចឌីជីថល ដូចតទៅ៖

### យុទ្ធសាស្ត្រគន្លឹះទី១ : ហេដ្ឋារចនាសម្ព័ន្ធឌីជីថល

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចូលរួមចំណែកសម្របសម្រួលលើការពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធសម្រាប់ទ្រទ្រង់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមឌីជីថល តាមរយៈការជំរុញអនុវត្តផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព, សម្របសម្រួលរួម, និងវិភាជថវិកាគាំទ្រ ផ្ដោតលើការកសាងបណ្ដាញអ៊ីនធើណិតល្បឿនលឿន, ប្រព័ន្ធទូទាត់ឌីជីថល, ប្រព័ន្ធឡជីស្ទីក និងដឹកជញ្ជូនឱ្យមានប្រសិទ្ធភាពខ្ពស់ ភាពរស់រវើក និងវិសាលភាពគ្របដណ្ដប់ សម្រាប់ទ្រទ្រង់សេដ្ឋកិច្ច និងសង្គមឌីជីថល ដែលអាចឆ្លើយតបបានទៅនឹងតម្រូវការតភ្ជាប់របស់ប្រជាពលរដ្ឋ។

## យុទ្ធសាស្ត្រគន្លឹះទី២ : ទំនុកចិត្តនិងភាពជឿជាក់លើប្រព័ន្ធឌីជីថល

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចូលរួមសម្របសម្រួលការកសាងប្រព័ន្ធច្បាប់ និងការបង្កើនការយល់ដឹងអំពីសន្តិសុខនៃប្រព័ន្ធឌីជីថល ដែលនឹងរួមចំណែកបង្កើនទំនុកចិត្ត និងភាពជឿជាក់របស់តួអង្គពាក់ព័ន្ធ និងលើកទឹកចិត្តការចូលរួមក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល ឱ្យបានទូលំទូលាយ នៅគ្រប់ដំណាក់កាល, ក្នុងនោះ ត្រូវយកចិត្តទុកដាក់លើការរៀបចំក្របខណ្ឌគតិយុត្ត គោលនយោបាយ យុទ្ធសាស្ត្រតាមវិស័យផ្សេងៗទាក់ទងឌីជីថលូបនីយកម្ម ជាមួយស្ថាប័នមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធ, ការផ្សព្វផ្សាយណែនាំ ការត្រួតពិនិត្យការអនុវត្ត, ការបង្កើនភាពបុរេសកម្ម ដើម្បីបង្កបរិយាកាសអំណោយផល គាំពារ និងធានាបាននូវសុវត្ថិភាពជូនអ្នកប្រើប្រាស់ និងលើកកម្ពស់ភាពប្រកួតប្រជែងក្នុងវិស័យឌីជីថល។

## យុទ្ធសាស្ត្រគន្លឹះទី៣ : ពលរដ្ឋឌីជីថល

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចូលរួមសម្របសម្រួលការលើកកម្ពស់ភាពជាអ្នកដឹកនាំឌីជីថល ការអភិវឌ្ឍនិងប្រមូលផ្តុំធនធានមនុស្ស និងការប្រែក្លាយទៅជាពលរដ្ឋឌីជីថល ដើម្បីបង្កើតជាចលករនៃបរិវត្តកម្មឌីជីថលនៅកម្ពុជា ក្នុងនោះ ត្រូវយកចិត្តទុកដាក់លើការការអភិវឌ្ឍសមត្ថភាព ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន, ការប្រមូលផ្តុំនិងកសាងបណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល ដោយកសាងផែនការយុទ្ធសាស្ត្រ និងរៀបចំយន្តការលើកទឹកចិត្តដែលសមស្រប, ការលើកកម្ពស់គុណភាពនៃការសិក្សាកម្រិតទូទៅជារួម និងបន្តធ្វើសមាហរណកម្មបច្ចេកវិទ្យាឌីជីថល ទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិតនៃប្រព័ន្ធអប់រំនិងកម្រិតបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដើម្បីធានាថាប្រជាពលរដ្ឋមានចំណេះដឹង និងជំនាញឌីជីថលគ្រប់គ្រាន់ ព្រមទាំងចេះប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងជីវភាពរស់នៅប្រចាំថ្ងៃប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

## យុទ្ធសាស្ត្រគន្លឹះទី៤ : រដ្ឋាភិបាលឌីជីថល

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចូលរួមសម្របសម្រួល និងជំរុញសេវាសាធារណៈឌីជីថល ឈរលើគោលការណ៍សេវាកាន់តែសាមញ្ញ កាន់តែឆាប់រហ័ស កាន់តែប្រសើរ កាន់តែចំណាយតិច និងការរៀបចំពង្រឹងអភិបាលកិច្ចផ្អែកលើទិន្នន័យ ដែលនឹងជំរុញ និងលើកកម្ពស់តួនាទីរបស់វិស័យសាធារណៈក្នុងការត្រួសត្រាយផ្លូវ ការបំពេញគម្លាតនៃការវិនិយោគ និងការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈក្នុងបរិការណ៍ឌីជីថល, ក្នុងនោះ ត្រូវយកចិត្តទុកដាក់វិភាជថវិកាគាំទ្រទំនើបកម្មសេវាឌីជីថលដែលមានស្រាប់ បង្កើតសេវាសាធារណៈអាទិភាពជាឌីជីថល និងដាក់ឱ្យដំណើរការនូវការផ្តល់សេវាសាធារណៈឌីជីថលជូនប្រជាពលរដ្ឋ, កសាងថ្នាលបច្ចេកវិទ្យាជាមូលដ្ឋានដើម្បីជាគន្លឹះជំរុញការអនុវត្តឌីជីថល, និងជំរុញក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្លាយជាស្ថាប័នឌីជីថលដែលជាផ្នែកមួយនៃរដ្ឋាភិបាលឌីជីថលកម្ពុជា។

## យុទ្ធសាស្ត្រគន្លឹះទី៥ : ធុរកិច្ចឌីជីថល

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចូលរួមសម្របសម្រួល និងជំរុញការលើកទឹកចិត្តសហគ្រាសជារួម និងសហគ្រាសធុនតូចនិងមធ្យមជាពិសេស ឱ្យចាប់យកឌីជីថលឱ្យបានទូលំទូលាយ, ការបង្កើតប្រព័ន្ធអេកូឡូស៊ីសម្រាប់បណ្តុះធុរកិច្ចថ្មីៗ និងការចូលរួមក្នុងខ្សែច្រវាក់ឌីជីថលនៅក្នុងតំបន់ និងសកល តាមរយៈការលើកកម្ពស់លទ្ធភាពសហគ្រាសក្នុងការថ្លក់ទៅនឹងថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) សំដៅជំរុញធុរកិច្ចឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា និងទទួលបានមកវិញនូវអត្ថប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល នវានុវត្តន៍ និងសមាហរណកម្មរបស់ធុរកិច្ចក្នុងស្រុក ទៅនឹងខ្សែច្រវាក់ផលិតកម្ម និងខ្សែច្រវាក់តម្លៃក្នុងតំបន់ និងសកលលោក។

## ដ្យាក្រាមទី២៖
## ក្របខណ្ឌយុទ្ធសាស្ត្រ នៃចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០



# ៥ គុណតម្លៃស្ថាប័ន

## ៥
# គុណតម្លៃស្ថាប័ន

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រកាន់យកគុណតម្លៃស្ថាប័ន ដែលប្រទាក់ក្រឡា និងបំពេញគ្នាទៅវិញទៅមក រួមមានៈ **ក្រមសីលធម៌វិជ្ជាជីវៈ ស្មារតីបុរេសកម្ម ប្រតិគុល្យការ ប្រសិទ្ធភាព-ស័ក្តិសិទ្ធភាព នវានុវត្តន៍ និងគុណាធិបតេយ្យ** ដើម្បីជំរុញការបំពេញការងាររបស់គ្រប់ថ្នាក់ដឹកនាំ អង្គភាព ក្រុមការងារ និងមន្ត្រីរាជការ ឱ្យស្ថិតក្នុង**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**។

**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ** សំដៅលើការសហការ បំពេញការងារជាមួយគ្នា នៅក្នុងប្រព័ន្ធ និងពេលវេលាតែមួយ អាចយល់គ្នាយ៉ាងច្បាស់ ដោយមិនត្រឹមតែបំពេញតួនាទីរៀងៗខ្លួន មិនប្រកាន់គ្នាទៅវិញទៅមកប៉ុណ្ណោះទេ, ប៉ុន្តែថែមទាំងសម្របសម្រួល និងសហការជិតស្និទ្ធ មានសង្គតិភាព ផ្តល់ព័ត៌មាន បំពេញឱ្យគ្នាទៅវិញទៅមក ទទួលខុសត្រូវខ្ពស់ក្នុងការបំពេញបេសកកម្មរួម។ ការពង្រឹងសាមគ្គីភាពផ្ទៃក្នុងរឹងមាំ ដោយរក្សាជំហរ **“សាមគ្គីរស់ បែកបាក់សាមគ្គីស្លាប់”**។

គុណតម្លៃទាំង៦ ខាងលើ មានអត្ថន័យដូចតទៅៈ

**១ ក្រមសីលធម៌វិជ្ជាជីវៈ**

ការប្រតិបត្តិតាមគោលការណ៍សីលធម៌ ដែលកំណត់នូវសកម្មភាព និងអាកប្បកិរិយាក្នុងពេលបំពេញការងារ ដើម្បីរក្សាគុណតម្លៃ កិត្តិយស និងសេចក្តីថ្លៃថ្នូរ នៃមន្ត្រីរាជការ តាមរយៈ ការប្រកាន់ខ្ជាប់ឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ[9] ព្រមទាំងគោរពបានយ៉ាងខ្ជាប់ខ្ជួននូវអភិក្រម ៤ ប្រការ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**២ ស្មារតីបុរេសកម្ម**

ការគិតយល់មុននូវលទ្ធភាពកើតមានបញ្ហា, ការប្រកាន់យកគោលការណ៍មិនបង្កើតបញ្ហា, ការរៀបចំប្រព័ន្ធការងារដែលកាត់បន្ថយលទ្ធភាពកើតមានបញ្ហា, ការត្រៀមលក្ខណៈសកម្មជានិច្ច ត្រៀមដោះស្រាយបញ្ហាជាយថាហេតុ, ការមិនមើលបំណាំ មិនចោទប្រកាន់គ្នា, និង ការគិតគូរដោះស្រាយបញ្ហាទាន់នៅទំហំតូច ចាត់វិធានការជាមុនដោយមិនរង់ចាំការណែនាំ។

**៣ ប្រតិគុល្យការ**

ការពិចារណា ថ្លឹងថ្លែង បែងចែកតួនាទី ភារកិច្ច និងសិទ្ធិសម្រេច ប្រកបដោយយុត្តិធម៌ ដើម្បីធ្វើឱ្យថ្នាក់ដឹកនាំអង្គភាព និងមន្ត្រីគ្រប់លំដាប់ថ្នាក់មានលំនឹងចិត្ត ការជឿជាក់ និងការទទួលខុសត្រូវច្បាស់លាស់ ក្នុងការអនុវត្តតួនាទី ភារកិច្ច ដោយឈរលើមាគ៌ាសុចរិត យុត្តិធម៌ បម្រើឧត្តមប្រយោជន៍ជាតិ និងប្រជាជន។

**៤ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព**

ការផ្តោតការយកចិត្តទុកដាក់លើគុណភាពនៃលទ្ធផល ភាពសមស្របនៃចំណាយ និងវិធីសាស្ត្រប្រតិបត្តិការ ដោយប្រកាន់ជំហរ **“គិតត្រូវ ធ្វើត្រូវ ចំណាយតិច បានផលអតិបរមា”**។

**៥ នវានុវត្តន៍**

ការប្រើគំនិតកែច្នៃ និងការចូលរួមដោះស្រាយបញ្ហាប្រឈមជាក់ស្តែង តាមរយៈការបង្កើតដំណោះស្រាយថ្មី ឬការច្នៃប្រឌិតលើស្នាដៃដែលមានស្រាប់ដែលបង្កើតជាតម្លៃបន្ថែម។

**៦ គុណាធិបតេយ្យ**

ប្រព័ន្ធលើកទឹកចិត្តសមស្រប ផ្អែកលើសមត្ថភាព សមិទ្ធកម្ម ប្រសិទ្ធភាព វិន័យ នវានុវត្តន៍ និងសមធម៌ ដែលធានាសុចរិតភាព និទ្ទេសភាព និងកិត្យានុភាពស្ថាប័ន តាមគោលការណ៍ **“លើកទឹកចិត្តផ្អែកលើគុណសម្បត្តិ និងបង្កើតគុណសម្បត្តិដើម្បីបានការលើកទឹកចិត្ត”**។

[9] ដកស្រង់ចេញពី “គោលនយោបាយធនធានមនុស្ស ក្នុងរដ្ឋបាលសាធារណៈ”, រាជរដ្ឋាភិបាលកម្ពុជា, ខែកញ្ញា ឆ្នាំ២០១៣

# ៦ យន្តការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

# ៦
# យន្តការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការសម្រេចចក្ខុវិស័យក្រសួង ទាមទារឱ្យមានការចូលរួមអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ពីថ្នាក់ដឹកនាំក្រសួង ថ្នាក់ដឹកនាំអង្គភាព មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងភាគីពាក់ព័ន្ធ។

- ក្នុងកម្រិតនយោបាយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាមេបញ្ជាការរបស់ក្រសួង មានភារកិច្ចដឹកនាំ តម្រង់ទិស និងផ្តល់ឱវាទានុសាសន៍ដល់ថ្នាក់ដឹកនាំក្រសួង អង្គភាពក្រោមឱវាទ ក្រោមអាណាព្យាបាលក្រសួង និងអង្គភាពពាក់ព័ន្ធ ក្នុងការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ ឱ្យសម្រេចតាមគោលដៅកំណត់។
- ក្នុងកម្រិតបច្ចេកទេស អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញតួនាទីជាអង្គភាពសម្របសម្រួល ដែលមានភារកិច្ចសម្របសម្រួលជាមួយថ្នាក់ដឹកនាំក្រសួង និងគ្រប់អង្គភាពជំនាញពាក់ព័ន្ធ ទាំងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ក្នុងការរៀបចំផ្សព្វផ្សាយ ណែនាំអនុវត្ត ជំរុញអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រនៃចក្ខុវិស័យក្រសួង។
- ថ្នាក់ដឹកនាំក្រសួង គ្រប់អង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួង ទាំងនៅថ្នាក់កណ្តាល ថ្នាក់មូលដ្ឋាន និងអង្គភាពពាក់ព័ន្ធ មានភារកិច្ចសហការ ចូលរួមអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ ទៅតាមសមត្ថកិច្ចរបស់អង្គភាព និងតាមការចាត់តាំងរបស់រដ្ឋមន្ត្រី, ដោយត្រូវតម្កល់ និងប្រតិបត្តិតាមឱ្យបានខ្ជាប់ខ្ជួននូវគុណតម្លៃស្ថាប័នរបស់ក្រសួង ដូចមានកំណត់ក្នុងខ្លឹមសារខាងដើម ដើម្បីបុព្វហេតុជាតិ ប្រជាជន និងស្ថាប័ន។

នៅក្នុងដំណាក់កាលអនុវត្ត ការងារអាទិភាពកំណត់នៅតាមយុទ្ធសាស្ត្រគន្លឹះនីមួយៗ ដែលមានកំណត់ផងដែរក្នុង **តារាងម៉ាទ្រីសតម្រង់ទិសការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ** (ឧបសម្ព័ន្ធទី២) ត្រូវយកទៅគិតគូររៀបចំបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់សាមីអង្គភាព រួចត្រូវរៀបចំគ្រោងថវិកាគាំទ្រក្នុងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកានៃក្របខណ្ឌថវិកាកម្មវិធី ក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង/ឬក្របខណ្ឌថវិកាដៃគូអភិវឌ្ឍផ្សេងៗទៀតទៅតាមសារជាតិការងារនិងតាមការសម្រេចរបស់រដ្ឋមន្ត្រី។ ផែនការសកម្មភាពនេះត្រូវយកទៅអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងប្រើប្រាស់ថវិកាគាំទ្រឱ្យមានប្រសិទ្ធភាព។

ការអនុវត្តចក្ខុវិស័យក្រសួង ជាកម្មវត្ថុនៃការតាមដាននិងត្រួតពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ និងការវាយតម្លៃសមិទ្ធកម្មពាក់កណ្តាល និងចុងកាលកំណត់។

- ការតាមដាននិងត្រួតពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ ជាការពិនិត្យនិងរាយការណ៍វឌ្ឍនភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពទៅតាមការកំណត់នៃក្របខណ្ឌយុទ្ធសាស្ត្រ។ របាយការណ៍តាមដាននិងត្រួតពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ ជារបៀបវារៈមួយនៃកិច្ចពិភាក្សាក្នុងវិបស្សនា ឬកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពរបស់រដ្ឋមន្ត្រី។ អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានភារកិច្ចរៀបចំផែនការ និងបែបបទនៃការតាមដាននិងត្រួតពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំនេះ។
- នៅពាក់កណ្តាលកាលកំណត់នៃចក្ខុវិស័យ គឺនៅដើមឆ្នាំ២០២៦ ត្រូវរៀបចំការវាយតម្លៃសមិទ្ធកម្មពាក់កណ្តាលកាលកំណត់ ដោយពិនិត្យលើសមិទ្ធកម្មធំៗដែលសម្រេចបានក្នុងរយៈពេល ៥ ឆ្នាំ នៃការអនុវត្តចក្ខុវិស័យក្រសួង។ ក្នុងករណីស្ថានភាពផ្លាស់ប្តូរខុសប្លែកខ្លាំងពីការរំពឹងទុក, ចក្ខុវិស័យក្រសួង អាចនឹងត្រូវបានសម្រេចឱ្យពិនិត្យកែសម្រួលឡើងវិញឱ្យសមស្របនឹងស្ថានភាពជាក់ស្តែង ទៅតាមការសម្រេចរបស់រដ្ឋមន្ត្រី។
- នៅចុងកាលកំណត់នៃចក្ខុវិស័យ គឺនៅដើមឆ្នាំ២០៣១ ត្រូវរៀបចំការវាយតម្លៃសមិទ្ធកម្មពេញរយៈពេល ៩ឆ្នាំ ដើម្បីវាយតម្លៃសមិទ្ធកម្មផ្ទាល់សំខាន់ៗ និងការចូលរួមចំណែករបស់ក្រសួងឱ្យរាជរដ្ឋាភិបាលសម្រេចបង្គោលចរឆ្នាំ២០៣០។ អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកការងារវាយតម្លៃនេះ។

# ៧ ការវិភាគ និង ការគ្រប់គ្រងហានិភ័យ

# ៧
# ការវិភាគនិងការគ្រប់គ្រងហានិភ័យ

ការវិភាគនិងការគ្រប់គ្រងហានិភ័យ ជាការវិភាគលើយន្តការទប់ទល់ ទប់ស្កាត់ និង/ឬកាត់បន្ថយនូវហានិភ័យដែលអាចកើតឡើងជាយថាហេតុ និងអាចធ្វើឱ្យប៉ះពាល់ដល់ការសម្រេចចក្ខុវិស័យក្រសួង។ ហានិភ័យចម្បងៗ និងការត្រៀមវិធានការនានាទៅតាមហានិភ័យនីមួយៗ មានដូចខាងក្រោម៖

## ១ ហានិភ័យនៃការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចអាចនាំទៅរកវិបត្តិសេដ្ឋកិច្ច

កម្ពុជាជាប្រទេសមានសេដ្ឋកិច្ចបើកចំហ។ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជានារយៈពេលចុងក្រោយនេះមានស្ថិរភាពល្អប្រសើរ ដែលស្តែងឱ្យឃើញពីវិន័យ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ សម្រាប់គោលនយោបាយរូបិយវត្ថុវិញ ការបន្តអនុវត្តគោលនយោបាយបែបដុល្លាររូបនីយកម្ម ថ្វីត្បិតអាចចូលរួមរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់និងអតិផរណាក្នុងស្រុក ប៉ុន្តែជម្រើសគោលនយោបាយដូច នេះនៅមិនទាន់សមស្របសម្រាប់រយៈពេលវែងនៅឡើយ។

*វិធានការគ្រប់គ្រង៖* កម្ពុជាត្រូវគិតគូរបង្កើត និងពង្រឹងឧបករណ៍គោលនយោបាយទាំងផ្នែកម៉ាក្រូសេដ្ឋកិច្ច ហិរញ្ញវត្ថុ រូបិយវត្ថុ និងហិរញ្ញវត្ថុសាធារណៈ ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ២ ការកើតឡើងនូវវិបត្តិសកលផ្សេងៗ

ការកើតឡើងនូវវិបត្តិជំងឺសកលណាមួយ ឬវិបត្តិជាសកលផ្សេងៗទៀត ជាអាទិ៍ វិបត្តិហិរញ្ញវត្ថុ វិបត្តិសង្គ្រាម ឬការប្រទាញប្រទង់មនោគមវិជ្ជាសកលនឹងជះផលប៉ះពាល់អវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជាដោយបង្អាក់ដំណើរការអភិវឌ្ឍនិងការសម្រេចនូវចក្ខុវិស័យកម្ពុជា និយាយជារួម និងចក្ខុវិស័យក្រសួង និយាយដោយឡែក។ វិបត្តិសកលទោះក្នុងសណ្ឋានណាក៏ដោយ នឹងទាញសមិទ្ធផលនៃការអភិវឌ្ឍឱ្យដើរថយក្រោយ និងកាត់បន្ថយលទ្ធភាពថវិការបស់រដ្ឋក្នុងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា សម្រាប់បន្តគាំទ្រដំណើរអភិវឌ្ឍ។

*វិធានការគ្រប់គ្រង៖* ក្នុងស្ថានការណ៍ដែលវិបត្តិរាលដាលកើតឡើង វិធានការបន្ទាន់សម្រាប់កម្ពុជាគឺការដាក់ចេញនូវវិធានការរក្សាលំនឹងម៉ាក្រូសេដ្ឋកិច្ចតាមរយៈគោលនយោបាយសារពើពន្ធនិងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជារួមឱ្យបានល្អ ដោយពង្រឹងការប្រមូលចំណូល រឹតត្បិតចំណាយ និងចាត់ចែងវិភាជឡើងវិញនូវថវិកាដែលបានអនុម័តរួចទៅតាមលទ្ធភាព សំដៅបង្វែរថវិកាដោះស្រាយវិបត្តិចំពោះមុខ។ ទន្ទឹមនេះ ការរៀបចំយន្តការគណៈកម្មការ ឬក្រុមការងារច្បាស់លាស់ ដែលមានលក្ខណៈអន្តរអង្គភាព ឬអន្តរក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដោះស្រាយបញ្ហាកើតឡើងជាក់ស្តែង និងគ្រប់គ្រងផលប៉ះពាល់នៃវិបត្តិ ពិតជាវិធានការដែលចាំបាច់។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គួររៀបចំឱ្យមានផែនការធានានិរន្តរភាពការងារ (Business Continuity Plan) ដើម្បីធានាដំណើរការស្ថាប័ន។ ក្រោយវិបត្តិថមថយ និងស្ថិតក្នុងស្ថានភាពអាចគ្រប់គ្រងបាន ការគិតគូររៀបចំផែនការស្តារសេដ្ឋកិច្ច-សង្គមឡើងវិញ (Social-economic resilience) គឺជាវិធានការចាំបាច់សម្រាប់រយៈពេលមធ្យម។

## ៣ សេដ្ឋកិច្ចសកលប្រឈមនឹងភាពមិនប្រាកដប្រជា

សេដ្ឋកិច្ចពិភពលោកស្ថិតក្នុងភាពមិនប្រាកដប្រជា ដែលទទួលរងឥទ្ធិពលពីវិបត្តិនៃជំងឺកូវីដ-១៩ សង្គ្រាមពាណិជ្ជកម្មរវាងប្រទេសមហាអំណាច ការប្រកាន់យកគោលនយោបាយគាំពារនិយម ការថមថយនៃកំណើនសេដ្ឋកិច្ចប្រទេសចិន ព្រមទាំងបញ្ហានានាពាក់ព័ន្ធភូមិសាស្ត្រនយោបាយ ភេរវកម្ម និងសន្តិសុខសកល។

*វិធានគ្រប់គ្រង៖* កម្ពុជាជ្រើសយកមាគ៌ាសេដ្ឋកិច្ចទីផ្សារសេរី ប៉ុន្តែរដ្ឋជាសេដ្ឋវិទូ ដែលធ្វើនិយ័តកម្ម និងអន្តរាគមន៍ក្នុងទីផ្សារតាមការចាំបាច់ ដើម្បីរក្សាលំនឹងទីផ្សារ និងរក្សាផលប្រយោជន៍រួមរបស់ប្រជាជន ដូចនេះ រដ្ឋត្រូវតែបន្តពង្រឹងការកសាងមូលដ្ឋានសេដ្ឋកិច្ចក្នុងស្រុកឱ្យបានរឹងមាំ និងបុរេសកម្មក្នុងកិច្ចអន្តរាគមន៍ ដើម្បីឆ្លើយតបដើរទាន់និងស្របតាមការផ្លាស់ប្តូរកត្តាភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចសកលលោក។

## ៤ ស្ថានភាពតម្រូវឱ្យជ្រើសរើសបច្ចេកវិទ្យាណាមួយដោយផ្តាច់មុខក្នុងបរិបទសេដ្ឋកិច្ច-សង្គមឌីជីថល

ក្នុងបរិការណ៍នៃបរិវត្តកម្មឌីជីថល, ការប្រើប្រាស់បច្ចេកវិទ្យាដើម្បីធ្វើទំនើបកម្មស្ថាប័ន ជាកត្តាចាំបាច់បំផុត និងជាកត្តាស្លាប់រស់សម្រាប់កម្ពុជា។ ការប្រជែងគ្នាផ្នែកបច្ចេកវិទ្យារវាងមហាអំណាចបច្ចេកវិទ្យាព័ត៌មានលើពិធីសារ ឬថ្នាលបច្ចេកវិទ្យាស្នូលដែលបម្រើឱ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យាផ្សេងៗ, នាំឱ្យការជ្រើសយកបច្ចេកវិទ្យាឱ្យសមស្រប ទៅនឹងតម្រូវការ សមត្ថភាព និងលទ្ធភាពស្ថាប័ន ពិតជាតម្រូវការយុទ្ធសាស្ត្រចាំបាច់សម្រាប់ទាញយកអត្ថប្រយោជន៍ ជាអតិបរមា សំដៅបង្កើនផលិតភាព ប្រសិទ្ធភាពការងារ និងធានាថាវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជាដើរទាន់ សភាពការណ៍ និងបន្តអភិវឌ្ឍទៅមុខ។ ប្រសិនបើកើតមានស្ថានភាពដែលតម្រូវឱ្យជ្រើសរើសយកបច្ចេកវិទ្យា ណាមួយដោយផ្តាច់មុខ ហើយត្រូវបានហាមឃាត់មិនឱ្យប្រើប្រាស់ឆ្លងប្រព័ន្ធនោះ កម្ពុជានឹងប្រឈមហានិភ័យនៃ ការជ្រើសយកបច្ចេកវិទ្យាដែលមិនសមស្រប ងាយនឹងហួសសម័យ មិនមានប្រសិទ្ធភាព ឬពុំមែនជាប្រព័ន្ធដែលប្រើប្រាស់ ភាគច្រើនលើសកលលោកដែលអាចជាកំហុសយុទ្ធសាស្ត្រនាំមកនូវបរាជ័យក្នុងដំណើរការអភិវឌ្ឍនិងទាញឱ្យស្ថាប័ន ដើរថយក្រោយ។

*វិធានគ្រប់គ្រង៖* ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តពង្រឹងការអភិវឌ្ឍផ្នែកបច្ចេកវិទ្យាព័ត៌មាន និង ជំរុញនវានុវត្តន៍ផ្ទៃក្នុងស្ថាប័ន ស្របតាមផែនការមេច្បាស់លាស់។ ការពិនិត្យឡើងវិញជាប្រចាំនូវប្រសិទ្ធភាពនៃ ការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន សន្តិសុខនិងសុវត្ថិភាពប្រព័ន្ធ និងការវិវត្តនៃបច្ចេកវិទ្យាក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាពិសេស ក្នុងស្ថាប័នរដ្ឋ ជាវិធានការចាំបាច់ ម្យ៉ាងដើម្បីកាត់បន្ថយហានិភ័យនៃបរាជ័យក្នុងការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន ដែលបានចាប់យកហើយនោះ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គួរពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកវិទ្យា ព័ត៌មានជាមួយស្ថាប័នផ្សេងៗ ក្នុងតំបន់ និងពិភពលោក ក្នុងការផ្លាស់ប្តូរបទពិសោធន៍ ការទទួលបានការគាំទ្រ បច្ចេកទេស និង/ឬហិរញ្ញវត្ថុ ព្រមទាំងរួមចំណែកកាត់បន្ថយគម្លាតឌីជីថលរវាងកម្ពុជាជាមួយប្រទេសនានាក្នុងតំបន់។

## ៥ ការប្រែប្រួលអាកាសធាតុរុញច្រានការអភិវឌ្ឍឱ្យដើរថយក្រោយ

ការប្រែប្រួលអាកាសធាតុជាប្រធានបទក្តៅ។ គ្រោះមហន្តរាយបណ្តាលមកពីការប្រែប្រួលអាកាសធាតុ បង្ក ឱ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ខាតបង់ថវិកា និងជះផលប៉ះពាល់លើការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងជីវភាព ប្រជាជន។ ក្នុងករណីកិច្ចខិតខំប្រឹងប្រែងរបស់ពិភពលោកមិនអាចឱ្យមានការវិវត្តជាវិជ្ជមានទេនោះ កម្ពុជាអាចនឹង ប្រឈមមហន្តរាយគ្រោះធម្មជាតិកាន់តែច្រើនឡើង ហើយផលប៉ះពាល់អវិជ្ជមានពីគ្រោះធម្មជាតិ នឹងរុញច្រានឱ្យ សមិទ្ធផលនិងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍសង្គម-សេដ្ឋកិច្ចដែលសម្រេចបានកន្លងមកដើរថយក្រោយ និងតម្រូវឱ្យ រាជរដ្ឋាភិបាលត្រូវបង្កើនការវិភាជថវិកាជាតិសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

*វិធានការគ្រប់គ្រង៖* កម្ពុជាត្រូវបន្តពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលបានដាក់ចេញកន្លងមក តាមរយៈការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបច្ចេកទេស ការបង្កើន ការយល់ដឹងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងការផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័ន អង្គភាព និងភាគី ពាក់ព័ន្ធ ទៅតាមផែនការសកម្មភាព សំដៅប្រមូលធនធាន និងកសាងភាពជាដៃគូជាមួយគ្រប់ភាគីពាក់ព័ន្ធឱ្យបាន ទូលំទូលាយ និងបន្តដាក់ចេញវិធានការបន្ថែមទៀត។ បន្ថែមពីនេះ កម្ពុជាត្រូវបន្តពង្រឹងកិច្ចសហការជាមួយ ដៃគូអភិវឌ្ឍន៍ និងបន្តចូលរួមកិច្ចចរចាអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដើម្បីចូលរួមចំណែកដោះស្រាយ បញ្ហាពិភពលោកនេះ និងកៀរគរធនធានពីប្រភពក្រៅប្រទេស ជាអាទិ៍មូលនិធិអាកាសធាតុបៃតង ដែលអាច រួមចំណែកផ្តល់ហិរញ្ញប្បទានដល់គម្រោងអាទិភាពនៅកម្ពុជា។

# ៥ សន្និដ្ឋាន

## ៨

# សន្និដ្ឋាន

អភិបាលកិច្ចល្អ នីតិរដ្ឋ សន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខ-សណ្តាប់ធ្នាប់សង្គម ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា យកចិត្តទុកដាក់ ខិតខំប្រឹងប្រែងស្ថាបនា កសាង និងការពារយ៉ាងមោះមុត រហូតសម្រេចបាន មហាសមិទ្ធផលនៃកិច្ចអភិវឌ្ឍលើគ្រប់វិស័យ។ ឈរលើមូលដ្ឋាននេះ កម្ពុជាបានឈានមកដល់ដំណាក់កាល “ប្រែប្រួលថ្មី” ដែលជា អន្តរកាលឆ្ពោះទៅសម្រេចឋានៈប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។ ដំណាក់កាលអន្តរកាលនេះតម្រូវឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តោតលើវិសេសភាពនៃមុខងាររបស់ក្រសួងផ្ទាល់ ព្រមទាំងការចូលរួមរបស់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធដោយ ផ្ទាល់ ឬប្រយោលផ្សេងៗទៀត និងគិតគូរកំណត់ចក្ខុវិស័យ សម្រាប់ឆ្នាំ២០៣០ ខាងមុខ ដើម្បីកសាងមូលដ្ឋានគ្រឹះផ្នែកសង្គម-សេដ្ឋកិច្ចដែលគាំទ្រដល់ដំណើរឆ្លងកាត់ដំណាក់កាលអន្តរកាលនេះដោយជោគជ័យ។ ទន្ទឹមនេះ តម្រូវការកសាងសមត្ថភាព ស្ថាប័ននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្ទាល់ដើម្បីបំពេញភារកិច្ចខាងលើ ពិតជាចាំបាច់ជាងពេលណាៗទាំងអស់។ នេះជា សនិទានកម្មនៃការរៀបចំ**ចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០**។

ចក្ខុវិស័យក្រសួង បានកំណត់ការប្រែក្លាយជា “ស្ថាប័ននៃឧត្តមភាព” ដែលពេញដោយសមត្ថភាពនិងគុណវុឌ្ឍិគ្រប់គ្រាន់ សម្រាប់បំពេញបេសកកម្មស្នូល និងបេសកកម្មពាក់ព័ន្ធ ដែលច្បាប់ និងរាជរដ្ឋាភិបាលប្រគល់ឱ្យ។ ការសម្រេចចក្ខុវិស័យ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវគាំទ្រដោយក្របខណ្ឌយុទ្ធសាស្ត្រ ដែលកំណត់ឱ្យមានអង្គភាពទទួលបន្ទុកច្បាស់លាស់។ ក្នុងនោះសម្រាប់ការកសាងស្ថាប័ន, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពង្រឹងសមត្ថភាពនិងវិជ្ជាជីវៈ ជំរុញស្មារតីសកម្ម និង បុរេសកម្ម និងធានាភាពស្អាតស្អំនិងសុចរិតភាព។ សម្រាប់ការបង្កើនប្រសិទ្ធភាពនៃការបំពេញមុខងារនិងភារកិច្ច, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសម្របសម្រួល និងជំរុញកសាងមូលដ្ឋានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិធន់មាំ ដឹកនាំធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈនិងទ្រព្យសម្បត្តិរដ្ឋឆ្ពោះទៅឧត្តមានុវត្តន៍ ចូលរួមកសាងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ និងចូលរួមជំរុញបរិវត្តកម្មឌីជីថល កសាងសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា។

ជោគជ័យនៃចក្ខុវិស័យក្រសួង អាស្រ័យជាចាំបាច់លើការចូលរួមពេញលេញ ប្រកបដោយឆន្ទៈមោះមុត របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ព្រមទាំងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ជាមួយនឹងមហិច្ឆតាប្រាកដនិយម និងការសម្រប សម្រួលក្នុងស្មារតីសមូហភាព។ ក្នុងនោះ សម្រាប់មុខងារដែលត្រូវសហការអនុវត្តជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធផ្សេងៗ ក្រៅរចនាសម្ព័ន្ធរដ្ឋបាលក្រសួង, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបំពេញមុខងារជានិម្មាបនករប្រកបដោយចក្ខុវិស័យ រីឯ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ នឹងត្រូវស្នើឱ្យចូលរួមសហការរៀបចំ អនុវត្ត និងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដោយតម្កល់ ឧត្តមប្រយោជន៍រួមរបស់ប្រជាជន និងសង្គមជាតិ, សហការអនុវត្តការងាររួមគ្នាក្នុងប្រព័ន្ធតួអង្គតែមួយ ក្នុងពេលវេលាតែមួយ សំដៅបង្កើតសហថាមភាព ដែលជំរុញឱ្យសម្រេចគោលដៅកសាងមូលដ្ឋានសង្គម-សេដ្ឋកិច្ចរឹងមាំ និងគាំទ្រដល់ការប្រែក្លាយ កម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០។

ឯកសារចក្ខុវិស័យក្រសួង ត្រូវបានចាត់ទុកជាឯកសាររស់ ដែលជាកម្មវត្ថុនៃការកែប្រែទៅតាមការប្រែប្រួលកាលៈទេសៈ សង្គម-សេដ្ឋកិច្ចកម្ពុជា និងតាមគោលដៅយុទ្ធសាស្ត្រឆ្នាំ២០៣០ របស់រាជរដ្ឋាភិបាល។ ចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០ ជាសក្ខីកម្មនៃកិច្ចខិតខំប្រឹងប្រែងផ្នែកផែនការនីយកម្ម និងការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់ថ្នាក់ដឹកនាំក្រសួង អង្គភាព ក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងវិសាលភាពនៃចក្ខុវិស័យនេះ ជាមួយនឹងបុគ្គលិក មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដើម្បីចូលរួម និងគាំទ្ររាជរដ្ឋាភិបាល ក្នុងដំណើរដឹកនាំនាវាកម្ពុជាឆ្ពោះទៅគោលដៅដ៏ប្រពៃ គឺ កម្ពុជាជា “កោះសន្តិភាព” ជារដ្ឋទំនើប ប្រកបដោយអារ្យធម៌ឧត្តុង្គឧត្តម ស្តុកស្តម្ភ រីកចម្រើនលូតលាស់ ប្រកបដោយចីរភាព សមធម៌បរិបូណ៌ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យ និងនីតិរដ្ឋ។

# ឧបសម្ព័ន្ធ

ខ

## ឧបសម្ព័ន្ធទី១ : ក្របខណ្ឌរួមនៃចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០

### ចក្ខុវិស័យ

"នៅឆ្នាំ២០៣០ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាស្ថាប័ននៃឧត្តមភាព ប្រកបដោយសមត្ថភាព និងគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីបំពេញបេសកកម្មស្នូលនិងពាក់ព័ន្ធ ក្នុងការចូលរួមវិភាគទានឱ្យសម្រេចចក្ខុវិស័យរាជរដ្ឋាភិបាល។"

### បេសកកម្ម

១. កសាងមូលដ្ឋានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ
២. កសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ
៣.ដឹកនាំ និងសម្របសម្រួលការកសាងប្រព័ន្ធគាំពារសង្គម
៤. ចូលរួមដឹកនាំ និងសម្របសម្រួលបរិវត្តកម្មឌីជីថល ការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល។

### ក្របខណ្ឌយុទ្ធសាស្ត្រ

**គោលបំណងទី១ : សមត្ថភាពនិងគុណវុឌ្ឍិជាស្ថាប័ននៃឧត្តមភាព**

**គោលដៅទី១ : ពង្រឹងសមត្ថភាព និងវិជ្ជាជីវៈ**

- យុទ្ធសាស្ត្រគន្លឹះទី១ : ប្រព័ន្ធអភិវឌ្ឍមូលធនមនុស្ស
- យុទ្ធសាស្ត្រគន្លឹះទី២ : ប្រព័ន្ធការងារលើកតម្កើងសមត្ថភាព
- យុទ្ធសាស្ត្រគន្លឹះទី៣ : យន្តការស្ថាប័ននវានុវត្តន៍
- យុទ្ធសាស្ត្រគន្លឹះទី៤ : ក្របខណ្ឌគតិយុត្ត និងគោលនយោបាយពេញលេញ

**គោលដៅទី២ : ជំរុញស្មារតីសកម្ម និងបុរេសកម្ម**

- យុទ្ធសាស្ត្រគន្លឹះទី១ : របៀបរបបការងារ
- យុទ្ធសាស្ត្រគន្លឹះទី២ : វប្បធម៌ផលិតភាព គុណភាព និងប្រសិទ្ធភាព
- យុទ្ធសាស្ត្រគន្លឹះទី៣ : សាមគ្គីភាពផ្ទៃក្នុង
- យុទ្ធសាស្ត្រគន្លឹះទី៤ : ហេដ្ឋារចនាសម្ព័ន្ធគាំទ្រការបំពេញការងារ
- យុទ្ធសាស្ត្រគន្លឹះទី៥ : ប្រព័ន្ធលើកទឹកចិត្ត ឬចាត់វិធានការ

**គោលដៅទី៣ : ធានាភាពស្អាតស្អំ និងសុចរិតភាព**

- យុទ្ធសាស្ត្រគន្លឹះទី១ : វប្បធម៌ស្អាតស្អំ
- យុទ្ធសាស្ត្រគន្លឹះទី២ : ប្រព័ន្ធការងារសុចរិត
- យុទ្ធសាស្ត្រគន្លឹះទី៣ : សេវាស្អាតស្អំ
- យុទ្ធសាស្ត្រគន្លឹះទី៤ : ការងារសុចរិត

**គោលបំណងទី២ : ប្រសិទ្ធភាពនៃការអនុវត្តមុខងារនិងភារកិច្ច**

**គោលដៅទី១ : បង្កើនភាពធន់នៃមូលដ្ឋានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ**

- យុទ្ធសាស្ត្រគន្លឹះទី១ : ចីរភាពនៃកំណើន
- យុទ្ធសាស្ត្រគន្លឹះទី២ : ពិពិធកម្មសេដ្ឋកិច្ច
- យុទ្ធសាស្ត្រគន្លឹះទី៣ : វិស័យឯកជន និងការងារ
- យុទ្ធសាស្ត្រគន្លឹះទី៤ : ភាពជាម្ចាស់ និងភាពជាដៃគូ ក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ

**គោលដៅទី២ : ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងទ្រព្យសម្បត្តិរដ្ឋឆ្ពោះទៅឧត្តមានុវត្តន៍**

យុទ្ធសាស្រ្តគន្លឹះទី១ : ចីរភាពនៃភាពជឿទុកចិត្តនៃថវិកា
យុទ្ធសាស្រ្តគន្លឹះទី២ : គណនេយ្យភាពហិរញ្ញវត្ថុ
យុទ្ធសាស្រ្តគន្លឹះទី៣ : ប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ
យុទ្ធសាស្រ្តគន្លឹះទី៤ : គណនេយ្យភាពសមិទ្ធកម្ម
យុទ្ធសាស្រ្តគន្លឹះទី៥ : ចលនការនៃការកែទម្រង់ និងប្រសិទ្ធភាពគ្រប់គ្រងប្រព័ន្ធ

**គោលដៅទី៣ : ចូលរួមកសាងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈជាប្រព័ន្ធនិងគ្រប់ជ្រុងជ្រោយ**

យុទ្ធសាស្រ្តគន្លឹះទី១ : អភិបាលកិច្ចល្អ
យុទ្ធសាស្រ្តគន្លឹះទី២ : ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃចំណាយ
យុទ្ធសាស្រ្តគន្លឹះទី៣ : ការទទួលខុសត្រូវ
យុទ្ធសាស្រ្តគន្លឹះទី៤ : ចីរភាពហិរញ្ញវត្ថុ

**គោលដៅទី៤ : ចូលរួមជំរុញបរិវត្តកម្មឌីជីថល កសាងសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា**

យុទ្ធសាស្រ្តគន្លឹះទី១ : ហេដ្ឋារចនាសម្ព័ន្ធឌីជីថល
យុទ្ធសាស្រ្តគន្លឹះទី២ : ទំនុកចិត្តនិងភាពជឿជាក់លើប្រព័ន្ធឌីជីថល
យុទ្ធសាស្រ្តគន្លឹះទី៣ : ពលរដ្ឋឌីជីថល
យុទ្ធសាស្រ្តគន្លឹះទី៤ : រដ្ឋាភិបាលឌីជីថល
យុទ្ធសាស្រ្តគន្លឹះទី៥ : ធុរកិច្ចឌីជីថល

## គុណតម្លៃស្ថាប័ន

**១-ក្រមសីលធម៌វិជ្ជាជីវៈ**
**២-ស្មារតីបុរេសកម្ម**
**៣-ប្រតិតុល្យការ**
**៤-ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព**
**៥-នវានុវត្តន៍**
**៦-គុណាធិបតេយ្យ**

ខ

## ឧបសម្ព័ន្ធទី២ : តារាងម៉ាទ្រីសតម្រង់ទិសការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ

| ល.រ.រួម | ល.រ | ការងារអាទិភាព | អង្គភាពទទួលបន្ទុក | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | គោលបំណងទី១ : សមត្ថភាពនិងគុណវុឌ្ឍិជាស្ថាប័ននៃឧត្តមភាព | | | | | | | | | | | | |
| | គោលដៅទី១ : ពង្រឹងសមត្ថភាព និងវិជ្ជាជីវៈ | | | | | | | | | | | | |
| | | យុទ្ធសាស្ត្រគន្លឹះទី១ : ប្រព័ន្ធអភិវឌ្ឍមូលធនមនុស្ស | | | | | | | | | | | |
| | | *រើសត្រូវ* | | | | | | | | | | | |
| ១ | ១ | ពង្រឹងការប្រឡងប្រជែងជ្រើសរើសមន្ត្រីថ្មី និងបុគ្គលិកជាប់កិច្ចសន្យានៅគ្រប់អង្គភាព | - អល-កសហវ. | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ២ | ២ | ពង្រឹងយន្តការស្នើផ្តល់ជូនក្របខណ្ឌពិសេស | - អល-កសហវ. | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៣ | ៣ | សាកល្បងអនុវត្តការជ្រើសរើស និងប្រើប្រាស់មន្ត្រី តាមប្រព័ន្ធនិយោជន៍ | - អល-កសហវ. | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | *បណ្តុះបណ្តាលត្រូវ* | | | | | | | | | | | |
| ៤ | ៤ | ជំរុញរៀបចំ និងបង្កើនគុណភាពនៃផែនការអភិវឌ្ឍធនធានមនុស្សនៅតាមអង្គភាពក្រោមឱវាទក្រសួង | - គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៥ | ៥ | រៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពជាការតម្រង់ទិស ឬវគ្គទូទៅ នៅថ្នាក់ក្រសួង | - វសហ.<br>- អល-កសហវ.<br>- គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៦ | ៦ | រៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លី-មធ្យម សម្រាប់បច្ចុប្បន្នភាព ឬបំពាក់ជំនាញថ្មីជាក់លាក់ នៅអង្គភាពជំនាញផ្ទាល់ | - គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៧ | ៧ | លើកទឹកចិត្តឱ្យបណ្តុះបណ្តាលគ្រូបង្គោលតាមអង្គភាព | - គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| ល.រ.រួម | ល.រ | ការងារអាទិភាព | អង្គភាពទទួលបន្ទុក | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៨ | ៨ | ពង្រឹងការចាត់បញ្ជូនមន្ត្រីចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលឱ្យចំមុខងារទទួលបន្ទុក និងជំរុញការចែករំលែកចំណេះដឹងផ្ទៃក្នុង | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៩ | ៩ | ជំរុញលើកទឹកចិត្តអត្តាភិវឌ្ឍន៍ | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | *ប្រើប្រាស់ត្រូវ* | | | | | | | | | | | |
| ១០ | ១០ | ពង្រឹងការគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ ការវិភាគមុខងារ តម្រូវការ គុណវុឌ្ឍិសម្រាប់មុខតំណែង និងការគ្រប់គ្រងគុណវុឌ្ឍិមន្ត្រីតាមប្រព័ន្ធ បច្ចេកវិទ្យាព័ត៌មាន | - អល-កសហវ.<br>- គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ១១ | ១១ | បែងចែកមន្ត្រី ផ្អែកលើគុណវុឌ្ឍិ ជំនាញ ការចង់បានរបស់មន្ត្រី និងតម្រូវការអង្គភាព-ក្រសួង | - អល-កសហវ.<br>- គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ១២ | ១២ | ជំរុញឱ្យមានសៀវភៅណែនាំការងារជំនាញនៅតាមនាយកដ្ឋាន | - គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | *ទុកដាក់ត្រូវ* | | | | | | | | | | | |
| ១៣ | ១៣ | បង្កើតកាលានុវត្តភាពសម្រាប់ការវិវឌ្ឍអាជីពរបស់មន្ត្រី ទាំងក្នុងមុខតំណែងរដ្ឋបាល និងមុខតំណែងវិជ្ជាជីវៈ | - គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ១៤ | ១៤ | តែងតាំងមន្ត្រីឱ្យកាន់មុខតំណែង ដោយផ្អែកលើសមត្ថភាព បុគ្គលិកលក្ខណៈ អតីតភាពការងារ និងសមភាពយេនឌ័រ | - អល-កសហវ.<br>- គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | **យុទ្ធសាស្ត្រគន្លឹះទី២ : ប្រព័ន្ធការងារលើកតម្កើងសមត្ថភាព** | | | | | | | | | | | |
| ១៥ | ១ | ធ្វើវិចារណកម្មមុខងារអង្គភាពក្រោមឱវាទ ដោយពិនិត្យ និងកែសម្រួលឡើងវិញនូវមុខងារភារកិច្ចដែលត្រួតគ្នា | - អល-កសហវ. | | | ✓ | ✓ | | | | ✓ | ✓ | |
| ១៦ | ២ | ទំនើបកម្មប្រព័ន្ធការងារតាមបច្ចេកវិទ្យាព័ត៌មាន ដោយធ្វើសន្ទានកម្មប្រព័ន្ធដែលពាក់ព័ន្ធគ្នា និងអនុវត្តប្រព័ន្ធអ៊ីនត្រាណិតក្រសួង ឬអ៊ិនធើណិតដែលមានប្រព័ន្ធសុវត្ថិភាពសមស្រប | - អល-កសហវ.<br>- គ្រប់អង្គភាព | | ✓ | ✓ | ✓ | | | | | | |

| ល.រ.រួម | ល.រ | ភារកិច្ចអាទិភាព | អង្គភាពទទួលបន្ទុក | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១៧ | ៣ | ផ្តល់សិទ្ធិអំណាចជាបន្តបន្ទាប់ដល់អង្គភាពជំនាញ លើការជ្រើសរើស ចាត់ចែង និងស្នើតែងតាំងមន្ត្រីដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ | - ថ្នាក់ដឹកនាំក្រសួង<br>- គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ១៨ | ៤ | ពិនិត្យ កែលម្អ ឬធ្វើបច្ចុប្បន្នភាពរំហូរនីតិវិធីការងារផ្ទៃក្នុង ដែលប្រទាំងប្រទើស និងស្មុគស្មាញ ព្រមទាំងសហការគ្នាកែលម្អ សម្រួល នីតិវិធីការងារឆ្លងអង្គភាព | - គ្រប់អង្គភាព | | ✓ | ✓ | | | | | ✓ | ✓ | |
| ១៩ | ៥ | ជំរុញអនុវត្តការបង្វឹក និងការណែនាំការងារដោយថ្នាក់ដឹកនាំអង្គភាព (Coaching and Mentoring) និងការបណ្តុះបណ្តាលផ្ទាល់ដោយមន្ត្រីជារៀមច្បង (On-the-job Training) | - គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ២០ | ៦ | ពិនិត្យលទ្ធភាពផ្តល់សិទ្ធិសម្រេចឱ្យបានច្រើន ដល់ថ្នាក់ដឹកនាំនៅក្រោមបន្ទាប់នៅគ្រប់កម្រិត ទៅតាមសមត្ថភាព និងកម្រិតអាចទទួលខុសត្រូវបានជាក់ស្តែង | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | **យុទ្ធសាស្ត្រគន្លឹះទី៣ : យន្តការស្ថាប័ននវានុវត្តន៍** | | | | | | | | | | | |
| ២១ | ១ | ពង្រឹងយន្តការគណៈកម្មាធិការ គណៈកម្មការ ក្រុមការងារអចិន្ត្រៃយ៍ដែលមានស្រាប់ ដោយផ្លាស់ប្តូរ ឬបន្ថែមសមាសភាពអ្នកពាក់ព័ន្ធតាមការចាំបាច់ និងជំរុញឱ្យចូលរួមមតិនិងអនុវត្តការងារពីគ្រប់សមាសភាព | - ថ្នាក់ដឹកនាំក្រសួង<br>- គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ២២ | ២ | លើកទឹកចិត្តឱ្យប្រើប្រាស់យន្តការអន្តរអង្គភាព ដើម្បីទទួលបន្ទុកការងារលក្ខណៈពហុវិស័យ ដោយមានយន្តការតាមដាននិងវាយតម្លៃ | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | **យុទ្ធសាស្ត្រគន្លឹះទី៤ : ក្របខណ្ឌគតិយុត្ត និងគោលនយោបាយពេញលេញ** | | | | | | | | | | | |
| ២៣ | ១ | បច្ចុប្បន្នភាព ឬបំពេញបន្ថែមក្របខណ្ឌគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធ ឱ្យស្របតាមទិសដៅនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០ | - កករ-កសហវ.<br>- គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| ល.រ.រួម | ល.រ | ការងារអាទិភាព | អង្គភាពទទួលបន្ទុក | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២៤ | ២ | បច្ចុប្បន្នភាព និងអភិវឌ្ឍបន្ថែមប្រព័ន្ធគ្រប់គ្រងការងារបុគ្គលិក ទាំងនៅកម្រិតក្រសួង និងនៅតាមអង្គភាព | - អល-កសហវ.<br>- គ្រប់អង្គភាព | ✓ | ✓ | ✓ | | | | | | | |
| | **គោលដៅទី២ : ជំរុញស្មារតីសកម្ម និងបុរេសកម្ម** | | | | | | | | | | | | |
| | | **យុទ្ធសាស្ត្រគន្លឹះទី១ : របៀបរបបការងារ** | | | | | | | | | | | |
| | | ***ធ្វើផែនការ*** | | | | | | | | | | | |
| ២៥ | ១ | ពង្រឹងការយល់ដឹង គោរព និងឱ្យតម្លៃជំនាញ មុខងារ និងភារកិច្ចរបស់ខ្លួននៅគ្រប់អង្គភាព | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ២៦ | ២ | ពង្រឹងការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំនៅគ្រប់កម្រិត ដោយមានគម្រោងថវិកាច្បាស់លាស់ | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ២៧ | ៣ | បែងចែកភារកិច្ច និងការទទួលខុសត្រូវ ទៅតាមចង្កោម ឬ ផែនការងារ | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | ***អនុវត្តផែនការ*** | | | | | | | | | | | |
| ២៨ | ៤ | ជំរុញការរៀបចំគម្រោងអនុវត្តផែនការសកម្មភាព តាមខែ ត្រីមាស ឆមាស ដោយគិតគូរចាត់ចែងស្នើសុំ ឬទូទាត់ថវិកាសម្រាប់គាំទ្រសកម្មភាពទាន់ពេល | - អល-កសហវ.<br>- គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ២៩ | ៥ | ជំរុញអនុវត្តផែនការ តាមការបែងចែកភារកិច្ច | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | ***តាមដាននិងវាយតម្លៃ*** | | | | | | | | | | | |
| ៣០ | ៦ | ពង្រឹងការអនុវត្តរបបរាយការណ៍ និងរបបប្រជុំ ទៅតាមឋានានុក្រម និងតាមយន្តការការងារ | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៣១ | ៧ | ជំរុញការរាយការណ៍វឌ្ឍនភាព បញ្ហាប្រឈម និងស្នើសុំការណែនាំ កិច្ចសហការ និងអន្តរាគមន៍ដោះស្រាយពីថ្នាក់ដឹកនាំ ទៅតាមឋានានុក្រម និងនីតិវិធីរដ្ឋបាល | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| ល.រ.រួម | ល.រ | ការងារអាទិភាព | អង្គភាពទទួលបន្ទុក | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | **យុទ្ធសាស្ត្រគន្លឹះទី២ : វប្បធម៌ផលិតភាព គុណភាព និងប្រសិទ្ធភាព** | | | | | | | | | | | |
| ៣២ | ១ | ជំរុញសាកល្បងជាបណ្ដើរៗនូវការរៀបចំ និងការអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម រវាងប្រធានស្ថាប័ន ប្រធានកម្មវិធី និងអង្គភាពថវិកា ក្នុងក្របខណ្ឌថវិកា កម្មវិធី | - អល-កសហវ.<br>- គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៣៣ | ២ | ដាក់ឱ្យអនុវត្តក្របខណ្ឌលទ្ធផលផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងក្របខណ្ឌការងារប្រចាំថ្ងៃ | - អល-កសហវ.<br>- គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៣៤ | ៣ | ពង្រឹងការបែងចែកភារកិច្ច និងការអនុវត្តកិច្ចព្រមព្រៀងការងារសម្រាប់មន្ត្រីរាជការ | - អល-កសហវ.<br>- គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៣៥ | ៤ | បង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម | - អល-កសហវ.<br>- គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៣៦ | ៥ | អនុវត្តគោលការណ៍ប្រតិភូកម្មសិទ្ធិសម្រេច និងកំណត់បន្ទាត់គណនេយ្យភាពនៅតាមអង្គភាព | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | **យុទ្ធសាស្ត្រគន្លឹះទី៣ : សាមគ្គីភាពផ្ទៃក្នុង** | | | | | | | | | | | |
| ៣៧ | ១ | ពង្រឹងយន្តការទទួលព័ត៌មានត្រឡប់ (Feedback) ការស្ដាប់កង្វល់របស់ថ្នាក់ដឹកនាំ បុគ្គលិក និងមន្ត្រីក្រោមឱវាទ និងការអនុវត្តរបបប្រជុំរាយការណ៍ និងដោះស្រាយបញ្ហា | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៣៨ | ២ | ជំរុញតម្លាភាពក្នុងការបំពេញការងារ និងបង្កើនការចូលរួមរបស់មន្ត្រីគ្រប់រូបទាំងក្នុងសកម្មភាពការងារ និងសកម្មភាពកំសាន្តផ្សេងៗរបស់អង្គភាព ក្រៅម៉ោងការងារ ទៅតាមលទ្ធភាព | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៣៩ | ៣ | ពង្រឹងយន្តការដោះស្រាយបញ្ហាប្រឈមឆ្លងអង្គភាព ដោយសហការគ្នាតាមខ្សែទទឹង | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| ល.រ.រួម | ល.រ | ការងារអាទិភាព | អង្គភាពទទួលបន្ទុក | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤០ | ៤ | ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ត្រូវដើរតួនាទីជាអ្នកសម្របសម្រួល ថ្លឹងថ្លែង ដោះស្រាយវិវាទ | - ថ្នាក់ដឹកនាំក្រសួង<br>- គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | **យុទ្ធសាស្រ្តគន្លឹះទី៤ : ហេដ្ឋារចនាសម្ព័ន្ធគាំទ្រការបំពេញការងារ** | | | | | | | | | | | |
| ៤១ | ១ | ជំរុញពិនិត្យស្ថានភាពហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តគាំទ្រដល់ការបំពេញការងារ | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៤២ | ២ | រៀបចំយន្តការគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក សម្ភារ និងបច្ចេកវិទ្យាព័ត៌មាន | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | **យុទ្ធសាស្រ្តគន្លឹះទី៥ : ប្រព័ន្ធលើកទឹកចិត្ត ឬចាត់វិធានការ** | | | | | | | | | | | |
| ៤៣ | ១ | កសាង និងពង្រឹងប្រព័ន្ធលើកទឹកចិត្ត ទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ សម្បូរបែប | - អល-កសហវ.<br>- គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៤៤ | ២ | ពង្រឹងប្រព័ន្ធ និងយន្តការតាមដាននិងវាយតម្លៃសមិទ្ធកម្ម និងការផ្តល់ព័ត៌មានត្រឡប់ | - អល-កសហវ.<br>- គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៤៥ | ៣ | ពង្រឹងយន្តការក្រុមប្រឹក្សា គណៈកម្មការវិន័យ នៅតាមអង្គភាព និងនៅថ្នាក់ក្រសួង | - អល-កសហវ.<br>- គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | **គោលដៅទី៣ : ធានាភាពស្អាតស្អំ និងសុចរិតភាព** | | | | | | | | | | | | |
| | | **យុទ្ធសាស្រ្តគន្លឹះទី១ : វប្បធម៌ស្អាតស្អំ** | | | | | | | | | | | |
| ៤៦ | ១ | ពង្រឹងយន្តការផ្សព្វផ្សាយផ្ទៃក្នុងក្រសួង និងអង្គភាពក្រោមឱវាទ នូវលិខិតបទដ្ឋាន គោលនយោបាយដែលរៀបចំ | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៤៧ | ២ | រៀបចំកម្មវិធីលើកកម្ពស់ភាពស្អាតស្អំ និងសុចរិតភាពជាប្រចាំនៅកម្រិតក្រសួង និងផ្សព្វផ្សាយបន្តទៅតាមអង្គភាព | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៤៨ | ៣ | ផ្សព្វផ្សាយជាប្រចាំនូវប្រព័ន្ធលើកទឹកចិត្តរបស់ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុជាមួយនឹងអភិក្រមការងារ ៤ ប្រការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | - អល-កសហវ.<br>- គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| ល.រ.រួម | ល.រ | ការងារអាទិភាព | អង្គភាពទទួលបន្ទុក | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | **យុទ្ធសាស្ត្រគន្លឹះទី២ : ប្រព័ន្ធការងារសុចរិត** | | | | | | | | | | | |
| ៤៩ | ១ | ពង្រឹងការអនុវត្តគោលការណ៍ប្រតិគុល្យការ | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៥០ | ២ | ពង្រឹងការអនុវត្តគោលការណ៍វិសមិតភាពមុខងារ | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៥១ | ៣ | រៀបចំ និងអនុវត្តក្របខណ្ឌគតិយុត្ត និងគោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF Internal Control Guideline) | - គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៥២ | ៤ | ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការអធិការកិច្ច និងសវនកម្មផ្ទៃក្នុង | - អគ្គាធិការដ្ឋាន<br>- អសក. | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៥៣ | ៥ | ពង្រឹងយន្តការវាយតម្លៃសមិទ្ធកម្មការងារសម្រាប់មន្ត្រី និងអង្គភាព | - អល-កសហវ.<br>- គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៥៤ | ៦ | ពង្រឹងយន្តការទទួលព័ត៌មានត្រឡប់ និងយន្តការទទួលពាក្យបណ្តឹង | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | **យុទ្ធសាស្ត្រគន្លឹះទី៣ : សេវាស្អាតស្អំ** | | | | | | | | | | | |
| ៥៥ | ១ | រៀបចំ ដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយឱ្យទូលាយ នូវក្របខណ្ឌគតិយុត្ត និងគោលការណ៍ណែនាំផ្សេងៗពាក់ព័ន្ធនឹង ការផ្តល់សេវារបស់ក្រសួង | - អល-កសហវ. | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៥៦ | ២ | ពង្រឹងយន្តការផ្តល់សេវាដែលប្រមូលផ្តុំ នៅច្រកចេញចូលតែមួយ, កាត់បន្ថយការកាន់ឯកសារចរាចរផ្ទាល់ដោយអ្នកស្នើសុំសេវា, និងពង្រីកការផ្តល់សេវា និងការទូទាត់កម្រៃសេវាតាមប្រព័ន្ធឌីជីថល | - គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៥៧ | ៣ | ពង្រឹងយន្តការទទួលព័ត៌មានត្រឡប់ និងយន្តការទទួលពាក្យបណ្តឹង | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៥៨ | ៤ | ពង្រឹងរបបចុះត្រួតពិនិត្យជាប្រចាំ និងដោយមិនជូនដំណឹងជាមុន នៅតាមទីតាំងផ្តល់សេវា | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| ល.រ.រួម | ល.រ | ការងារអាទិភាព | អង្គភាពទទួលបន្ទុក | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៥៩ | ៥ | រៀបចំ និងពង្រឹងការវាយតម្លៃ និងទទួលស្គាល់អ្នកដឹកនាំគំរូ និងអង្គភាពផ្ដល់សេវាសាធារណៈគំរូ ប្រចាំក្រសួង និងការអនុវត្តការលើកទឹកចិត្តបន្ថែមផ្អែកលើគុណភាពនៃការផ្ដល់សេវា | - គ្រប់អង្គភាព | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | **យុទ្ធសាស្ត្រគន្លឹះទី៤ : ការងារសុចរិត** | | | | | | | | | | | |
| ៦០ | ១ | ពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការ | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៦១ | ២ | បង្កើតកិច្ចព្រមព្រៀងសុចរិតភាព សម្រាប់បុគ្គលិក និងមន្ត្រីថ្មី | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៦២ | ៣ | ពង្រឹងការអនុវត្តប្រព័ន្ធថវិកាសមិទ្ធកម្ម និងការអនុវត្តការងារ និងការលើកទឹកចិត្តផ្អែកលើលទ្ធផល | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៦៣ | ៤ | ពង្រឹងយន្តការត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មមន្ត្រី | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៦៤ | ៥ | ពង្រឹងការអនុវត្តវិធានការវិន័យ | - គ្រប់អង្គភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | **គោលបំណងទី២ : ប្រសិទ្ធភាពនៃការអនុវត្តមុខងារនិងភារកិច្ច** | | | | | | | | | | | | |
| | **គោលដៅទី១ : បង្កើនភាពធន់នៃមូលដ្ឋានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ** | | | | | | | | | | | | |
| | | **យុទ្ធសាស្ត្រគន្លឹះទី១ : ចីរភាពនៃកំណើន** | | | | | | | | | | | |
| ៦៥ | ១ | រៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដោយប្រុងប្រយ័ត្ន | - អគប.<br>- អគសហ.<br>- អង្គភាពពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៦៦ | ២ | ជំរុញរៀបចំយន្តការគ្រប់គ្រងវិបត្តិ និងហានិភ័យផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ អចលនទ្រព្យ និងវិស័យដទៃផ្សេងទៀត | - អគប.<br>- អគសហ.<br>- អសហ.<br>- អង្គភាពពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៦៧ | ៣ | ជំរុញរៀបចំក្របខណ្ឌគតិយុត្តសម្រាប់អនុវត្តច្បាប់ស្ដីពីវិនិយោគថ្មី និងច្បាប់ស្ដីពីតំបន់សេដ្ឋកិច្ចពិសេស | - អគសហ.<br>- អង្គភាពពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

